ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តព្រះសីហនុ
សំណុំរឿងព្រហ្មទណ្ឌលេខ ៧៣០
ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៩
សាលក្រមលេខ: **៦០០/៧០ (ឃ)**
ចុះថ្ងៃទី៣០ **ខែកក្កដា ឆ្នាំ២០២០**

នាមនាមប្រជារាស្ត្រខ្មែរ
សាលាដំបូងខេត្តព្រះសីហនុ

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី២៥ និងថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២០ នៅសាលាដំបូងខេត្តព្រះសីហនុ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជម្រះដូចតទៅ៖

ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ
លោក [redacted] ជាចៅក្រមប្រឹក្សា
លោក [redacted] ជាចៅក្រមប្រឹក្សា

តំណាងអយ្យការ

លោក [redacted] ជាព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តព្រះសីហនុ

ក្រឡាបញ្ជីសវនាការ

លោក [redacted] ជាក្រឡាបញ្ជីសាលាដំបូងខេត្តព្រះសីហនុ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ **៧៣០** ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៩ ដែលមាន ៖

១-ជនជាប់ចោទឈ្មោះ [redacted] **KUN** ភេទប្រុស កើតថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ១៩៨០ ជនជាតិចិន មុខរបរ "ពាណិជ្ជករ" កាន់លិខិតឆ្លងដែនលេខ E09299663 មានទីកន្លែងកំណើតនៅ [redacted] ប្រទេសចិន មានទីលំនៅមុនពេលឃាត់ខ្លួននៅ ផ្ទះជួល ស្ថិតនៅ ភូមិ៤ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ប្រពន្ធឈ្មោះ [redacted] **LI XIA** មានកូនចំនួន ០២ នាក់ ឪពុកឈ្មោះ [redacted] **GUANG MING** "រស់" ម្តាយឈ្មោះ [redacted] **JIM YIN** "រស់" ជានីតិជនប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការពីមុន "គ្មាន"។

- ឃាត់ខ្លួនថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៩
- ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ **៣០១៦ ត៣/១៩** ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៩
- ដីកាសម្រេចពន្យារពេលការឃុំខ្លួនជាបណ្តោះអាសន្នលេខ **៦៥៤៦ ត.៣/១៩** ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៩
- ដីកាបង្គាប់ឲ្យឃុំខ្លួនបន្តលេខ **៦៥៤៧ ត៣/១៩** ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៩
- មានលោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

២-ជនជាប់ចោទឈ្មោះ [redacted] **XING GUI** ភេទប្រុស កើតថ្ងៃទី១១ ខែតុលា ឆ្នាំ១៩៧១ ជនជាតិចិន មុខរបរ "ថៅកែមៅការសំណង់" កាន់លិខិតឆ្លងដែនលេខ G54375157 មានទីកន្លែងកំណើតនៅ ប្រទេសចិន ទីលំនៅមុនពេលឃាត់ខ្លួននៅ ផ្ទះជួល ស្ថិតនៅ សង្កាត់លេខ២

ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ប្រពន្ធឈ្មោះ [redacted] **THI THUY HOA** ហៅ អាហ័រ ជនជាតិវៀតណាម **ឪពុកឈ្មោះ**[redacted] **QIAN MING** "ស្លាប់" **ម្តាយឈ្មោះ**[redacted] **SHI LIANG** "រស់" ជានីតិជន ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការពីមុន "គ្មាន"។

- ឃាត់ខ្លួនថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៩
- ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ **៣០១៨ តត/១៩** ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៩
- ដីកាសម្រេចពន្យារពេលការឃុំខ្លួនជាបណ្តោះអាសន្នលេខ **៦៥៤៨ ត.ព/១៩** ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៩
- ដីកាបង្គាប់ឲ្យឃុំខ្លួនបន្តលេខ **៦៥៤៩ តព/១៩** ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៩
- មានលោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

ជាប់ចោទពីបទ៖ **មនុស្សឃាតដោយអចេតនា, បង្កឲ្យមានរបួសស្នាមដោយអចេតនា** និងបទ **ធ្វើឲ្យខូចខាតមានស្ថានទម្ងន់ទោសដោយសារការបង្ករបួសដល់អ្នកដទៃ** ប្រព្រឹត្តនៅ ក្រុមទី១៥ ភូមិ៣ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៩ បទល្មើសដែលមានចែង និងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **២០៧** មាត្រា **២៣៦** និងមាត្រា **៤១៤** នៃក្រមព្រហ្មទណ្ឌ។

៣-ជនជាប់ចោទឈ្មោះ [redacted] **YA PING** ភេទស្រី កើតថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ១៩៧៣ ជនជាតិចិន មុខរបរ "អ្នកជួយមើលការងារនៅក្នុងការដ្ឋាន" កាន់លិខិតឆ្លងដែនលេខ E69715733 មានទីកន្លែងកំណើតនៅ ខេត្តហ៊ូប៊ុ ប្រទេសចិន មានទីលំនៅមុនពេលឃាត់ខ្លួននៅ ផ្ទះជួល ស្ថិតនៅ ភូមិ៤ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ **ប្តីឈ្មោះ** [redacted] **BO XU** **ឪពុកឈ្មោះ** [redacted] **GUN DE** "រស់" **ម្តាយឈ្មោះ** [redacted] **DONG RONG** "រស់" ជានីតិជន ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការពីមុន "គ្មាន"។

- ឃាត់ខ្លួនថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៩
- ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ **៣០២០ តព/១៩** ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៩
- ដីកាសម្រេចពន្យារពេលការឃុំខ្លួនជាបណ្តោះអាសន្នលេខ **៦៥៥២ ត.ព/១៩** ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៩
- ដីកាបង្គាប់ឲ្យឃុំខ្លួនបន្តលេខ **៦៥៥៣ តព/១៩** ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៩
- លោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

៤-ជនជាប់ចោទឈ្មោះ **GOU YU** ភេទប្រុស កើតថ្ងៃទី២០ ខែមេសា ឆ្នាំ១៩៩០ ជនជាតិចិន មុខរបរ "ជាងសំណង់" កាន់លិខិតឆ្លងដែនលេខ EE04913731 មានទីកន្លែងកំណើតនៅ ខេត្ត[redacted] ប្រទេសចិន មានទីលំនៅមុនពេលឃាត់ខ្លួន មិនពិតប្រាកដ **ប្រពន្ធឈ្មោះ** [redacted] **YONG XIANG** **ឪពុកឈ្មោះ** [redacted] **BIAO BING** "រស់" **ម្តាយឈ្មោះ**[redacted] **FEI YUE** "រស់" ជានីតិជន ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការពីមុន "គ្មាន"។

- ឃាត់ខ្លួនថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៩
- ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ **៣០២២ តព/១៩** ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៩
- ដីកាសម្រេចពន្យារពេលការឃុំខ្លួនជាបណ្តោះអាសន្នលេខ **៦៥៥០ ត.ព/១៩** ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៩
- ដីកាបង្គាប់ឲ្យឃុំខ្លួនបន្តលេខ **៦៥៥១ តព/១៩** ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៩

Scanned with CamScanner

- លោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ។

៥-ជនជាប់ចោទឈ្មោះ [redacted] **THI THUY HOA** ហៅ **អាហ័រ** ភេទស្រី កើតថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៧៧ ជនជាតិវៀតណាម កាន់លិខិតឆ្លងដែនលេខ C2889935 ប្តីឈ្មោះ [redacted] **XING GUI**។

- ដីកាបង្គាប់ឲ្យចាប់ខ្លួនលេខ **៤៧/១៩** ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩
- លោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

៦-ជនជាប់ចោទឈ្មោះ [redacted] **ប៊ុនធឿន** ហៅ **ធឿន** ភេទប្រុស កើតថ្ងៃទី០៩ ខែសីហា ឆ្នាំ១៩៧៩ ជនជាតិខ្មែរ មុខរបរ -ជាងដែក- មានទីកន្លែងកំណើតនៅ [redacted] ខេត្តកំពង់ចាម ទីលំនៅបច្ចុប្បន្ននៅ ភូមិជ្រុយ សង្កាត់វិហារហ្លួង ក្រុងសួង ខេត្តត្បូងឃ្មុំ។

- ដីកាបង្គាប់ឲ្យចាប់ខ្លួនលេខ **៤៨/១៩** ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩
- លោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

ជាប់ចោទពីបទ៖ **សមគំនិតក្នុងអំពើមនុស្សឃាតដោយអចេតនា, សមគំនិតក្នុងអំពើបង្ករបួសស្នាមដោយអចេតនា** និង **សមគំនិតក្នុងអំពើធ្វើឲ្យខូចខាតមានស្ថានទម្ងន់ទោសដោយសារការបង្ករបួសដល់អ្នកដទៃ** ប្រព្រឹត្តនៅ ក្រុមទី១៥ ភូមិ៣ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៩ បទល្មើសដែលមានចែង និងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **២៩** មាត្រា **២០៧** មាត្រា **២៣៦** និងមាត្រា **៤១៤** នៃក្រមព្រហ្មទណ្ឌ។

-មានដើមបណ្តឹងរដ្ឋប្បវេណីៈ

១.ឈ្មោះ [redacted] **រិទ្ធីវុឌ្ឍ** ភេទប្រុស អាយុ ៥៧ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នភូមិ៣ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។

-មានលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិ។

២.ឈ្មោះ [redacted] **TOMOTAKA** ភេទប្រុស កើតឆ្នាំ១៩៧៣ ជនជាតិជប៉ុន និងឈ្មោះ [redacted] **YUKO** ភេទស្រី កើតឆ្នាំ១៩៧៣ ជនជាតិជប៉ុន មានទីលំនៅបច្ចុប្បន្នភូមិ៤ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។

-មានលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិ។

៣.ឈ្មោះ [redacted] **លីក្ន** អាយុ២០ ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅ ភូមិកូនវ៉ា ឃុំស្រែជិៈ ស្រុកសំបូរ ខេត្តក្រចេះ។

៤.ឈ្មោះ [redacted] **វ៉ែន** ហៅ [redacted] **ពៅ** ភេទប្រុស កើតឆ្នាំ១៩៩៩ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅ ភូមិស្រែឬស្សី ឃុំស្រែសំបូរ ស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង។

៥.ឈ្មោះ [redacted] **ប្រុស** ភេទប្រុស កើតឆ្នាំ១៩៩៩ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅ ភូមិស្រែឬស្សី ឃុំស្រែសំបូរ ស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង។

៦.ឈ្មោះ [redacted] **ដិត** ភេទស្រី កើតឆ្នាំ១៩៨២ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅ ភូមិស្រែឬស្សី ឃុំស្រែសំបូរ ស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង ជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវជាម្តាយរបស់សពឈ្មោះ [redacted] **តៃ**។

Scanned with CamScanner

៧.ឈ្មោះ [redacted] **កា** ភេទស្រី កើតឆ្នាំ១៩៧៣ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅភូមិស្រែឫស្សី ឃុំស្រែសំបូរ ស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង ជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវជាម្តាយរបស់សព ឈ្មោះ យ៉ន រឿន។

៨.ឈ្មោះ [redacted] **យ៉ុន** ភេទប្រុស កើតឆ្នាំ១៩៦៧ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅភូមិគិឡូប្រាំបី សង្កាត់សាមគ្គី ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង ជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវជាឪពុករបស់សពឈ្មោះ [redacted] ប៊ុនធី។

-មានលោកស្រី [redacted] ជាមេធាវីតំណាងដោយអាណត្តិ។

៩.ឈ្មោះ [redacted] **វ៉ាន់ជា** ភេទប្រុស កើតថ្ងៃទី០៤ ខែមីនា ឆ្នាំ១៩៨១ មានទីលំនៅបច្ចុប្បន្ននៅភូមិ៣ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។

-មានលោកស្រី [redacted] ជាមេធាវីតំណាងដោយអាណត្តិ។

១០.ឈ្មោ [redacted] **សុន** ភេទប្រុស កើតឆ្នាំ១៩៩០ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅភូមិជយោ ឃុំជយោ ស្រុកចំការលើ ខេត្តកំពង់ចាម។

១១.ឈ្មោះ [redacted] **ចំនឡាង** ភេទប្រុស កើតឆ្នាំ១៩៩៧ ជនជនខ្មែរ មានទីលំនៅបច្ចុប្បន្ននៅភូមិយាវ ឃុំកំពង់ចាម ស្រុកសំបូរ ខេត្តក្រចេះ ជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវជាបងប្រុសរបស់ជនរងគ្រោះឈ្មោះ [redacted] អូនណោង (រងរបួសធ្ងន់) និងត្រូវជាកូនរបស់សព ឈ្មោះ [redacted] **ណា** និងឈ្មោះ [redacted] **ដែន**។

១២.ឈ្មោះ [redacted] **ញ៉** ភេទប្រុស កើតឆ្នាំ១៩៦៩ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅភូមិ៦.១០ សង្កាត់វិហារហ្លួង ក្រុងសូង ខេត្តត្បូងឃ្មុំ ជាដើមបណ្តឹមរដ្ឋប្បវេណីត្រូវជាឪពុករបស់សពឈ្មោះ [redacted] **ចាន់ថន**។

១៣.ឈ្មោះ [redacted] **ចាន់ណេត** ភេទប្រុស កើតឆ្នាំ១៩៨៨ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅភូមិ៦.១០ សង្កាត់វិហារហ្លួង ក្រុងសូង ខេត្តត្បូងឃ្មុំ។

១៤.ឈ្មោះ [redacted] **អឿន** ភេទស្រី កើតឆ្នាំ១៩៩២ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅភូមិ៦១០ សង្កាត់វិហារហ្លួង ក្រុងសូង ខេត្តត្បូងឃ្មុំ។

១៥.ឈ្មោះ [redacted] **ម៉ារ៉ា** ភេទស្រី អាយុ២៨ ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅភូមិទ័ពត្បែង ឃុំពង្រ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវជាប្រពន្ធរបស់សពឈ្មោះ [redacted] **សុខហៀង**។

១៦.ឈ្មោះ [redacted] **យ៉ុន** ភេទស្រី អាយុ ៥០ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅភូមិទ័ពត្បែង ឃុំពង្រ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវជាប្រពន្ធរបស់សពឈ្មោះ [redacted] **មៅ**។

១៧.ឈ្មោះ [redacted] **ហាត់** ភេទស្រី អាយុ៤០ ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅភូមិទ័ពត្បែង ឃុំពង្រ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវជាប្រពន្ធរបស់សពឈ្មោះ [redacted] **វិច្ឆ័ក**។

១៨.ឈ្មោះ [redacted] **វណ្ណ** ភេទស្រី អាយុ៥០ ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅ ផ្ទះលេខ KH-CCF191 (អង្គការស្កុត) ផ្លូវលំ ក្រុមទី៩ ភូមិព្រែកទាល់ មណ្ឌល៨ សង្កាត់ស្ទឹងមានជ័យ១ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវជាម្តាយរបស់សពឈ្មោះ [redacted] **បញ្ញា**។

Scanned with CamScanner

១៩.ឈ្មោះ [redacted] **អិត** ភេទស្រី កើតឆ្នាំ១៩៧៧ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅភូមិត្រពាំងសាលា ឃុំឈើកាច់ ស្រុកបាភ្នំ ខេត្តព្រៃវែង ជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវជាប្រពន្ធរបស់សពឈ្មោះ [redacted] **មន។**

២០.ឈ្មោះ [redacted] **សំណាង** ភេទស្រី កើតឆ្នាំ១៩៨៤ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅភូមិត្រពាំងសាលា ឃុំឈើកាច់ ស្រុកបាភ្នំ ខេត្តព្រៃវែង និងឈ្មោះ [redacted] **ចំរើន** ត្រូវជាបងប្រុសរបស់សពឈ្មោះ [redacted] **ចន្ថា** ជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវជាប្រពន្ធ របស់សពឈ្មោះ [redacted] **ចន្ថា**។

២១.ឈ្មោះ [redacted] **ផៃ** ភេទប្រុស កើតឆ្នាំ១៩៦៩ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅភូមិត្រពាំងសាលា ឃុំឈើកាច់ ស្រុកបាភ្នំ ខេត្តព្រៃវែង ជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវជាឪពុករបស់សពឈ្មោះ [redacted] **ជាន់ណា។**

២២.ឈ្មោះ [redacted] **សាខន** ភេទស្រី កើតឆ្នាំ១៩៧៣ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅភូមិត្រពាំងសាលា ឃុំឈើកាច់ ស្រុកបាភ្នំ ខេត្តព្រៃវែង ជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវជាប្រពន្ធរបស់សពឈ្មោះ [redacted] **មៅ**។

២៣.ឈ្មោះ [redacted] **ថេន** ភេទប្រុស កើតឆ្នាំ១៩៧៣ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅភូមិត្រពាំងសាលា ឃុំឈើកាច់ ស្រុកបាភ្នំ ខេត្តព្រៃវែង ជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវជាឪពុករបស់សពឈ្មោះ [redacted] **ឃាន។**

២៤.ឈ្មោះ [redacted] **ថាន** ភេទប្រុស កើតឆ្នាំ១៩៧៦ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅ ភូមិមាត់ព្រៃ ឃុំជើងភ្នំ ស្រុកបាភ្នំ ខេត្តព្រៃវែង ជាឪពុកជនរងគ្រោះឈ្មោះ [redacted] **ចាន់ដេវីត** និងឈ្មោះ [redacted] **សុថាត** ភេទស្រី កើតឆ្នាំ១៩៩៥ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នភូមិអង្គាញ់ ឃុំឈើកាច់ ស្រុកបាភ្នំ ខេត្តព្រៃវែង ជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវជាប្រពន្ធរបស់សពឈ្មោះ [redacted] **ចាន់ដេវីត។**

២៥.ឈ្មោះ [redacted] **សុភាព** ភេទប្រុស កើតឆ្នាំ១៩៩៩ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅភូមិត្រពាំងសាលា ឃុំឈើកាច់ ស្រុកបាភ្នំ ខេត្តព្រៃវែង។

២៦.ឈ្មោះ [redacted] **សាផល់** ភេទប្រុស កើតឆ្នាំ១៩៨០ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅភូមិក្រូច ឃុំកន្សោមអក ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។

២៧.ឈ្មោះ [redacted] **ជា** ភេទប្រុស កើតឆ្នាំ១៩៨៨ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅភូមិត្រពាំងសាលា ឃុំឈើកាច់ ស្រុកបាភ្នំ ខេត្តព្រៃវែង ជាជនរងគ្រោះ។

២៨.ឈ្មោះ [redacted] **រស់** ភេទប្រុស កើតឆ្នាំ១៩៧៨ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅភូមិត្រពាំងស្វាយ ឃុំស្តៅកោង ស្រុកបាភ្នំ ខេត្តព្រៃវែង ជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវជាឪពុករបស់ជនរងគ្រោះឈ្មោះ [redacted] **គា**។

២៩.ឈ្មោះ [redacted] **ស៊ីថា** ភេទប្រុស កើតឆ្នាំ១៩៧៨ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នភូមិក្រូច ឃុំកន្សោមអក ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។

-មានលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិ។

៣០.ឈ្មោះ [redacted] **ម៉ុម** ភេទស្រី កើតឆ្នាំ១៩៦៥ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅក្រុមទី០៩ ភូមិអូរដា ឃុំបូរ ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ត្រូវជាម្តាយរបស់សពជនរងគ្រោះឈ្មោះ [redacted] ចន្ថា និងត្រូវជាម្តាយក្មេករបស់សពជនរងគ្រោះឈ្មោះ [redacted] ប្រុស។

Scanned with CamScanner

៣១.ឈ្មោះ [redacted] **សុភា** ភេទស្រី កើតឆ្នាំ១៩៨៣ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅភូមិចិនតាយ ឃុំមេទឹក ស្រុកបាកាន ខេត្តពោធិ៍សាត់ ជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវជាប្រពន្ធរបស់សពឈ្មោះ [redacted] **ទឹម**។

៣២.ឈ្មោះ [redacted] **កែនរស្មី** ភេទប្រុស កើតឆ្នាំ១៩៨៦ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ១០៤ ភូមិត្រពាំងទូល សង្កាត់កំបូល ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវជាប្តីរបស់សពឈ្មោះ [redacted] **លំអង**។

៣៣.ឈ្មោះ [redacted] **សុខន** ភេទប្រុស កើតឆ្នាំ១៩៨០ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅភូមិចិនតាយ ឃុំមេទឹក ស្រុកបាកាន ខេត្តពោធិ៍សាត់។

៣៤.ឈ្មោះ [redacted] **នាង** ភេទប្រុស កើតឆ្នាំ១៩៨៥ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅភូមិចិនតាយ ឃុំមេទឹក ស្រុកបាកាន ខេត្តពោធិ៍សាត់។

៣៥.ឈ្មោះ [redacted] **ចំណែន** ភេទប្រុស កើតឆ្នាំ១៩៨៩ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅភូមិចិនតាយ ឃុំមេទឹក ស្រុកបាកាន ខេត្តពោធិ៍សាត់។

៣៦.ឈ្មោះ [redacted] **ប៊ុនធឿន** ភេទប្រុស កើតឆ្នាំ១៩៧៩ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅភូមិចិនតាយ ឃុំមេទឹក ស្រុកបាកាន ខេត្តពោធិ៍សាត់។

៣៧.ឈ្មោះ [redacted] **សែន** ភេទប្រុស កើតឆ្នាំ១៩៧៩ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅភូមិចិនតាយ ឃុំមេទឹក ស្រុកបាកាន ខេត្តពោធិ៍សាត់។

៣៨.ឈ្មោះ [redacted] **ស្រីកា** ភេទស្រី អាយុ២៣ ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅភូមិព្រៃទទឹង ឃុំអង្គសុភី ស្រុកកំពង់ត្រាច ខេត្តកំពត ជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវជាបងបង្កើតរបស់សពឈ្មោះ [redacted] **សុភ័ណ្ឌ**។

៣៩.ឈ្មោះ [redacted] **ប្រុស** ភេទប្រុស កើតឆ្នាំ១៩៧១ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅភូមិព្រៃទទឹង ឃុំអង្គសុភី ស្រុកកំពង់ត្រាច ខេត្តកំពត ជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវជាឪពុករបស់សពឈ្មោះ [redacted] **សំណាង** និងឈ្មោះ [redacted] **ភក្រា**។

៤០.ឈ្មោះ [redacted] **សុខឿន** ភេទស្រី អាយុ៤៨ ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅភូមិព្រៃទទឹង ឃុំអង្គសុភី ស្រុកកំពង់ត្រាច ខេត្តកំពត ជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវជាម្តាយរបស់សពឈ្មោះ [redacted] **ឫទិន**។

៤១.ឈ្មោះ [redacted] **សារុន** ភេទស្រី កើតឆ្នាំ១៩៨២ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅភូមិបឹងធំខាងកើត ឃុំអង្គសុភី ស្រុកកំពង់ត្រាច ខេត្តកំពត ជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវជាប្រពន្ធរបស់សពឈ្មោះ [redacted] **ម៉េង**។

៤២.ឈ្មោះ [redacted] **លេង** ភេទស្រី កើតឆ្នាំ១៩៨១ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅភូមិបឹងធំខាងកើត ឃុំអង្គសុភី ស្រុកកំពង់ត្រាច ខេត្តកំពត ជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវជាប្រពន្ធរបស់សពឈ្មោះ [redacted] **ថាវ ហៅ ចាន់តូ**។

៤៣.ឈ្មោះ [redacted] **ពៅ** ភេទប្រុស កើតឆ្នាំ១៩៩១ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅភូមិអង្គសុភី ឃុំបឹងសាលាខាងជើង ស្រុកកំពង់ត្រាច ខេត្តកំពត។

៤៤.ឈ្មោះ [redacted] **ឃាង** ភេទប្រុស កើតឆ្នាំ១៩៩២ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅភូមិដាសស្តរ ឃុំបឹងសាលាខាងជើង ស្រុកកំពង់ត្រាច ខេត្តកំពត។

៤៥.ឈ្មោះ [redacted] **វុធ** ភេទប្រុស អាយុ៣៨ ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅភូមិបឹងធំខាងកើត ឃុំអង្គសុភី ស្រុកកំពង់ត្រាច ខេត្តកំពត។

៤៦.ឈ្មោះ [redacted] **ផេត** ភេទប្រុស កើតឆ្នាំ១៩៨១ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅភូមិព្រៃស្បូវ ឃុំនរាយណ៍ ស្រុកឈូក ខេត្តកំពត។

៤៧.ឈ្មោះ [redacted] **ប្រុស** ភេទប្រុស កើតឆ្នាំ១៩៨៦ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅភូមិត្រពាំងឈើទាល ឃុំជ្រៃស ស្រុកជុំគីរី ខេត្តកំពត។

៤៨.ឈ្មោះ [redacted] **សំអុល** ភេទប្រុស កើតឆ្នាំ១៩៨៤ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅភូមិត្រពាំងឈើទាល ឃុំជ្រៃស ស្រុកជុំគីរី ខេត្តកំពត។

៤៩.ឈ្មោះ [redacted] **សាវ៉ាត** ភេទប្រុស កើតឆ្នាំ១៩៩០ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅភូមិត្រពាំងឈើទាល ឃុំជ្រៃស ស្រុកជុំគីរី ខេត្តកំពត។

៥០.ឈ្មោះ [redacted] **ធីម** ភេទប្រុស កើតឆ្នាំ១៩៦៦ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅភូមិព្រៃស្បូវ ឃុំនរាយណ៍ ស្រុកឈូក ខេត្តកំពត។

-មានលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិ។

-មានសាក្សី:

១.លោក [redacted] **ន៏ម** ភេទប្រុស អាយុ ៤៩ឆ្នាំ ទីលំនៅបច្ចុប្បន្ននៅភូមិ៤ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ជាចៅសង្កាត់លេខ៤។

២.លោក [redacted] **សីហា** ភេទប្រុស អាយុ ៣៥ឆ្នាំ ទីលំនៅបច្ចុប្បន្ននៅភូមិ២ សង្កាត់លេខ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ជាប្រធានការិយាល័យអង្គភាពលទ្ធកម្មសាលាក្រុងព្រះសីហនុ។

៣.លោក [redacted] **ថៃសរ** ភេទប្រុស អាយុ ៣៦ឆ្នាំ ទីលំនៅបច្ចុប្បន្ននៅភូមិ១ សង្កាត់លេខ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ជាប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ក្រុងព្រះសីហនុ។

៤.លោក [redacted] **សុវន្ត** ភេទប្រុស អាយុ ៤៦ ឆ្នាំ ទីលំនៅបច្ចុប្បន្ននៅផ្ទះលេខG6 ផ្លូវលេខ១ ភូមិក្រោលគោ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ជាប្រធានការិយាល័យសំណង់នៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលខេត្តព្រះសីហនុ។

៥.លោក [redacted] **ចិត្តនិយម** ភេទប្រុស អាយុ ៥០ឆ្នាំ ទីលំនៅបច្ចុប្បន្ននៅភូមិ១ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ជាប្រធានការិយាល័យ អភិវឌ្ឍន៍សំណង់ នៃសាលាខេត្តព្រះសីហនុ។

៦.លោក [redacted] **ជានរិន** ភេទប្រុស អាយុ ៤៣ឆ្នាំ ទីលំនៅបច្ចុប្បន្ននៅភូមិ២ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ជានាយកទីចាត់ការអន្តរវិស័យនៃសាលាខេត្តព្រះសីហនុ។

៧.លោក [redacted] **សុផល** ជាមេធាវីការពារសិទ្ធិឲ្យលោក [redacted] **ស្រុង**, លោក [redacted] **សុវន្ត** និងលោក [redacted] **ថៃសរ**

៨.ឈ្មោះ [redacted] **ហ៊ុយ** ជាម្ចាស់ដីជួល មានទីលំនៅបច្ចុប្បន្ននៅ ក្រុមទី១៥ ភូមិ៣ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។

៩.ឈ្មោះ [redacted] សុវិន មានទីលំនៅបច្ចុប្បន្ននៅ ធ្វើការសំណង់នៅម្តុំទួលសង្កែ។

-បានឃើញរបាយការណ៍លេខ **១៤៤ រ.ប.ក/១៩** ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៩ របស់ការិយាល័យព្រហ្មទណ្ឌកម្រិតធ្ងន់នៃស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ។

-បានឃើញកំណត់ហេតុទទួលវត្ថុតាងលេខ **៤០០ រ.ត/១៩** ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៩ របស់លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងខេត្តព្រះសីហនុ។

-បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ **២៩៦៧ អ.យ.ត/១៩** ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៩ របស់តំណាងអយ្យការអមសាលាដំបូងខេត្តព្រះសីហនុ។

-បានឃើញដីកាសន្និដ្ឋានស្តាពរលេខ **១៥៨៦ អ.យ.ត/២០** ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូងខេត្តព្រះសីហនុ។

-បានឃើញដីកាដំណោះស្រាយលេខ **១៥៥៩/២០** ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តព្រះសីហនុ។

-បានឃើញដីការក្សាទុកជនត្រូវចោទឲ្យនៅក្នុងឃុំលេខ **២០៨៨/២០** លើឈ្មោះ [redacted] KUN, លេខ **២០៩១/២០** លើឈ្មោះ [redacted] YU, លេខ**២០៨៩/២០** លើឈ្មោះ [redacted] XING GUI និងលេខ**២០៩០/២០** លើឈ្មោះ [redacted] YAPING ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តព្រះសីហនុ។

<u>អង្គហេតុនៃបណ្តឹងចោទប្រកាន់មានដូចតទៅ</u>

កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៩ វេលាម៉ោង ០៤ និង ៣០ នាទី ទៀបភ្លឺ នៅចំណុចតាមបណ្តោយផ្លូវ ៧ មករា ស្ថិតនៅ ក្រុមទី១៥ ភូមិ៣ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ មានករណី **មនុស្សឃាតដោយអចេតនា, បង្កឲ្យមានរបួសស្នាមដោយអចេតនា និងធ្វើឲ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោស** មួយបានកើតឡើងដោយមានហេតុការណ៍ រលំបាក់សំណង់អាគារដែលកំពុងសាងសង់បានកំពស់ ៧ ជាន់ បណ្តាលឲ្យសង្កត់លើកម្មការសំណង់ស្លាប់ជាង ២០ នាក់ និងរបួសជាង ២០ នាក់ ហើយក៏បណ្តាលឲ្យខូចខាតផ្ទះអ្នកជិតខាង ១ ខ្នង ខូចខាតរោងលាងរថយន្ត និងធ្វើឲ្យខូចខាតរថយន្តជាច្រើនគ្រឿង ព្រមទាំងបានបណ្តាលឲ្យមានរបួសអ្នកជិតខាងដែលស្នាក់នៅក្នុងផ្ទះរបស់ខ្លួនផងដែរ។ មកទល់នឹងថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៩ នេះ កម្លាំងជំនាញ រួមទាំងអាជ្ញាធរដែលពាក់ព័ន្ធបាននឹងកំពុងព្យាយាម ចុះជួយកាយកំទេចអាគារដែលបាក់រលំនោះ ដើម្បីជួយសង្គ្រោះជនរងគ្រោះបន្តទៀត។ ក្នុងអង្គហេតុខាងលើគឺឈ្មោះ CHENG KUN បានជួលទីតាំងដីខាងលើពីឈ្មោះ [redacted] ហ៊ុយ ភេទប្រុស កើតឆ្នាំ១៩៥៥ តាមកិច្ចសន្យាចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៨។ ឈ្មោះ [redacted] KUN បានព្រមព្រៀងគ្នាសាងសង់អាគារខាងលើដោយមានឈ្មោះ [redacted] XING GUI ទទួលមៅការសាងសង់សំណង់ខាងលើ។ ក្នុងការមៅការសាងសង់នេះ គឺឈ្មោះ [redacted] XING GUI មានភាគហ៊ុន ៤៩% និងឈ្មោះ [redacted] HUA មានភាគហ៊ុន ៥១% ហើយមានឈ្មោះ [redacted] ប៊ុនធឿន ហៅ ធឿន ជាជាងដែក។ ការរត់ច្បាប់សាងសង់គឺឈ្មោះ [redacted] THI THUY HOA ហៅ អាហ័រ ត្រូវជាប្រពន្ធរបស់ឈ្មោះ [redacted] XING GUI ជាអ្នកចាត់ចែងទាំងអស់។ ចំណែកឈ្មោះ [redacted] YU ជាមេការមៅការបូកជញ្ជាំងអាគារនេះ។ ក្នុងអំឡុងពេលនៃការសាងសង់អាគារខាងលើនេះ ជនរងគ្រោះដែលជាអ្នកជិតខាងបានដាក់ពាក្យបណ្តឹងជាច្រើនឡើកទៅអាជ្ញាធរមានសមត្ថកិច្ច ដើម្បីជួយអន្តរាគមន៍ដោយមូលហេតុការដ្ឋាននោះមានបញ្ហា និងបណ្តាលឲ្យប៉ះពាល់ដល់ទ្រព្យសម្បត្តិជាអ៊ីយ៉ៗ ហើយសមត្ថកិច្ចជំនាញក៏បានចុះមកត្រួតពិនិត្យ និងបានចុះផ្អាកការសាងសង់ផងដែរ។ ប៉ុន្តែអាគារខាងលើនៅតែអាចសាងសង់បន្តទៀត រហូតបង្កឲ្យមានគ្រោះថ្នាក់មហន្តរាយបណ្តាលឲ្យស្លាប់ និងរបួសជនរងគ្រោះជាច្រើននាក់។

នាពេលសវនាការ

-ដូចមានក្នុងកំណត់ហេតុស្តីពីការជំនុំជម្រះកាលពីថ្ងៃទី២៥ និងថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តព្រះសីហនុ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់ចម្លើយសាក្សី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីជនជាប់ចោទ

-ក្រោយពីបានស្តាប់សម្តីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យឯកសារ និងវត្ថុតាងនានា

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

សាលាដំបូងខេត្តព្រះសីហនុ

យល់ឃើញថា

១.ជនជាប់ចោទឈ្មោះ [redacted] **KUN** ភេទប្រុស កើតថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ១៩៨០ ជនជាតិចិន និងឈ្មោះ [redacted] **XING GUI** ភេទប្រុស កើតថ្ងៃទី១១ ខែតុលា ឆ្នាំ១៩៧១ ជនជាតិចិន (សារតារជាតិខាងលើ) ត្រូវបានតំណាងអយ្យការដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទ **មនុស្សឃាតដោយអចេតនា, បង្ករបួសស្នាមដោយអចេតនា** និងបទ **ធ្វើឲ្យខូចខាតមានស្ថានទម្ងន់ទោសដោយសារការបង្ករបួសដល់អ្នកដទៃ។** រីឯជនជាប់ចោទឈ្មោះ [redacted] **YA PING** ភេទស្រី កើតថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ១៩៧៦ ជនជាតិចិន, ឈ្មោះ [redacted] **YU** ភេទប្រុស កើតថ្ងៃទី២០ ខែមេសា ឆ្នាំ១៩៩០ ជនជាតិចិន, ជនជាប់ចោទឈ្មោះ [redacted] **THI THUY HOA** ហៅ **អាហ័រ** ភេទស្រី កើតថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៧៧ ជនជាតិវៀតណាម និងឈ្មោះ [redacted] **ប៊ុនធឿន** ហៅ **ធឿន** ភេទប្រុស កើតថ្ងៃទី០៩ ខែសីហា ឆ្នាំ១៩៧៩ ជនជាតិខ្មែរ (សារតារជាតិខាងលើ) ត្រូវបានតំណាងអយ្យការដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទ **សមគំនិតក្នុងអំពើមនុស្សឃាតដោយអចេតនា, បទ សមគំនិតក្នុងអំពើបង្ករបួសស្នាមដោយអចេតនា** និងបទ **សមគំនិតក្នុងអំពើធ្វើឲ្យខូចខាតមានស្ថានទម្ងន់ទោសដោយសារការបង្ករបួសដល់អ្នកដទៃ** តាមដីកាសន្និដ្ឋានស្តាពរលេខ **១៥៤៦ អ.យ.ក/២០** ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២០ និងត្រូវបានចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តព្រះសីហនុបញ្ជូនទៅជំនុំជម្រះតាមដីកាដំណោះស្រាយលេខ **១៥៥៩/២០** ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០២០។

គស្តុតាងមាន

២.ជនជាប់ចោទឈ្មោះ [redacted] KUN បានឆ្លើយគ្រប់ដំណាក់កាលនីតិវិធីមានលក្ខណៈប្រហាក់ប្រហែលគ្នាថា: ខ្លួនមកប្រទេសកម្ពុជាក្នុងឆ្នាំ២០១៥ មានគោលបំណងទេសចរណ៍ និងមើលស្ថានភាពសេដ្ឋកិច្ច លុះដល់ឆ្នាំ២០១៦ ខ្លួនចាប់ផ្តើមបើកអាជីវកម្មភោជនីយដ្ឋានឈ្មោះ [redacted] KUN។ ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៨ ខ្លួនបានធ្វើកិច្ចសន្យាជួលដីពីឈ្មោះ ញឹក ហ៊ុយ ដោយជួលក្នុងមួយខែតម្លៃ ៦.០០០ (ប្រាំមួយពាន់) ដុល្លារអាមេរិក ក្រោយពេលជួលដីបានរយៈពេល ០៦ (ប្រាំមួយ) ខែ ខ្លួនចាប់ផ្តើមចុះកិច្ចសន្យាជាមួយឈ្មោះ [redacted] XING GUI ដើម្បីសាង

Scanned with CamScanner

សង់សណ្ឋាគារ មានកម្ពស់ ០៥ ជាន់ ស្មើនឹង ១៩ ម៉ែត្រ បានប្រគល់ប្រាក់ចំនួន ៣០ ភាគរយ ស្មើនឹងទឹកប្រាក់ ២០១.៤០០ (ពីរសែនមួយពាន់បួនរយ) ដុល្លារអាមេរិក ឲ្យទៅឈ្មោះ [redacted] XING GUI និងបានប្រគល់ប្រាក់ចំនួន ១៥.០០០ (មួយម៉ឺនប្រាំពាន់) ដុល្លារអាមេរិក ឲ្យទៅប្រពន្ធ ឈ្មោះ [redacted] XING GUI ឈ្មោះ [redacted] THI THUY HAO ហៅ អាហ័រ ដើម្បីបំពេញ បែបបទសុំច្បាប់សាងសង់ ហើយគេបានប្រាប់ខ្លួនថាមានរយៈពេល ០៣ (បី) ខែ ទើបទទួលបាន ច្បាប់សាងសង់នោះ បន្ទាប់មកឈ្មោះ [redacted] XING GUI បានចាប់ផ្តើមការងារសាងសង់ បណ្តើរៗតែម្តង។

ក្នុងរយៈពេលកំពុងសាងសង់នៅអំឡុងឆ្នាំ ២០១៩ មានអាជ្ញាធរចុះមកបាញ់ថ្នាំ នៅលើសំណង់ឲ្យផ្អាកការសាងសង់ ដោយមូលហេតុអាជ្ញាធរឲ្យដាក់សំណាញ់ការពារកុំឲ្យមានធ្លាក់ដុំថ្មមកខាងក្រោមអគារ។ បន្ទាប់មកឈ្មោះ [redacted] XING GUI បានធ្វើការដោះស្រាយជាមួយអាជ្ញាធររួចរាល់ និងបន្តសកម្មភាពសាងសង់សំណង់អគារបន្តទៀត រហូតមកដល់អំឡុងខែមករា ឆ្នាំ២០១៩ អគារបានសាងសង់បានចំនួន ០៤ (បួន) ជាន់ ហើយខ្លួនមានបំណងចង់សាងសង់បន្ថែមចំនួន ០២ (ពីរ) ជាន់បន្ថែមទៀត ទើបខ្លួនបានហៅមិត្តភក្តិ ដែលជាមេការសំណង់ឈ្មោះ ZHU មកជួយពិនិត្យសំណង់អគារ ដោយធ្វើការវាស់វែង ថ្លឹងម៉ែត្រទឹក និងទំលាក់ប្រយោល បានដឹងថាសំណង់អគារនោះទ្រេតប្រហែល ៩.០៥ (មួយកណ្តាក់សញ្ញា ប្រាំ) តឹក ទៅ ០២ (ពីរ) តឹក ទៅខាងអរុណរះ ខ្លួនបានសួរទៅមេការឈ្មោះ [redacted] XING GUI ថាមានបញ្ហាដល់អគារ ឬអត់? មេការឈ្មោះ [redacted] XING GUI បានប្រាប់ខ្លួនថាទ្រេតប៉ុណ្ណឹងអត់មានបញ្ហាអ្វីទេ គាត់អាចកែច្នៃ និងបានអះអាងថាអាចសាងសង់បន្តទៀតបាន ទើបខ្លួនបានប្រគល់ប្រាក់បន្ថែមចំនួន ៨០.០០០ (ប្រាំបីម៉ឺន) ដុល្លារអាមេរិក ទៅឲ្យមេការសំណង់ឈ្មោះ [redacted] XING GUI ដើម្បីចាប់ផ្តើមសាងសង់សំណង់អគារបន្ថែម ០២ (ពីរ) ជាន់ ទៀត សរុបមកអគារទាំងមូលមានកម្ពស់០៨ (ប្រាំបី) ជាន់ គិតទាំងជាន់ដំបូល លុះពេលចាប់ផ្តើមសាងសង់ដល់ជាន់ដំបូលលើ ស្រាប់តែអគារទាំងមូលបានដួលរលំ នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៩ វេលាម៉ោង ០៥ និង ០០ ទៀបភ្លឺតែម្តង។

មេការសំណង់ឈ្មោះ [redacted] XING GUI បានមៅការសាងសង់សំណង់អគារពីខ្លួនទាំងអស់ ទាំងសម្ភារៈ និងកម្លាំងពលកម្មផងដែរ។ រីឯឈ្មោះ [redacted] YAPING ជាបងស្រីជីដូនមួយខ្លួន មានតួនាទីជាអ្នកដាំស្ល និងធ្វើការងារផ្ទះ ចំណែកឯឈ្មោះ [redacted] YU មានតួនាទីជាជាងបៀកស៊ីម៉ង់ត៍ និងលាបថ្នាំអគារ, ឈ្មោះ [redacted] ប៊ុនធឿន គឺជាជាងផ្សារដែកដែលមៅការងារសាងសង់គ្រោងដែកអគារបន្តពីឈ្មោះ [redacted] XING GUI ដោយឡែកឈ្មោះ [redacted] THI THUY HAO ហៅ អាហ័រ ជាអ្នកទទួលបំពេញបែបបទចេញច្បាប់សាងសង់អគារឲ្យខ្លួន និងត្រូវជាប្រពន្ធរបស់មេការសំណង់ឈ្មោះ [redacted] XING GUI ផងដែរ។ ខ្លួនពុំបានដឹងថានៅក្នុងហេតុការណ៍បាក់រលំអគាររបស់ខ្លួនបានធ្វើឲ្យមានមនុស្សស្លាប់ និងរងរបួស ប៉ុន្មាននាក់នោះទេ និងពុំបានដឹងដែរថាបានបង្កការខូចខាតដល់ទ្រព្យសម្បត្តិរបស់អ្នកជិតខាងអស់ប៉ុន្មានដែរ ពីព្រោះខ្លួនត្រូវបានសមត្ថកិច្ចបានធ្វើការឃាត់ខ្លួន និងសាកសួរនៅស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ ប៉ុន្តែក្រោយមកខ្លួនបានដឹងថាក្នុងហេតុការណ៍បាក់រលំអគាររបស់ខ្លួននោះ បានបណ្តាលឲ្យមានមនុស្សស្លាប់ និងរបួសជាច្រើននាក់ និងបានបង្កការខូចខាតទ្រព្យសម្បត្តិអ្នកជិតខាងអស់ជាច្រើន តាមរយៈសមត្ថកិច្ចប្រាប់។

ជនជាប់ចោទជាម្ចាស់គម្រោងសាងសង់សំណង់សណ្ឋាគារ ដែលបានមៅការសាងសង់ឲ្យ ឈ្មោះ [redacted] XING GUI បានបំពានកាតព្វកិច្ចសន្តិសុខ និងកាតព្វកិច្ចប្រុងប្រយ័ត្នដែលច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិក្រោមច្បាប់ដែលចេញដោយក្រសួង រៀបចំដែនដីនគរូនីយកម្ម សំណង់ និងសុរិយោដីនៃព្រះរាជាណាចក្រកម្ពុជាតម្រូវ ដែលបានបញ្ជាឲ្យមេការសំណង់ឈ្មោះ [redacted] XING GUI ធ្វើការសាងសង់សំណង់សណ្ឋាគារទាំងខ្លួនបានដឹងយ៉ាងច្បាស់ថាការសាងសង់សំណង់សណ្ឋាគារ ពុំបានគោរពទៅតាមបទដ្ឋានបច្ចេកទេសសំណង់ ដែលបានធ្វើឲ្យប៉ះពាល់ទៅដល់គុណភាពសំណង់ទាំងមូល និងអាយុជីវិតរបស់កម្មករសំណង់ ដែលស្នាក់នៅ និងធ្វើការងារក្រោមអគារ ព្រមទាំងបានបង្កឲ្យមានរបួស និងព្យសនកម្មផ្នែកខាងសម្ភារៈ និងស្មារតីដល់អ្នកជិតខាងនៃអគាររបស់ខ្លួនជាច្រើន។

៣.ជនជាប់ចោទឈ្មោះ [redacted] XING GUI បានឆ្លើយនៅគ្រប់ដំណាក់កាលនីតិវិធីមានលក្ខណៈប្រហាក់ប្រហែលគ្នាថា: នៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៨ ខ្លួនបានចុះកិច្ចព្រមព្រៀងទទួលមៅការសាងសង់សណ្ឋាគារមានកម្ពស់ ០៥ (ប្រាំ) ជាន់ ពីម្ចាស់គម្រោងឈ្មោះ [redacted] KUN និងបានប្រគល់សិទ្ធិឲ្យឈ្មោះ [redacted] THI THUY HAO ហៅ អាហ័រ ជាអ្នកបំពេញបែបបទសុំច្បាប់សាងសង់ និងរកកម្មករមកធ្វើការ។ ខ្លួនមានតួនាទីជាអ្នកផ្សារគ្រោងដែកបង្គុំ និងពិនិត្យលក្ខណៈបច្ចេកទេសសំណង់ចាប់ពីជាន់ទី ០១ (មួយ) ដល់ជាន់ទី ០៥ (ប្រាំ) ប៉ុន្តែខ្លួនពុំបានទទួលមៅការបុកគ្រឹះនោះទេ។ ក្រោយពីការសាងសង់អគារបានចំនួន ០៥ (ប្រាំ) ជាន់ ឈ្មោះ [redacted] KUN បានឲ្យខ្លួនសាងសង់អគារនោះចំនួន ០២ (ពីរ) ជាន់ បន្ថែមទៀត ហើយខ្លួនបានចុះកិច្ចព្រមព្រៀងមៅការសាងសង់បន្ថែមនោះតាមការស្នើសុំរបស់ឈ្មោះ [redacted] KUN។

ក្រោយពេលចុះកិច្ចព្រមព្រៀងសាងសង់បន្ថែមរួច ខ្លួនបានផ្សារដែកបង្គុំចូលគ្នា តទៅលើទៀតដល់ជាន់ទី ០៦ (ប្រាំមួយ) បន្ទាប់មកឈ្មោះ [redacted] KUN ជាអ្នករកកម្មកររ៉ែ មកផ្សារដែកបង្គុំឡើងទៅលើបន្តពីខ្លួន រហូតដល់ជាន់ទី ០៧ (ប្រាំពីរ) ហើយការសាងសង់អគារចាប់ពីជាន់ទី ០៧ (ប្រាំពីរ) តទៅ ខ្លួនលែងទទួលខុសត្រូវទៀតហើយ។ នៅពេលចាប់ផ្តើមសាងសង់អគារបន្ថែមចំនួន ០២ (ពីរ) ជាន់បន្ថែមទៀតនោះ ខ្លួនបានគណនាឃើញថា ត្រូវប្រើដែកសរសរចំនួន ២០ (ម្ភៃ) ដើម មានប្រវែង ១២ (ដប់ពីរ) ម៉ែត្រ ដោយដែកក្នុងមួយដើមអាចទ្រទម្ងន់ចំនួន ៧៩២ (ប្រាំពីររយកៅសិបពីរ) គីឡូក្រាម ហើយសំណង់ទាំងមូលក្នុងមួយជាន់មានទម្ងន់ ១៥.៨៤០ (មួយម៉ឺន ប្រាំពាន់ប្រាំបីរយសែសិប) គីឡូក្រាម ចំពោះអគារកម្ពស់ ០៧ (ប្រាំពីរ) ជាន់ មានទម្ងន់សរុប ប្រមាណ ១៨០ (មួយរយប៉ែតសិប) តោន ហើយចំពោះគ្រឹះអគារអាចទ្រទម្ងន់អគារទាំងមូលបានពុំមានបញ្ហាអ្វីទេ។ ចំពោះសំណង់អគារដែលបានបាក់រលំនេះ បណ្តាលមកពីឈ្មោះ [redacted] KUN ចង់ធ្វើបន្ទប់ក្រោមដីមួយជាន់បន្ថែមទៀត និងបានឲ្យកម្មកររាយឥដ្ឋដែលរៀបជាប់នឹងជើងសរសរនៃជាន់ទី ០១ (មួយ) ចេញ បណ្តាលឲ្យសរសរអគារទាំងមូលលែងមានកម្លាំងទប់ ទើបបណ្តាលឲ្យអគារទាំងមូលត្រូវបាក់រលំតែម្តង។ ចំពោះកម្មករដែលស្លាប់ និងរងរបួសពីការបាក់រលំអគារទាំងមូលមិនមែនជាកម្មកររបស់ខ្លួនទេ ជាកម្មករដែលឈ្មោះ [redacted] KUN បានជួលមកធ្វើការក្រោយពេលដែលខ្លួនបានប្រគល់អគារទាំងមូលឲ្យទៅគាត់។

ជនជាប់ចោទបានឆ្លើយសារភាពថា ខ្លួនពិតជាបានចុះកិច្ចព្រមព្រៀងទទួលមៅការសាងសង់សណ្ឋាគារមានកម្ពស់ ០៥ (ប្រាំ) ជាន់ និងបានចុះកិច្ចព្រមព្រៀងសាងសង់អគារកម្ពស់ ០២ (ពីរ) ជាន់ បន្ថែមទៀតពី ម្ចាស់គម្រោងឈ្មោះ [redacted] KUN ពិតប្រាកដមែន។ ប៉ុន្តែជនជាប់

ចោទបានព្យាយាមឆ្លើយបដិសេធថា ខ្លួនបានឈប់ទទួលខុសត្រូវក្នុងការសាងសង់អគារនោះ នៅពេលដែលអគារនោះ សាងសង់បានកម្ពស់ ០៦ (ប្រាំមួយ) ជាន់ និងបានប្រគល់អគារទាំងមូលឲ្យទៅឈ្មោះ [redacted] KUN គ្រប់គ្រង។ ប៉ុន្តែឈ្មោះ [redacted] KUN បានយកអគារនោះជួលបន្តឲ្យទៅឈ្មោះ [redacted]ហៃ ហើយឈ្មោះ [redacted]ហៃ បានធ្វើបន្ទប់នៅជាន់ទី ០១ (មួយ) បានធ្វើឲ្យប៉ះពាល់ដល់លក្ខណៈបច្ចេកទេសនៃអគារ ទើបបណ្តាលឲ្យអគារទាំងមូលត្រូវបាក់រលំជាចម្លើយដោះសារ ដើម្បីគេចវេះពីការទទួលខុសត្រូវព្រហ្មទណ្ឌដែលជាផលវិបាកនៃអំពើប្រព្រឹត្តរបស់ខ្លួនតែប៉ុណ្ណោះ។ ផ្អែកតាមកិច្ចសន្យាមៅការគម្រោងសាងសង់ ពុំមានចុះថ្ងៃខែឆ្នាំ, កិច្ចព្រមព្រៀងមៅការសាងសង់ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៩ និងកិច្ចសន្យាទទួលមៅការសាងសង់ កិច្ចព្រមព្រៀងបំពេញបន្ថែម ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៩ រវាងជនជាប់ចោទឈ្មោះ [redacted] KUN និងឈ្មោះ [redacted] XING GUI។

ជនជាប់ចោទបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងមៅការសាងសង់ និងកិច្ចព្រមព្រៀងមៅការសាងសង់អគារបន្ថែម ហើយជនជាប់ចោទបានដឹងយ៉ាងច្បាស់អំពីភាពដែលអាចទ្រទ្រង់បាននៃអគារទាំងមូល និងបានអះអាងថាអគារនោះអាចសាងសង់បានរហូតដល់ចំនួន ០៧ (ប្រាំពីរ) ជាន់ ដោយគ្មានបញ្ហា។ ជារួមការបាក់រលំនៃអគារទាំងមូលបណ្តាលមកពីជនជាប់ចោទដែលមានតួនាទីជាអ្នកមៅការសាងសង់ និងជាមេការសំណង់ បានប្រព្រឹត្តអំពើធ្វេសប្រហែសខ្វីខ្វា មិនប្រុងប្រយ័ត្ន និងបានបំពានកាតព្វកិច្ចសន្តិសុខដែលច្បាប់ និងបទដ្ឋានគតិយុត្តិក្រោមច្បាប់ដែលចេញដោយក្រសួងរៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីនៃព្រះរាជាណាចក្រកម្ពុជាតម្រូវ បណ្តាលឲ្យអគារបាក់រលំបង្កឲ្យមានកម្មករស្លាប់ និងរបួស ព្រមទាំងបង្កឲ្យមានការខូចខាតដល់ទ្រព្យសម្បត្តិរបស់អ្នកជិតខាងអស់ជាច្រើន អំពើនេះត្រូវបានកំណត់ថាជាបទល្មើសដែលមានចែង និងឲ្យផ្តន្ទាទោសតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

៤.ជនជាប់ចោទឈ្មោះ [redacted] YAPING បានឆ្លើយគ្រប់ដំណាក់កាលនីតិវិធីមានលក្ខណៈប្រហាក់ប្រហែលគ្នាថា: ខ្លួនមកដល់ប្រទេសកម្ពុជាក្នុងឆ្នាំ២០១៥ ក្នុងគោលបំណងទេសចរណ៍ លុះដល់អំឡុងខែឧសភា ឆ្នាំ២០១៩ ឈ្មោះ [redacted] KUN ត្រូវជាប្អូនជីដូនមួយខ្លួន បានហៅខ្លួនឲ្យមកប្រទេសកម្ពុជាដើម្បីជួយកិច្ចការផ្ទះ ដូចជា ដាំស្លៀ បោកខោអាវ។ នៅក្នុងអំឡុងពេលដែលឈ្មោះ [redacted] KUN បានសាងសង់សំណង់អគារ ខ្លួនទៅការដ្ឋានសំណង់នោះបានប្រហែល ១០ដង ភាគច្រើនខ្លួនទៅកន្លែងការដ្ឋានសំណង់ដើម្បីហៅប្អូនប្រុសមកហូបបាយ ដោយសារតែខ្លួនទូរស័ព្ទហៅប្អូនប្រុសមិនលើក។ ពេលខ្លួនទៅរកប្អូនក៏បានឃើញការភ្ជាប់ដំណរដែកធ្មឹមជាមួយនឹងសរសរដែកមានលក្ខណៈចំហរមិនមានខ្ចៅ (ប្រឡុង) ហើយកន្លែងផ្សេងទៀតមានចាប់ខ្ចៅខុសគ្នា ទើបខ្លួនថតរូបទាំងនោះផ្ញើទៅកាន់ប្រព័ន្ធវីឆាតដែលមានប្អូនខ្លួន និងមេការសំណង់ដើម្បីឲ្យប្អូនប្រុសខ្លួន និងមេការឈ្មោះ [redacted] XING GUI បានដឹង ដើម្បីឲ្យប្អូន និងមេការពិនិត្យមើលកន្លែងទាំងនោះឡើងវិញ។ បន្ទាប់មកមានជាងជនជាតិខ្មែរបានមកជូសជុលកែលម្អឲ្យល្អឡើងវិញ។ លុះដល់ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ វេលាម៉ោង ១១ ថ្ងៃត្រង់ ខ្លួនបានឆ្លងកាត់ការដ្ឋានសំណង់ ខ្លួនបានចូលទៅមើលថាមានខ្សាច់ ឬស៊ីម៉ង់ត៍ក្នុងការដ្ឋាន តាមការ ភ្ជាំផ្ញើរូបស្រស់អ្នកខ្លួន បន្ទាប់មកខ្លួនបានហូសទៅមន្ទីរពេទ្យដើម្បីព្យាបាលជំងឺ។ ខ្លួនទៅការដ្ឋានសំណង់ក្នុងនាមខ្លួនជាបងស្រីជីដូនមួយរបស់ឈ្មោះ [redacted] KUN តែប៉ុណ្ណោះ ខ្លួនពុំមែនជាអ្នកបច្ចេកទេស

សំណង់ទេ ហើយពុំទទួលបានប្រាក់ចំណេញអ្វីនៅក្នុងគម្រោងអគារនោះដែរ។ ស្រាប់តែនៅថ្ងៃទី ២២ ខែមិថុនា ឆ្នាំ២០១៩ អគារបានដួលរលំតែម្តង។

ចំពោះចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] YAPING ថា ខ្លួនបានដឹងដំណើរដែកធ្មឹមជាមួយសសរមានលក្ខណៈចំហរ មិនមានខ្ចៅ (ប្រឡុង) ហើយកន្លែងផ្សេងទៀតមានខ្ចៅខុសគ្នា ហើយអគារដែលបានបាក់រលំបានបង្ហាញពីកំហុសអចេតនានៃការចូលរួមក្នុងសកម្មភាពល្មើសព័បទ មនុស្សឃាតដោយអចេតនា និងបទ បង្ករបួសដោយអចេតនា ដែលមានចែង និងឲ្យផ្តន្ទាទោសតាមមត្រា ២០៧ និងមាត្រា២៣៦ នៃក្រមព្រហ្មទណ្ឌ។ ផ្ទុយទៅវិញ អំពើល្មើសរបស់ជនជាប់ចោទគ្មានសញ្ញាណណាមួយ បង្ហាញឲ្យឃើញពីចេតនាទុច្ចរិតក្នុងការចូលរួមបង្កឲ្យមានការខូចខាតមានស្ថានទម្ងន់ទោសដោយបង្កឲ្យអ្នកដទៃរបួសនោះទេ។ គប្បីឲ្យជនជាប់ចោទឈ្មោះ [redacted] YAPING រួចខ្លួនព័បទចោទ សមគំនិតក្នុងអំពើធ្វើឲ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោសដោយសារការបង្ករបួសដល់អ្នកដទៃ តាមមាត្រា៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

៥.ជនជាប់ចោទឈ្មោះ [redacted] YU បានឆ្លើយគ្រប់ដំណាក់កាលនីតិវិធីមានលក្ខណៈប្រហាក់ប្រហែលគ្នាថា: ខ្លួនមកដល់ប្រទេសកម្ពុជាក្នុងឆ្នាំ២០១៩ ដើម្បីរកការងារធ្វើ។ ក្រោយមកខ្លួនបានធ្វើការងារជាកម្មករសំណង់នៅការដ្ឋានសំណង់ក្បែរវិមានឯករាជ្យ ធ្វើការងារនៅទីនោះបានរយៈពេល ០៣ ខែ ឈ្មោះ [redacted] KUN បានទាក់ទងមកខ្លួនដើម្បីឲ្យជួយធ្វើការងារនៅអគារកម្ពស់០៧ ជាន់ ជាជាងលាបថ្នាំ រចនាពណ៌នៅលើជញ្ជាំងអគារផ្នែកខាងក្រៅ ចំពោះការងារនៅខាងក្នុងអគារមានកម្មកររួចហើយ ប៉ុន្តែមិនទាន់បានចាប់ផ្តើមធ្វើការងារទេ ដោយឈ្មោះ [redacted] KUN បានឲ្យខ្លួនសម្រាករយៈពេល០៥ ថ្ងៃ សិន ចាំ មកធ្វើការងារ ក្រោយពីខ្លួនសម្រាកដល់ថ្ងៃទី០៥ អគារនោះបានដួលរលំតែម្តង។ ខ្លួនពុំដែលស្គាល់ឈ្មោះ [redacted] XING GUI ឈ្មោះ [redacted] YAPING, ឈ្មោះ [redacted] THI THUY HAO, ឈ្មោ [redacted] JUN HUA ទេ។

ចំពោះចម្លើយដោះបន្ទុករបស់ជនជាប់ចោទឈ្មោះ [redacted] YU គ្មានភស្តុតាងណាមួយមកបញ្ជាក់ដែលអាចឲ្យតុលាការជឿបានឡើយ ដោយហេតុថា តាមរបាយការណ៍លេខ ១៤៤ រ.ប.ក /១៩ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៩ របស់ការិយាល័យព្រហ្មទណ្ឌកម្រិតធ្ងន់នៃស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ ឃើញថា ជនជាប់ចោទឈ្មោះ [redacted] YU ជាសហចារីនៃអំពើដែលបង្កឲ្យមានការបាក់រលំអគារកំពស់ ០៧ ជាន់ កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៩ ផងដែរ។ ផ្ទុយទៅវិញ កំហុសរបស់ជនជាប់ចោទឈ្មោះ [redacted] YU កើតចេញពីការធ្វេសប្រហែស ខ្ជីខ្ជា ទើបជាការរួមចំណែកបង្កឲ្យមានវិនាសកម្មដ៏សែនធ្ងន់ធ្ងរ បង្កឲ្យប៉ះពាល់ដល់ជនរងគ្រោះជាច្រើននាក់បានរងរបួស និងស្លាប់ទៀតផង។ ហេតុនេះជនចាប់ចោទឈ្មោះ [redacted] YU ជាសហចារីនៃអំពើមនុស្សឃាតដោយអចេតនា និងអំពើ បង្កឲ្យមានរបួសស្នាមដោយអចេតនា ដែរ។ ផ្ទុយទៅវិញ កំហុសរបស់ជនជាប់ចោទឈ្មោះ [redacted] YU គ្មានធាតុផ្សំបទល្មើស សមគំនិតក្នុងអំពើធ្វើឲ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោសដោយសារការបង្ករបួសដល់អ្នកដទៃ ឡើយ គប្បីតុលាការឲ្យជនជាប់ចោទឈ្មោះ [redacted] YU រួចខ្លួនពីបទចោទ ព័បទ សមគំនិតក្នុងអំពើធ្វើឲ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោសដោយសារការបង្ករបួសដល់អ្នកដទៃ តាមមាត្រា៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៦.លោក [redacted] នីម ជាចៅសង្កាត់លេខ៤ បានបញ្ជាក់ថា: ការស្នើសុំច្បាប់សាងសង់ត្រូវស្នើសុំពីសាលាសង្កាត់លេខ៤ ទៅមុន ទើបបញ្ជូនទៅការិយាល័យភូមិបាលក្រុងព្រះសីហនុ រួចទើប បញ្ជូនបន្តទៅសាលាក្រុងព្រះសីហនុ បន្ទាប់មកត្រូវបញ្ជូនឯកសារបន្តទៅមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តព្រះសីហនុ ទើបមន្ទីរបញ្ជូនបន្តទៅសាលាខេត្តព្រះសីហនុ ដើម្បីសុំគោលការណ៍។ បន្ទាប់ពីនេះ ខ្លួនពុំដឹងលំអិតអំពីនីតិវិធីបន្ទាប់ទៀតយ៉ាងណានោះទេ។ ចំពោះការសាងសង់សំណង់អគារដែលបានបាក់រលំនេះ ពុំមាននរណាម្នាក់ស្នើសុំច្បាប់សម្រាប់សាងសង់នោះទេ ដោយខ្លួនបានត្រួតពិនិត្យមើលសៀវភៅលេខចេញ និងចូលរបស់សាលាសង្កាត់ពុំឃើញមានការស្នើសុំនោះទេ។ ខ្លួនធ្លាប់ឃើញលោក [redacted] សីហា ប្រធានការិយាល័យលទ្ធកម្មក្រុងព្រះសីហនុ ចុះទៅពិនិត្យមើលរាល់ការដ្ឋានសំណង់ក្នុងសង្កាត់លេខ៤ ប៉ុន្តែខ្លួនពុំដឹងថាត្រួតពិនិត្យលើអ្វីនោះទេ ការចុះទៅពិនិត្យរបស់គាត់ជាការចាត់តាំងរបស់សាលាក្រុងព្រះសីហនុ។

៧.លោក [redacted] សីហា ជាប្រធានការិយាល័យសាលាក្រុងទទួលបន្ទុកការងារលទ្ធកម្ម បានបញ្ជាក់ថា: ចំពោះអគារដែលបាក់រលំ ខ្លួនពុំដឹងរឿងស្នើសុំច្បាប់សាងសង់នោះទេ។ តាមកំណត់ហេតុចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៩ ដែលមានខ្លួនចុះពិនិត្យនោះ ដំបូងមានការប្តឹងពីការប៉ះពាល់ដល់សំណង់អ្នកជិតខាង ដោយមានលោក [redacted] ចិត្តនិយម ជាអនុប្រធានអនុគណៈកម្មការចុះត្រួតពិនិត្យសំណង់ខេត្ត បានបង្កើតក្រុមការងារដោយមានខ្លួន ជាសមាជិក ដោយពេលចុះទៅនោះ ពិនិត្យមើលលើផលប៉ះពាល់ និងទិដ្ឋភាពច្បាប់ជារួម។ នៅក្នុងកំណត់ហេតុក៏មានការបញ្ឈប់កុំឲ្យសាងសង់ជាបណ្តោះអាសន្ន ហើយទិដ្ឋភាពនៅពេលនោះ អគារបានឈប់ការសាងសង់ជាបណ្តោះអាសន្នមែន ប៉ុន្តែស្រាប់តែមួយរយៈក្រោយមក ទើបមានការសាងសង់ឡើងដែកបន្ថែម ដោយពេលនោះខ្លួនក៏បានរាយការណ៍ទៅថ្នាក់ខេត្តដែរ ហើយ ក្រុមការងារបានចុះពិនិត្យតែមិនមានសកម្មភាពសាងសង់ទេ និងគ្មានកម្មករនៅទីតាំងនោះដែរ។

៨.លោក [redacted] ថៃស័រ ជាប្រធានការិយាល័យរៀបចំដែន ដីនគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តព្រះសីហនុ បានបញ្ជាក់ថា: អគារដែលបានបាក់រលំពុំមានឯកសារច្បាប់សាងសង់ដាក់ចូលមកការិយាល័យរបស់ខ្លួនឡើយ។ ចំពោះអគារដែលបានបាក់រលំមានកម្ពស់ ០៧ ជាន់ ខ្លួនមិនទាន់អាចកំណត់ដឹងថាជាសមត្ថកិច្ចរបស់ខេត្ត ឬក្រសួងឡើយ ទាល់តែសិក្សាជាមុនដោយមានការស្នើសុំពីម្ចាស់អគារ មានភ្ជាប់ជាមួយ នូវប្លង់ស្តាបត្យកម្ម ជាដើម។

៩.លោក [redacted] សុវន្ត ជាប្រធានការិយាល័យសំណង់នៃមន្ទីរៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តព្រះសីហនុ បានបញ្ជាក់ថា: ទាក់ទងនឹងការសាងសង់អគារដែលមានទំហំ ១៧.១ គុណនឹង ២៥.២ មានកម្ពស់០៧ ជាន់ ស្មើងនឹង ២.៤៤៧,៣៦ ម៉ែត្រការ៉េ ដែលបានដួលរលំនេះ ពុំមានលិខិតអនុញ្ញាតសាងសង់នោះទេ។ សមត្ថកិច្ចក្នុងការចេញលិខិតអនុញ្ញាតសាងសង់អគារដែលបានបាក់រលំនោះ ជាសមត្ថកិច្ចរបស់រដ្ឋបាលខេត្តព្រះសីហនុ កន្លងមករដ្ឋបាលខេត្តបានបង្កើតគណៈកម្មការចុះទៅដល់អគារដែលបាក់រលំចំនួន០២ ដង លើកទី១ ចុះទៅធ្វើសណ្តាប់ធ្នាប់ និងលើកទី២ បានចុះទៅធ្វើកិច្ចសន្យាផ្អាកការសាងសង់ជាបណ្តោះអាសន្ន ចំពោះការបង្កើតគណៈកម្មការរបស់រដ្ឋបាលខេត្តព្រះសីហនុ ដឹកនាំដោយលោក [redacted] ចិត្តនិយម មានតួនាទី ជាប្រធានការិយាល័យគ្រប់គ្រងអភិវឌ្ឍសំណង់នៃទីចាត់ការអន្តរ-វិស័យខេត្តព្រះសីហនុ និងមានលោក [redacted] ញឹមឈៀង និងលោក [redacted] សុភាព មន្ត្រីការិយាល័យ

រៀបចំដែនដីនីរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តព្រះសីហនុចូលរួម ប៉ុន្តែខ្លួនពុំបានចូលរួមនោះទេ។ តាមរយៈកំណត់ ហេតុលើកទី២ ឃើញថាគណៈកម្មការបានសម្រេចបញ្ឈប់មិនធ្វើការសាងសង់ជាបណ្តោះអាសន្ន ប៉ុន្តែនៅតែមានការសាងសង់បន្តទៀត រហូតដល់អគារបាក់រលំនៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៩។ តាមលទ្ធផលគណនាបង្ហាញថា ទំហំមុខកាត់ធាតុនៃគ្រឿងបង្គុំ (ធ្នឹម ធ្នឹមរង សសរ) ជាក់ស្តែងមិនគ្រប់គ្រាន់ បើធៀបជាមួយការគណនាធាតុផ្សំគ្រង់ដំណើរវាងបង្គុំធ្នឹម និងសសរមិនមានលទ្ធភាពទ្រទ្រង់គ្រប់គ្រាន់ និងមានកំហុសបច្ចេកទេសនៃការសាងសង់ដូចជា ប៊ូឡុងខុសទីតាំង និងខុសស្តង់ដា។ល។ ហេតុផលនេះ បញ្ជាក់ថាគ្រឿងបង្គុំនឹងបាក់រលំនៅពេលណាមួយ បើទោះបីមិនកើតឡើងនៅពេលនេះក្តី ហើយការបាក់រលំអគារជាក់ស្តែងនៅថ្ងៃកើតហេតុបណ្តាលមកពីបាក់ធ្នឹមរងខាងស្តាំអគារនៃជាន់ទី៥ ដោយការដាក់បន្ទុកសាងសង់លើស, **សំរុតគ្រឹះចំហៀងខាងឆ្វេងអគាលៀនជាតំបន់កណ្តាលអគារដោយភ្លៀងចាប់ផ្តើម និងឧបទ្វេវហេតុផ្សេងដែលមិនអាចកំណត់បានដូចជាការមានជម្លោះកម្មករជាដើម។**

១០.លោក [redacted] ចិត្តនិយម ប្រធានការិយាល័យគ្រប់ គ្រងអភិវឌ្ឍសំណង់នៃរដ្ឋបាលខេត្តព្រះសីហនុ បញ្ជាក់ថា: **ចំពោះអគារដែលបាក់រលំនោះ** ខ្លួនបាន**ចុះទៅពិនិត្យចំនួន០២** ដង **លើកទី១** ខ្លួន**ចុះទៅដើម្បីធ្វើ**សណ្តាប់ធ្នាប់ ដោយរដ្ឋបាលក្រុងជាអ្នកអញ្ជើញចូលរួម **លើកទី១** នេះមិនមានធ្វើកំណត់ហេតុទេ ម្ល**ហេតុដែលចុះទៅនោះដើម្បីពិនិត្យមើលច្បាប់**សាងសង់ និង**សណ្តាប់ធ្នាប់**នៅក្នុងការដ្ឋាន ប៉ុន្តែពេលចុះទៅដល់ពុំបានជួបម្ចាស់**សំណង់**ទេ ជួបតែកម្មករ**សំណង់**តែប៉ុណ្ណោះ។ **លើកទី២** ស្របពេលដែលមានបណ្តឹងផ្ញាល់មាត់មករដ្ឋបាលក្រុងថា មានធ្លាក់ដែក ហើយ**ធ្វើសំណង់**ក្បែរដោយពុំបានទុកគំលាតឲ្យបានត្រឹមត្រូវ ទើបរដ្ឋបាលក្រុងបាន**អញ្ជើញ**ខ្លួន**ឲ្យចូលរួម**។ ក្រុមការងារដែលមានការចូលរួមពីរដ្ឋបាលក្រុងបានធ្វើកំណត់ហេតុហាមឃាត់កុំឲ្យមានការសាងសង់បន្ត ហើយខណៈនោះ អគារសាងសង់បានកម្ពស់ ០៤ ជាន់ហើយ និងគ្មានកម្មករនៅសាងសង់នៅឡើយទេ។ ចាប់ពីពេលនោះមក ក្រុមការងារមិនបានចុះទៅពិនិត្យទៀតដែរ ព្រោះមានភារកិច្ចទាក់ទងនឹងសំណង់ មានការសាងសង់ច្រើន។ ម្យ៉ាងទៀតសមត្ថភាពមន្ត្រីអនុវត្តច្បាប់នៅមានកម្រិតនៅឡើយ មានចំនួនមន្ត្រីតិច។ ក្រុមការងារដែលចុះទៅនោះ មិនមានសមត្ថកិច្ចត្រួតពិនិត្យលើគុណភាពសំណង់នោះទេ មានសិទ្ធិត្រឹមតែត្រួតពិនិត្យមើលសណ្តាប់ធ្នាប់តែប៉ុណ្ណោះ។ នៅពេលដែលខ្លួន និងក្រុមការងារចុះទៅត្រួតពិនិត្យមើលសណ្តាប់ធ្នាប់នោះ ខ្លួនបានសុំការអនុញ្ញាតពីអភិបាលខេត្ត ហើយពេលដែលចុះទៅត្រួតពិនិត្យមើលសណ្តាប់ធ្នាប់សំណង់នោះ ខ្លួនបានរាយការណ៍ពីលទ្ធផលទៅលោកអភិបាលខេត្តដោយផ្ទាល់។

១១.លោក [redacted] ធារិន ជានាយកទីចាត់ការអន្តរវិស័យនៃរដ្ឋបាលខេត្តព្រះសីហនុ បញ្ជាក់ថា: ទាក់ទងនឹងច្បាប់សាងសង់ចំណុះរដ្ឋបាលខេត្តព្រះសីហនុ គឺសំណង់ណាដែលមានទំហំពី ៥០០ ម៉ែត្រការ៉េ ដល់ក្រោម ៣.០០០ ម៉ែត្រការ៉េ ហើយអ្នកស្នើសុំត្រូវដាក់ពាក្យស្នើសុំទៅសាលាសង្កាត់សាមីជាមុន រួចបញ្ជូនមកការិយាល័យភូមិបាលក្រុង ហើយទើបបញ្ជូនបន្តមកមន្ទីរវៀបចំដែនដីនរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តព្រះសីហនុ រួចទើបបញ្ជូនបែបបទស្នើសុំច្បាប់សាងសង់នោះមករដ្ឋបាលខេត្តព្រះសីហនុ ចុងក្រោយទើបបញ្ជូនបន្តចូលទៅអភិបាលខេត្តដើម្បីពិនិត្យ និងសម្រេច។ អគារបាក់រលំនេះ ស្ថិតក្នុងសមត្ថកិច្ចរបស់រដ្ឋបាលខេត្តក្នុងការចេញច្បាប់អនុញ្ញាតិសាងសង់ ចំពោះច្បាប់អនុញ្ញាតសាងសង់ខ្លួនពុំបានដឹងទេ។ នៅក្រោយ

ពេលដែលអគារបាក់រលំរួច រដ្ឋបាលខេត្តបានបង្កើតគណៈកម្មការចុះស្រាវជ្រាវ ដោយមានរបាយការណ៍របស់កងរាជអាវុធហត្ថខេត្តព្រះសីហនុ បានសន្និដ្ឋានថា អគារបាក់រលំដោយសារតែមានការកាត់តផ្សារដែកជាច្រើនកន្លែង គ្មានជំនាញត្រួតពិនិត្យច្បាស់លាស់ ការរៀបឥដ្ឋពីជាន់លើចុះមកជាន់ក្រោមដោយឥដ្ឋខ្មែរ មានទម្ងន់ធ្ងន់ជាឥដ្ឋចិន ការជញ្ជូនសម្ភារៈសំណង់ធ្ងន់ៗផ្សេងៗទៅដាក់នៅជាន់លើច្រើន ធ្វើឲ្យអគារធ្ងន់លើសកម្រិតជើងក្រោមអគារមិនអាចទ្រទ្រង់បាន ជាហេតុធ្វើឲ្យផ្នែកខាងក្រោមអគារទន់គាច់ដួលរលំបាក់តែម្តង។ នៅពេលដែលលោក [redacted] ចិត្តនិយម ចុះទៅផ្ទាកការសាងសង់អគារ ពុំមានរាយការណ៍ឲ្យខ្លួនទេ ក្រោយពេលដែលអគារបានរលំបាក់រួច ទើបលោក លី ចិត្តនិយម បានយករបាយការណ៍ឲ្យខ្លួនពិនិត្យមើល។

១២.លោក [redacted] សុវិន បានឆ្លើយបញ្ជាក់ថា: ខ្លួនមានមុខរបរជាកម្មរសំណង់ មានទីលំនៅបច្ចុប្បន្ននៅ ម៉ុំទូលសង្កែ។ ធ្លាប់ធ្វើការងារសំណង់នៅអគារនោះ មុនពេលអគាររលំមួយថ្ងៃខ្លួនបានទៅធ្វើការបានឃើញអគារខាងក្រោមអត់រៀបឥដ្ឋ, គ្មានឃើញអ្វីប្លែកទេ ឈ្មោះ [redacted] XING GUI បានជួលខ្លួនធ្វើការងារ ដោយឲ្យថ្លៃឈ្នួល ១ ថ្ងៃ តម្លៃ ១២ ដុល្លារ អាមេរិក ប្រសិនអគារអត់រលំ ខ្លួនទៅធ្វើការងាររាល់ថ្ងៃ ជាកម្មករសំអាតកំបោរមិនបានស្នាក់នៅក្នុងអគារទេ។ ខ្លួនធ្វើការងារនៅទីនោះបានចំនួន២ ខែមកហើយ មានគ្នាចំនួន ៣ នាក់ ចំណែក២នាក់ទៀត ទៅស្រុកអស់ហើយ។ បានជាខ្លួនមកធ្វើជាសាក្សី ពីព្រោះខ្លួនអាណិតឈ្មោះ [redacted] GUI។ ពេលខ្លួនទៅធ្វើការ ខ្លួនបានឃើញមានធុងហ្គាសដែលជារបស់ក្រុមហ៊ុន នៅជាន់ទី ១ ហើយមានកម្មករសុទ្ធតែជនជាតិចិន។ ខ្លួនស្គាល់ឈ្មោះ [redacted] KUN និងឈ្មោះ [redacted] YAPING ច្រើនជាងគេ។

១៣.ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] រិទ្ធិវុឌ្ឍ បានឆ្លើយបញ្ជាក់ថា: កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៩ វេលាម៉ោង ០៥ និង ០០ នាទី ទៀបភ្លឺ មានព្រឹត្តិការណ៍បាក់រលំអគារកំពុងសាងសង់ដែលមានកម្ពស់០៧ ជាន់ ស្ថិតនៅ ភូមិ៣ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ បណ្តាលឲ្យផ្ទះរបស់ខ្លួនជួលឲ្យជនជាតិជប៉ុនធ្វើអាជីវកម្មបើកភោជនីយដ្ឋានលក់ម្ហូបជប៉ុន ដែលស្ថិតនៅជាប់ខាងត្បូងនៃអគាររងការខូចខាតទាំងស្រុង។ ក្នុងរឿងនេះ ខ្លួនទាមទារថ្លៃខូចខាតសម្ភារៈ និងផ្ទះសរុបចំនួន ៧៣.១៤០ (ប្រាំពីរម៉ឺនបីពាន់មួយរយសែសិប) ដុល្លារអាមេរិក, ទាមទារការខាតបង់លើថ្លៃឈ្នួលផ្ទះដែលត្រូវទទួលបានរហូតដល់ពេលសាងសង់រួចរាល់ សរុបចំនួន ១៤៤.០០០ (ដប់បួនម៉ឺនបួនពាន់) ដុល្លារអាមេរិក និងទាមទារសំណងជំងឺចិត្តចំនួន ៣.០០០ (បីពាន់) ដុល្លារអាមេរិក តុលាការគប្បីពិចារណា។

១៤.ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] TOMOTAKA និងឈ្មោះ [redacted] YUKO បានឆ្លើយបញ្ជាក់ថា: កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៩ វេលាម៉ោង ០៥ និង ០០ នាទី ទៀបភ្លឺ មានព្រឹត្តិការណ៍បាក់រលំអគារកំពុង សាងសង់ដែលមានកម្ពស់០៧ ជាន់ ស្ថិតនៅ ភូមិ៣ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ បណ្តាលឲ្យផ្ទះដែលខ្លួនបានជួលបើកអាជីវកម្មលក់ម្ហូបអាហារជប៉ុន នៅជាប់ខាងត្បូងអគារនោះរងការខូចខាតទាំងស្រុង។ ក្នុងរឿងនេះ ខ្លួនទាមទារថ្លៃខូចខាតសម្ភារៈសរុបចំនួន ៩៩ ៧១៥ (ប្រាំបួនម៉ឺនប្រាំបួនពាន់ប្រាំពីររយដប់ប្រាំ) ដុល្លារអាមេរិក, ទាមទារការខាតបង់លើប្រាក់ចំណូលអាជីវកម្មរហូតដល់ពេលភោជនីយដ្ឋានសាងសង់រួចរាល់ចំនួន ១២០.០០០ (ដប់ពីរម៉ឺន) ដុល្លារអាមេរិក និងទាមទារសំណងជំងឺចិត្តចំនួន ៨៥.០០០ (ប្រាំបីម៉ឺនប្រាំពាន់) ដុល្លារអាមេរិក តុលាការគប្បីពិចារណា។

Scanned with CamScanner

១៥.ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]វ៉ាន់ដា បានបញ្ជាក់ថា នៅក្នុងហេតុការណ៍បាក់រលំអគារនេះ ខ្លួនទទួលរងផលប៉ះពាល់រោងជាង និងរថយន្តចំនួន០៥ គ្រឿង ម៉ាក LEXUS 470 មួយ គ្រឿង ខ្លួនទាមទារសំណង ៣០.០០០ (បីម៉ឺន) ដុល្លារអាមេរិក, ម៉ាក STAREX (ខូចខាតទាំង ស្រុង) ខ្លួនទាមទារសំណង ២២.៥០០ (ពីរម៉ឺនពីរពាន់ប្រាំរយ), ម៉ាក MERCEDES S320 សេរីឆ្នាំ ១៩៩៨ ខ្លួនទាមទារ ៦.០០០ (ប្រាំមួយពាន់) ដុល្លារអាមេរិក, ម៉ាក HYUNDAI 1.5 TON ខ្លួនទាម ទារសំណង ២.៥០០ (ពីរពាន់ប្រាំរយ) ដុល្លារអាមេរិក និងម៉ាក RANGROVER សេរីឆ្នាំ២០០៥ (ខូចខាត ៤០%) ខ្លួនទាមទារសំណង ៣៥.០០០ (បីម៉ឺនប្រាំពាន់) ដុល្លារអាមេរិក, ទាមទារថ្លៃ ខូចខាតរោងជាងចំនួន ៤២.០០០ (បួនម៉ឺនពីរពាន់) ដុល្លារអាមេរិក និងទាមទារសំណងជំងឺចិត្តចំនួន ៣០.០០០ (បីម៉ឺន) ដុល្លារអាមេរិក តុលាការគប្បីពិចារណា។

១៦-**ជនរងគ្រោះដែលរងរបួស** និងបានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ ដើម្បីប្តឹងទាមទារសំណងរដ្ឋប្បវេណីពីឈ្មោះ [redacted] KUN, ឈ្មោះ [redacted] GUI, ឈ្មោះ [redacted] YAPING, ឈ្មោះ [redacted] YU, ឈ្មោះ [redacted] THI THUY HAO ហៅ អាហ័រ និងឈ្មោះ [redacted] ប៊ុនធឿន មានដូចខាងក្រោម:

១៦.១.ឈ្មោះ [redacted] ល័ក្ខ ប្តឹងទាមទារសំណងរដ្ឋប្បវេណី សរុបចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិក តុលាការគប្បីពិចារណា។

១៦.២.ឈ្មោះ [redacted] រ៉ន ហៅ ចន ពៅ ប្តឹងទាមទារសំណងរដ្ឋប្បវេណី សរុបចំនួន ៤០.០០០.០០០ (សែសិបលាន) រៀល តុលាការគប្បីពិចារណា។

១៦.៣.ឈ្មោះ [redacted] ប្រុស ប្តឹងទាមទារសំណងរដ្ឋប្បវេណី សរុបចំនួន ៤០.០០០.០០០ (សែសិបលាន) រៀល តុលាការគប្បីពិចារណា។

១៦.៤.ឈ្មោះ [redacted] សុន ប្តឹងទាមទារសំណងរដ្ឋប្បវេណី សរុបចំនួន ៨០.០០០.០០០ (ប៉ែតសិបលាន) រៀល តុលាការគប្បីពិចារណា។

១៦.៥.ឈ្មោះ [redacted] អៀន ប្តឹងទាមទារសំណងរដ្ឋប្បវេណី សរុបចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិក តុលាការគប្បីពិចារណា។

១៦.៦.ឈ្មោះ [redacted] ចាន់ណេត ប្តឹងទាមទារសំណងរដ្ឋប្បវេណី សរុបចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិក តុលាការគប្បីពិចារណា។

១៦.៧.ឈ្មោះ [redacted] សុភាព ប្តឹងទាមទារសំណងរដ្ឋប្បវេណី សរុបចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិក តុលាការគប្បីពិចារណា។

១៦.៨.ឈ្មោះ [redacted] សុផស់ ប្តឹងទាមទារសំណងរដ្ឋប្បវេណី សរុបចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិក តុលាការគប្បីពិចារណា។

១៦.៩.ឈ្មោះ [redacted] ដា ប្តឹងទាមទារសំណងរដ្ឋប្បវេណី សរុបចំនួន ៤០.០០០ (បួនម៉ឺន) ដុល្លារអាមេរិក តុលាការគប្បីពិចារណា។

១៦.១០.ឈ្មោះ [redacted] រស់ ប្តឹងទាមទារសំណងរដ្ឋប្បវេណី សរុបចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិក តុលាការគប្បីពិចារណា។

១៦.១១.ឈ្មោះ [redacted] សុីថា ប្តឹងទាមទារសំណងរដ្ឋប្បវេណី សរុបចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិក តុលាការគប្បីពិចារណា។

១៦.១២.ឈ្មោះ [redacted] សុខន ប្តឹងទាមទារសំណងរដ្ឋប្បវេណី សរុបចំនួន ៨0.000.000 (ប៉ែតសិបលាន) រៀល តុលាការគប្បីពិចារណា។

១៦.១៣.ឈ្មោះ [redacted] នាង ប្តឹងទាមទារសំណងរដ្ឋប្បវេណី សរុបចំនួន ៨0.000.000 (ប៉ែតសិបលាន) រៀល តុលាការគប្បីពិចារណា។

១៦.១៤.ឈ្មោះ [redacted]ចំរើន ប្តឹងទាមទារសំណងរដ្ឋប្បវេណី សរុបចំនួន ៨0.000.000 (ប៉ែតសិបលាន) រៀល តុលាការគប្បីពិចារណា។

១៦.១៥.ឈ្មោះ [redacted]ប៊ុនធឿន ប្តឹងទាមទារសំណងរដ្ឋប្បវេណី សរុបចំនួន ៨0.000.000 (ប៉ែតសិបលាន) រៀល តុលាការគប្បីពិចារណា។

១៦.១៦.ឈ្មោះ [redacted] សែន ប្តឹងទាមទារសំណងរដ្ឋប្បវេណី សរុបចំនួន ៨0.000.000 (ប៉ែតសិបលាន) រៀល តុលាការគប្បីពិចារណា។

១៦.១៧.ឈ្មោះ [redacted] សុខៀន ប្តឹងទាមទារសំណងរដ្ឋប្បវេណី សរុបចំនួន ៦៥.000 (ប្រាំមួយម៉ឺនប្រាំពាន់) ដុល្លារអាមេរិក តុលាការគប្បីពិចារណា។

១៦.១៨.ឈ្មោះ [redacted]ៅ ប្តឹងទាមទារសំណងរដ្ឋប្បវេណី សរុបចំនួន ២0.000 (ពីរម៉ឺន) ដុល្លារអាមេរិក តុលាការគប្បីពិចារណា។

១៦.១៩.ឈ្មោះ [redacted] ឃាង ប្តឹងទាមទារសំណងរដ្ឋប្បវេណី សរុបចំនួន ២0.000 (ពីរម៉ឺន) ដុល្លារអាមេរិក តុលាការគប្បីពិចារណា។

១៦.២0.ឈ្មោះ [redacted] វុធ ប្តឹងទាមទារសំណងរដ្ឋប្បវេណី សរុបចំនួន ២0.000 (ពីរម៉ឺន) ដុល្លារអាមេរិក តុលាការគប្បីពិចារណា។

១៦.២១.ឈ្មោះ [redacted] ផេត ប្តឹងទាមទារសំណងរដ្ឋប្បវេណី សរុបចំនួន ៨0.000.000 (ប៉ែតសិបលាន) រៀល តុលាការគប្បីពិចារណា។

១៦.២២.ឈ្មោះ [redacted] ប្រុស ប្តឹងទាមទារសំណងរដ្ឋប្បវេណី សរុបចំនួន ៨0.000.000 (ប៉ែតសិបលាន) រៀល តុលាការគប្បីពិចារណា។

១៦.២៣.ឈ្មោះ [redacted] សំអុល ប្តឹងទាមទារសំណងរដ្ឋប្បវេណី សរុបចំនួន ៨0.000.000 (ប៉ែតសិបលាន) រៀល តុលាការគប្បីពិចារណា។

១៦.២៤.ឈ្មោះ [redacted] សាវ៉ាត ប្តឹងទាមទារសំណងរដ្ឋប្បវេណី សរុបចំនួន ៨0.000.000 (ប៉ែតសិបលាន) រៀល តុលាការគប្បីពិចារណា។

១៦.២៥.ឈ្មោះ [redacted] ធីម ប្តឹងទាមទារសំណងរដ្ឋប្បវេណី សរុបចំនួន ៨0.000.000 (ប៉ែតសិបលាន) រៀល តុលាការគប្បីពិចារណា។

១៦.២៦.ឈ្មោះ [redacted]ចិនឡាង ត្រូវជាបងប្រុសរបស់ជនរងគ្រោះឈ្មោះ [redacted] អ្នឈាង (រងរបួសធ្ងន់) ប្តឹងទាមទារសំណងរដ្ឋប្បវេណី សរុបចំនួន ១៣0.000 (ដប់បីម៉ឺន) ដុល្លារអាមេរិក តុលាការគប្បីពិចារណា។

១៧-**សិទ្ធិវន្តរបស់ជនរងគ្រោះដែលបានទទួលមរណភាព** និងបានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ ដើម្បីប្តឹងទាមទារសំណងរដ្ឋប្បវេណីពីឈ្មោះ [redacted] KUN, ឈ្មោះ [redacted] XING GUI, ឈ្មោះ [redacted] YAPING, ឈ្មោះ [redacted] YU, ឈ្មោះ [redacted] THI THUY HAO ហៅ អាហ័រ និងឈ្មោះ [redacted] ប៊ុនធឿន មានដូចខាងក្រោម:

Scanned with CamScanner

១៧.១.ឈ្មោះ [redacted] ជិត ប្តឹងទាមទារសំណងរដ្ឋប្បវេណី សរុបចំនួន ៦០.០០០.០០០ (ហុកសិប លាន) រៀល តុលាការគប្បីពិចារណា។

១៧.២.ឈ្មោះ [redacted] កា ប្តឹងទាមទារសំណងរដ្ឋប្បវេណី សរុបចំនួន ៦០.០០០.០០០ (ហុកសិប លាន) រៀល តុលាការគប្បីពិចារណា។

១៧.៣.ឈ្មោះ [redacted] យ៉ុន ប្តឹងទាមទារសំណងរដ្ឋប្បវេណី សរុបចំនួន ៦០.០០០.០០០ (ហុកសិបលាន) រៀល តុលាការគប្បីពិចារណា។

១៧.៤.ឈ្មោះ [redacted] សាខន ប្តឹងទាមទារសំណងរដ្ឋប្បវេណី សរុបចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិក តុលាការគប្បីពិចារណា។

១៧.៥.ឈ្មោះ [redacted] ថាន ត្រូវជាឪពុក និងឈ្មោះ [redacted] សុថាត ត្រូវជាប្រពន្ធសពជនរងគ្រោះឈ្មោះ [redacted] ចាន់ដេវិត ប្តឹងទាមទារសំណងរដ្ឋប្បវេណី សរុបចំនួន ៥០.០០០ (ប្អូនម៉ឺន) ដុល្លារអាមេរិក។ ឈ្មោះ [redacted] សុថាត ត្រូវជាប្រពន្ធសពជនរងគ្រោះឈ្មោះ [redacted] ចាន់ដេវិត ជាសន្តតិជនជានិច្ច តុលាការគប្បីកំណត់យកឈ្មោះ [redacted] សុថាត ជាអ្នកទទួលសំណងពីជនជាប់ចោទ តាម មាត្រា១១៦១ នៃក្រមរដ្ឋប្បវេណី។

១៧.៦.ឈ្មោះ [redacted] ចំរើន ត្រូវជាបងប្រុស និងឈ្មោះ [redacted] សំណាង ត្រូវជាប្រពន្ធ សពជនរងគ្រោះឈ្មោះ [redacted] ចន្ថា ប្តឹងទាមទារសំណងរដ្ឋប្បវេណី សរុបចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិក។ ឈ្មោះ [redacted] សំណាង ត្រូវជាប្រពន្ធសពជនរងគ្រោះឈ្មោះ [redacted] ចន្ថា ជាសន្តតិជនជានិច្ច តុលាការគប្បីកំណត់យកឈ្មោះ [redacted] សំណាង ជាអ្នកទទួលសំណងពីជនជាប់ចោទ តាមមាត្រា១១៦១ នៃក្រមរដ្ឋប្បវេណី។

១៧.៧.ឈ្មោះ [redacted] អិត ប្តឹងទាមទារសំណងរដ្ឋប្បវេណី សរុបចំនួន ៣០.០០០ (បីម៉ឺន) ដុល្លារ អាមេរិក តុលាការគប្បីពិចារណា។

១៧.៨.ឈ្មោះ [redacted] ចិនឡាង ត្រូវជាកូនរបស់សពជនរងគ្រោះឈ្មោះ [redacted] ណា (ជាឪពុក) ឈ្មោះ [redacted] ដែន (ជាម្តាយ) ប្តឹងទាមទារសំណងរដ្ឋប្បវេណី សរុបចំនួន ១៣០.០០០ (ដប់បីម៉ឺន) ដុល្លារអាមេរិក តុលាការគប្បីពិចារណា។

១៧.៩.ឈ្មោះ [redacted] ញ៉ ត្រូវជាឪពុករបស់សពជនរងគ្រោះឈ្មោះ [redacted] ចាន់ថន ប្តឹងទាមទារសំណងរដ្ឋប្បវេណី សរុបចំនួន ៩០.០០០ (ប្រាំបួនម៉ឺន) ដុល្លារអាមេរិក តុលាការគប្បីពិចារណា។

១៧.១០.ឈ្មោះ [redacted] ម៉ារ៉ា ត្រូវជាប្រពន្ធរបស់សពជនរងគ្រោះឈ្មោះ [redacted] សុខហៀង ប្តឹងទាមទារសំណងរដ្ឋប្បវេណី សរុបចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិក តុលាការគប្បីពិចារណា។

១៧.១១.ឈ្មោះ [redacted] យ៉ុន ត្រូវជាប្រពន្ធរបស់សពជនរងគ្រោះឈ្មោះ [redacted] មៅ ប្តឹងទាមទារសំណងរដ្ឋប្បវេណី សរុបចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិក តុលាការគប្បីពិចារណា។

១៧.១២.ឈ្មោះ [redacted] ហាត់ ត្រូវជាប្រពន្ធរបស់សពជនរងគ្រោះឈ្មោះ [redacted] វិច្ឆិរ៉ា ប្តឹងទាមទារសំណងរដ្ឋប្បវេណី សរុបចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិក តុលាការគប្បីពិចារណា។

១៧.១៣.ឈ្មោះ [redacted] វណ្ណី ត្រូវជាម្តាយរបស់សពជនរងគ្រោះឈ្មោះ [redacted] បញ្ញា ប្តឹងទាមទារសំណងរដ្ឋប្បវេណី សរុបចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិក តុលាការគប្បីពិចារណា។

Scanned with CamScanner

១៧.១៤.ឈ្មោះ [redacted] ផៃ ត្រូវជាឪពុករបស់សពជនរងគ្រោះឈ្មោះ [redacted] ជាន់ណា ប្តឹងទាមទារសំណងរដ្ឋប្បវេណី សរុបចំនួន ៣០.០០០ (បីម៉ឺន) ដុល្លារអាមេរិក តុលាការគប្បីពិចារណា។

១៧.១៥.ឈ្មោះ [redacted] ថេន ត្រូវជាឪពុកសពជនរងគ្រោះឈ្មោះ [redacted] ឃាន ប្តឹងទាមទារសំណងរដ្ឋប្បវេណី សរុបចំនួន ៣០.០០០ (បីម៉ឺន) ដុល្លារអាមេរិក តុលាការគប្បីពិចារណា។

១៧.១៦.ឈ្មោះ [redacted] ម៉ុម ត្រូវជាម្តាយបង្កើតរបស់សពជនរងគ្រោះឈ្មោះ [redacted] ចន្ថា និងត្រូវជាម្តាយក្មេកសពជនរងគ្រោះឈ្មោះ [redacted] ប្រុស ប្តឹងទាមទារសំណងរដ្ឋប្បវេណី សរុបចំនួន ៤៨០.០០០.០០០ (បួនរយប៉ែតសិបលាន) រៀល តុលាការគប្បីពិចារណា។

១៧.១៧.ឈ្មោះ [redacted] សុភា ត្រូវជាប្រពន្ធរបស់សពជនរងគ្រោះឈ្មោះ [redacted] ទឹម ប្តឹងទាមទារសំណងរដ្ឋប្បវេណី សរុបចំនួន ១៦០.០០០.០០០ (មួយរយហុកសិបលាន) រៀល តុលាការគប្បីពិចារណា។

១៧.១៨.ឈ្មោះ [redacted] កែនរស្មី ត្រូវជាប្តីរបស់សពជនរងគ្រោះឈ្មោះ [redacted] លំអង ប្តឹងទាមទារសំណងរដ្ឋប្បវេណី សរុបចំនួន ៥០០.០០០. ០០០ (បួនរយលាន) រៀល តុលាការគប្បីពិចារណា។

១៧.១៩.ឈ្មោះ [redacted] ស្រីកា ត្រូវជាបងស្រីរបស់សពជនរងគ្រោះឈ្មោះ [redacted] សុភ័ណ្ឌ ប្តឹងទាមទារសំណងរដ្ឋប្បវេណី សរុបចំនួន ៦០.០០០ (ប្រាំមួយម៉ឺន) ដុល្លារអាមេរិក តុលាការគប្បីពិចារណា។

១៧.២០.ឈ្មោះ [redacted] ប្រុស ត្រូវជាឪពុករបស់សពជនរងគ្រោះឈ្មោះ [redacted] សំណាង និងឈ្មោះ [redacted]ភត្រា ប្តឹងទាមទារសំណងរដ្ឋប្បវេណី សរុបចំនួន ១២០.០០០ (ដប់ពីរម៉ឺន) ដុល្លារអាមេរិក តុលាការគប្បីពិចារណា។

១៧.២១.ឈ្មោះ [redacted] សារុន ត្រូវជាប្រពន្ធរបស់សពជនរងគ្រោះឈ្មោះ [redacted] ម៉េង ប្តឹងទាមទារសំណងរដ្ឋប្បវេណី សរុបចំនួន ៣០.០០០ (បីម៉ឺន) ដុល្លារអាមេរិក តុលាការគប្បីពិចារណា។

១៧.២២.ឈ្មោះ [redacted] លេង ត្រូវជាប្រពន្ធរបស់សពជនរងគ្រោះឈ្មោះ [redacted] ថា ហៅ ចាន់តូ ប្តឹងទាមទារសំណងរដ្ឋប្បវេណី សរុបចំនួន ៣០.០០០ (បីម៉ឺន) ដុល្លារអាមេរិក តុលាការគប្បីពិចារណា។

១៨.លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឲ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]រិទ្ធវុឌ្ឍ បានធ្វើសេចក្តីសន្និដ្ឋានទាមទារថា: សំណងការខូចខាតដែលកូនក្តីខ្ញុំបាទទាមទារមានៈ ទាមទារថ្លៃខូចខាត សម្ភារៈផ្ទះចំនួន ៧៣.០០០ (ប្រាំពីរម៉ឺនបីពាន់) ដុល្លារអាមេរិក, ទាមទារការខូចខាតថ្លៃជួលផ្ទះដែលជនជាតិជប៉ុនត្រូវបន្តជួលចំនួន ១៩៤.០០០ (ដប់បួនម៉ឺនបួនពាន់) ដុល្លារអាមេរិក និងទាមទារសំណងជំងឺចិត្តចំនួន ៣.០០០ (បីពាន់) ដុល្លារអាមេរិក ខ្លួនសុំសរុបចំនួនទឹកប្រាក់ដែលកូនក្តីខ្លួនទាមទារមានចំនួន ២៤៧.០០០ (ម្ភៃបួនម៉ឺនប្រាំពីរពាន់) ដុល្លារអាមេរិក តុលាការគប្បីពិចារណា។

១៩.លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឲ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] TOMOTAKA បានធ្វើសេចក្តីសន្និដ្ឋានទាមទារថា: ខ្លួនសុំធ្វើសេចក្តីសន្និដ្ឋានរួម និងសុំទាមទារការខូចខាតរបស់កូនក្តីខ្លួនដែលមានដូចជា សម្ភារៈចង្ក្រាន តុ ទ្វ កៅអី ភេសជ្ជៈផ្សេងៗ

ដែលនៅក្នុងផ្ទះចំនួន ៩៩.៧១៥ (ប្រាំបួនម៉ឺនប្រាំបួនពាន់ប្រាំពីរយដប់ប្រាំ) ដុល្លារអាមេរិក. ទាមទារការខាតបង់ចំណូលថ្លៃអាជីវកម្មចំនួន ១២០.០០០ (ដប់ពីរម៉ឺន) ដុល្លារអាមេរិក និង ទាមទារសំណងជំងឺចិត្តចំនួន ៨៥.០០០ (ប្រាំបីម៉ឺនប្រាំពាន់) ដុល្លារអាមេរិក ដោយសារតែការភិតភ័យនាពេលអគារបាក់រលំ តុលាការគប្បីពិចារណា។

២០.លោកស្រី [redacted] ជាមេធាវីតំណាងដោយអាណត្តិឲ្យដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ [redacted] វ៉ាន់ដា បានសេចក្តីសន្និដ្ឋានទាមទារថា: ឆ្លងកាត់នីតិវិធីនៃការស៊ើបអង្កេត នីតិវិធីនៃការស៊ើបសួរ និងនីតិវិធីនៃការជំនុំជម្រះរួចមកឃើញថា: តាមរយៈភស្តុតាង និងការបំភ្លឺរបស់មន្ត្រីជំនាញបានបង្ហាញថា ការសាងសង់អគាររលំបាក់នេះ ពុំមានលិខិតអនុញ្ញាតឲ្យសាងសង់នោះទេ នេះបង្ហាញថាសំណង់ខាងលើជាសំណង់ខុសច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា (អនុក្រឹត្យលេខ៨៦ អនក្រ.បក ស្តីពីលិខិតអនុញ្ញាតសាងសង់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧)។

យោងតាមចម្លើយរបស់ឈ្មោះ [redacted] KUN (ម្ចាស់សំណង់),ឈ្មោះ [redacted] XING GUI (អ្នកមៅការសាងសង់) និងឈ្មោះ [redacted] YAPING (ជាអ្នកជួយមើលការខុសត្រូវការសាងសង់) បានឃើញ និងដឹងយ៉ាងច្បាស់ថា សំណង់ដែលកំពុងសាងសង់នេះ ទ្រេតប្រហែល ០១ តឹកកន្លះទៅ ០២ តឹក ហើយពួកគេនៅតែបន្តអនុញ្ញាត និងសាងសង់ ការណ៍នេះជាមូលហេតុមួយដែលនាំឲ្យអគារខាងលើរលំ។ ពួកគេមានចេតនាទុច្ចរិតដូចមានបញ្ញត្តិនៅក្នុងមាត្រា ៤ កថាខណ្ឌទី២ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ចែងថា "...ប៉ុន្តែក្នុងករណីដែលច្បាប់ចែងទុកមុន បទល្មើសមួយអាចកើតចេញពីការមិនប្រុងប្រយ័ត្ន ការខ្វីខ្ជា ការធ្វេសប្រហែស ឬការមិនគោរពកាតព្វកិច្ចដោយឡែកណាមួយ" ហើយអំពើនេះ គឺជាកំហុសចេតនា (កំហុសចេតនានៃអំពើអនីតិសាស្ត្រ) តាមបញ្ញត្តិមាត្រា៧៤២ នៃក្រមរដ្ឋប្បវេណី។ ក្នុងនាមខ្លួនជាមេធាវីតំណាងដោយអាណត្តិឲ្យក្នុងក្តីសំណូមពរឲ្យតុលាការ ផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ និងសុំឲ្យតុលាការបង្គាប់ឲ្យជនជាប់ចោទសងសំណងការខូចខាត និងសំណងជំងឺចិត្តទៅឲ្យក្នុងក្តីខ្លួនចំនួន ៣៦.៣០០ (បីម៉ឺនប្រាំមួយពាន់បីរយ) ដុល្លារអាមេរិក, ថ្លៃខាតបង់លើការផ្អាកអាជីវកម្មដើម្បីជួសជុលយានដ្ឋានសារជាថ្មី ចំនួន ៤២.០០០ (បួនម៉ឺនពីរពាន់) ដុល្លារអាមេរិក ព្រមទាំងរថយន្តម៉ាក RANGROVER SPORT (series 2005) ថ្មី ចំនួន ០១ គ្រឿង ដែលមានតម្លៃ ៣៥.០០០ (បីម៉ឺនប្រាំពាន់) ដុល្លារអាមេរិក, រថយន្តម៉ាក LEXUS 470 (series 2001) ថ្មី ចំនួន ០១ គ្រឿង ដែលមានតម្លៃស្មើនឹង ៣០.០០០ (បីម៉ឺន) ដុល្លារអាមេរិក, រថយន្តម៉ាក HYUNDAI GRAND STAREX H1 (series 2001) ថ្មី ចំនួន០១ គ្រឿង ដែលមានតម្លៃស្មើនឹង ២២.៥០០ (ពីរម៉ឺនពីរពាន់ប្រាំរយ) ដុល្លារអាមេរិក, ថ្លៃជួសជុលរថយន្តម៉ាក MERCERDES BENZ (series 1996) ដែលមានតម្លៃសរុបស្មើនឹង ចំនួន ៦.០០០ (ប្រាំមួយពាន់) ដុល្លារអាមេរិក និងថ្លៃជួសជុលរថយន្តម៉ាក HYUNDAI ទម្ងន់ ១.៥ តោន ដែលមានតម្លៃសរុបស្មើនឹងចំនួន ២.៥០០ (ពីរពាន់ប្រាំរយ) ដុល្លារអាមេរិក ដោយក្តីអនុគ្រោះ តុលាការគប្បីពិចារណា។

២១.លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឲ្យដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ [redacted] ម៉ុម, ឈ្មោះ [redacted] សុភា, ឈ្មោះ [redacted] គែនរស្មី, ឈ្មោះ [redacted] សុខន, ឈ្មោះ [redacted] នាង, ឈ្មោះ [redacted] ចំរើន, ឈ្មោះ [redacted] ប៊ុនធឿន, ឈ្មោះ [redacted] សែន, ឈ្មោះ [redacted] ស្រីកា, ឈ្មោះ [redacted] ប្រុស, ឈ្មោះ [redacted] សុខខៀន, ឈ្មោះ [redacted] សារុន, ឈ្មោះ [redacted] លេង, ឈ្មោះ [redacted] ពៅ, ឈ្មោះ [redacted]

ឃាង. ឈ្មោះ[redacted] វុធ, ឈ្មោះ[redacted]ផេត, ឈ្មោះ[redacted] សំអុល, ឈ្មោះ[redacted] ប្រុស, ឈ្មោះ[redacted] សាវ៉ាត និងឈ្មោះ [redacted] ធីម បានធ្វើសេចក្តីសន្និដ្ឋានទាមទារថា: ខ្លួនជាមេធាវីតំណាងដោយអាណត្តិឲ្យដើមបណ្តឹងរដ្ឋប្បវេណី ដែលទទួលរងគ្រោះក្នុងករណីបាក់រលំអគារកម្ពស់ ០៧ ជាន់ ករណីរលំបាក់អគារនេះ បណ្តាលមកពីបទល្មើសព្រហ្មទណ្ឌដែលមានបញ្ជាក់ពីការរកឃើញនូវពិរុទ្ធភាពរបស់ជនជាប់ចោទទាំងអស់នៅក្នុងដីកាសន្និដ្ឋានស្តាពរ និងបានចោទប្រកាន់ជនជាប់ចោទដែលប្រព្រឹត្តអំពើដោយផ្ទាល់មានឈ្មោះ [redacted] KUN និងឈ្មោះ [redacted] XING GUI ពីបទ មនុស្សឃាតដោយអចេតនា, បទ បង្កវិបូសស្នាមដោយអចេតនា និងបទធ្វើឲ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោសដោយសារការបង្កវិបូសដល់អ្នកដទៃ និងបានចោទប្រកាន់ទៅលើបក្ខពួកផ្សេងទៀត ពីបទ សមគំនិតក្នុងអំពើមនុស្សឃាតដោយអចេតនា, បទ សមគំនិតក្នុងអំពើបង្កវិបូសស្នាមដោយអចេតនា និងបទ សមគំនិតក្នុងអំពើធ្វើឲ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោសដោយសារការបង្កវិបូសដល់អ្នកដទៃ ដែលមានកំណត់ថាជាបទល្មើសនៅក្នុងក្រមព្រហ្មទណ្ឌ។ ឃើញថា ក្នុងការពិភាក្សាដេញដោលនាពេលសវនាការ ជនជាប់ចោទឈ្មោះ [redacted] KUN ជាម្ចាស់អគារ ដែលបានធ្វើសកម្មភាពវិនិយោគទៅលើអគារដោយពុំមានច្បាប់អនុញ្ញាត ហើយជនជាប់ ចោទខ្លួនឯងក៏បានដឹងថាការធ្វើសកម្មភាពក្នុងការសាងសង់ដោយពុំមានច្បាប់អនុញ្ញាតគឺជាអំពើដែលមិនត្រឹមត្រូវដែរ ដោយបានបង្កើតកំហុសដោយចេតនា ដែលឲ្យមេការសំណង់ឈ្មោះ [redacted] XING GUI ធ្វើការសាងសង់សំណង់ដែលពុំមានច្បាប់អនុញ្ញាត ហើយជនជាប់ចោទឈ្មោះ [redacted] KUN និងឈ្មោះ[redacted] XING GUI បានដឹងយ៉ាងច្បាស់ថា សំណង់អគារដែលខ្លួនបានសង់គឺមិនគោរពទៅតាមបទដ្ឋានសំណង់មានការវៀច ហើយនៅពេលដែលធ្វើការសាងសង់មានការកែតម្រូវខ្នាតអគារដែលអ្នកទាំងពីរជាពិសេសជនជាប់ចោទឈ្មោះ [redacted] XING GUI បានដឹងយ៉ាងច្បាស់ថាការកែតម្រូវខ្នាតអគារនោះ មានការប៉ះពាល់ទៅដល់ទម្រង់ទ្រទាំងមូលនៃអគារដែលអាចឲ្យមានហានិភ័យដល់អគារដែលអាចបង្កឲ្យមានផលប៉ះពាល់ដល់អ្នកដទៃ។ នៅពេលដែលកំពុងសាងសង់ជនជាប់ចោទឈ្មោះ [redacted] XING GUI ដែលជាអ្នកទទួលបន្ទុកមៅការសាងសង់ មានចេតនាធ្វេសប្រហែសក្នុងការគ្រប់គ្រងស្ថានភាព នៃគម្រោងអគារដោយធ្វើការសាងសង់ដោយពុំបានបំពាក់ខ្ចៅត្រឹមត្រូវតាមស្តង់ដា តាមកោសលវិច័យរបស់អ្នកជំនាញបានបញ្ជាក់ពីភាពខុសគ្នាយ៉ាងឆ្ងាយពីទម្រង់នៃការសាងសង់ ដែលការកម្រិតខ្ចៅទៅលើដំណរភ្ជាប់នៃដែក និងសំណង់ គឺអាចគ្រប់គ្រងបានត្រឹមតែប្រាំជាន់តែប៉ុណ្ណោះ ប៉ុន្តែជនជាប់ចោទបានសាងសង់រហូតដល់ចំនួន ០៧ ជាន់ ការណ៍នេះបញ្ជាក់ឲ្យឃើញអំពីកំហុសដោយចេតនា។ ទន្ទឹមនឹងនោះ កម្មករដែលជាកូនក្តីរបស់ខ្លួន ដែលជាជនរងគ្រោះនោះ ជាអ្នកដែលធ្វើការងារក្រោមបង្គាប់របស់និយោជកឈ្មោះ [redacted] KUN និងឈ្មោះ [redacted] XING GUI តែឈ្មោះ [redacted] XING GUI បានបដិសេធនាពេលសវនាការថា គាត់ពុំមានកូនជាងទេ ប៉ុន្តែតាមចម្លើយរបស់សាក្សីឈ្មោះ [redacted] សុវិន បានបញ្ជាក់ថា គាត់ជាអ្នកទទួលលុយផ្ទាល់ពីឈ្មោះ [redacted] XING GUI ចម្លើយនេះបញ្ជាក់ថាកម្មករទាំងអស់នៅក្នុងអគារនោះ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់បុគ្គលទាំងពីរូបនេះ។ ថ្វីត្បិតតែកូនក្តីរបស់ខ្លួនបានទទួលនូវថវិការឧបត្ថម្ភពីរដ្ឋ ប៉ុន្តែថវិកានោះគឺពុំមែនជាថវិការដែលកើតចេញពីសំណងរបស់ជនជាប់ចោទនោះទេ ខ្លួនសុំឲ្យតុលាការពិចារណាទៅលើលក្ខណៈពិសេសមួយរបស់កម្មករដែលជាកូនក្តីរបស់ខ្លួន ដែលកម្មករទាំងអស់ភាគច្រើនជាបុគ្គលចំបងនៅក្នុង

គ្រួសារ ការបាត់បង់បុគ្គលចំបងនៅក្នុងគ្រួសារដែលស្ថិតនៅក្នុងស្ថានភាពក្រីក្រនោះ បានប៉ះពាល់ទៅដល់ជីវភាពគ្រួសារទាំងមូលតែម្តង បាត់បង់បុគ្គលចំបងដែលជាអ្នករកលុយផ្គត់ផ្គង់គ្រួសារ ខ្លួនសុំឲ្យតុលាការមេត្តាពិចារណានៅក្នុងការផ្តល់សំណង ក្នុងកម្រិតព្រំដែនអតិបរមានៃការទាមទារ។

ជារួមជនជាប់ចោទឈ្មោះ [redacted] KUN និងឈ្មោះ [redacted] XING GUI មានកាតព្វកិច្ចទទួលខុសត្រូវក្នុងការសងសំណងការខូចខាតរួមចំពោះជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី។ ជនជាប់ចោទមានការដ្ឋាន និងក្រុមហ៊ុនជាក់ស្តែងមួយចំនួនដែលកំពុងតែកាន់កាប់ និងមានគណនីធនាគារផងដែរ ដែលបញ្ជាក់ថាជនជាប់ចោទមានលទ្ធភាព ខ្លួនស្នើសុំឲ្យតុលាការមេត្តាចាត់វិធានការណ៍ ក្នុងការរឹបអូសនូវទ្រព្យសម្បត្តិរបស់ជនជាប់ចោទដើម្បីធានាសំណងដល់ដើមបណ្តឹងរដ្ឋប្បវេណី។ ក្នុងនាមខ្លួនជាមេធាវីតំណាងដោយអាណត្តិឲ្យដើមបណ្តឹងរដ្ឋប្បវេណីទាំង២១ រូប ទាំងរងរបួស និងសិទ្ធិវិន្តរបស់ជនរងគ្រោះដែលបាត់បង់ជីវិត សុំរក្សាការទាមទារដូចក្នុងពាក្យបណ្តឹង។ ចំពោះជនបង្កផ្សេងទៀត ខ្លួនស្នើសុំឲ្យតុលាការមេត្តាពិចារណាអំពីកំហុស និងការទទួលខុសត្រូវនៅក្នុងករណីដែលតុលាការរកឃើញថាមានកំហុស សុំតុលាការមេត្តាពិចារណាអំពីកាតព្វកិច្ចសាមគ្គីនៅក្នុងរឿងនេះដោយក្តីអនុគ្រោះ។

២២.លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឲ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុន. ឈ្មោះ [redacted] ចិនឡាង, ឈ្មោះ [redacted] ញ៉, ឈ្មោះ [redacted] ចាន់ណេត, ឈ្មោះ [redacted] អៀន, ឈ្មោះ [redacted] មារ៉ា, ឈ្មោះ [redacted] យ៉ិន, ឈ្មោះ [redacted] ហាត់, ឈ្មោះ [redacted] វណ្ណា, ឈ្មោះ [redacted] អិត, ឈ្មោះ [redacted] សំណាង, ឈ្មោះ [redacted] ថាន, ឈ្មោះ [redacted] ផៃ, ឈ្មោះ [redacted] សាខន, ឈ្មោះ [redacted] ថេន, ឈ្មោះ [redacted] សុភាព, ឈ្មោះ [redacted] សុផល់, ឈ្មោះ [redacted] ដា, ឈ្មោះ [redacted] វស់ និងឈ្មោះ [redacted] ស៊ីថា បានធ្វើសេចក្តីសន្និដ្ឋានទាមទារថា: ខ្លួនសុំរក្សានូវសេចក្តីថ្លែងការណ៍ដូចគ្នាទាំងស្រុងជាមួយនឹងសហភាគាឈ្មោះ [redacted] ចាន់ណេត។ ក្រោយពីការសួដេញដោលនាពេលសវនាការ យើញថាជនជាប់ចោទឈ្មោះ [redacted] KUN បានបង្កើតកិច្ចសន្យាជួលដី ហើយសាងសង់អគារ ដោយការដោះសាររបស់គាត់នាពេលសវនាការ និងចម្លើយគ្រប់ដំណាក់កាលយើញថា មានការប្រែប្រួលរហូត គាត់កំពុងតែឆ្លើយគេចវេះអំពីកំហុស និងកាតព្វកិច្ចដែលគាត់ត្រូវទទួល តែចំណុចដែលគាត់មិនអាចគេចវេះបាននោះគឺគាត់បង្ខំចិត្តត្រូវតែសាងសង់អគារនេះបន្ថែមចំនួន០២ ជាន់ទៀត ដែលតាមលក្ខណៈបច្ចេកទេសពិនិត្យឃើញថា អគារនេះមិនអាចសាងសង់ថែមចំនួន ០២ ជាន់ទៀតបានទេ តែដោយសារតែគាត់ចង់វិនិយោគបានធ្វើឲ្យគាត់សាងសង់បន្ថែមចំនួន០២ ជាន់ទៀត ដែលនេះជាមូលហេតុនៃការបាក់រលំអគារនេះ។ ចំពោះជនជាប់ចោទឈ្មោះ [redacted] XING GUI បានអះអាងថាគាត់ជាវិស្វករ ប៉ុន្តែពុំអត់មានសញ្ញាបត្រទេ ផ្ទុយមកវិញ តាមចម្លើយរបស់គាត់ យើញថាគាត់មិនមែនជាវិស្វករទេ ព្រោះគាត់បានអះអាងថាគាត់ចេះផ្សារដែកតាំងពីអាយុ១៥ ឆ្នាំ ដូច្នេះគាត់មកធ្វើការសាងសង់នេះ ធ្វើទៅតាមអ្វីដែលគាត់ចេះធម្មតា ដោយមិនបានយកចិត្តទុកដាក់ ខ្ជិខ្ជារក្នុងការសាងសង់ ដែលធ្វើឲ្យអគារងាយនឹងបាក់រលំ។ ម្យ៉ាងទៀតគាត់ពិតជាបានចុះកិច្ចសន្យាសាងសង់អគារនេះ ដោយមានហត្ថលេខារបស់គាត់ពិតប្រាកដ បានទទួលស្គាល់ថាគាត់បានទទួលប្រាក់ពីឈ្មោះ [redacted] KUN ចំណុចនេះបញ្ជាក់ថា គាត់ត្រូវតែមានកាតព្វកិច្ចទទួលខុសត្រូវពាក់ព័ន្ធនឹងបទល្មើសព្រហ្មទណ្ឌផង និងការសងសំណងចំពោះ

ជនរងគ្រោះផង ខ្លួនសុំរក្សាការទាមទារសំណងការខូចខាត និងជំងឺចិត្តដូចក្នុងពាក្យបណ្តឹងទាំងស្រុង។

២៣.លោកស្រី [redacted] ជាមេធាវីតំណាងដោយអាណត្តិឲ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ល័ក្ខ, ឈ្មោះ [redacted] ប្រុស, ឈ្មោះ [redacted] រ៉ែន, ឈ្មោះ [redacted] យ៉ុន, ឈ្មោះ [redacted] ផិត និងឈ្មោះ [redacted] ការ បានធ្វើសេចក្តីសន្និដ្ឋានទាមទារថា: ខ្លួនសុំធ្វើសេចក្តីសន្និដ្ឋានទាមទារដូចគ្នានឹងការសន្និដ្ឋានរបស់សហភាគាខាងលើ និងសុំរក្សាការទាមទារដូចមាននៅក្នុងពាក្យបណ្តឹងទាំងស្រុង។

២៤.តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា: ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទទាំង ០៤ រូប និងការពិនិត្យភស្តុតាងផ្សេងៗក្នុងសំណុំរឿងនេះ តំណាងអយ្យការសុំធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំដូចតទៅ: ជនជាប់ចោទឈ្មោះ [redacted] KUN និងឈ្មោះ [redacted] XING GUI ត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទ មនុស្សឃាតដោយអចេតនា បទ បង្ករបួសស្នាមដោយអចេតនា និងបទ ធ្វើឲ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោសដោយសារការបង្កឲ្យមានរបួសស្នាមដល់អ្នកដទៃ ប្រព្រឹត្តនៅ ភូមិ៣ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៩។ ជនជាប់ចោទឈ្មោះ [redacted] YAPING ឈ្មោះ [redacted] YU ឈ្មោះ [redacted] THI THUY HAO ហៅ អាហ័រ និងឈ្មោះ [redacted] ប៊ុនធឿន ត្រូវបានដាក់ឲ្យស្ថិតក្រោមការពិនិត្យពីបទ សមគំនិតក្នុងអំពើមនុស្សឃាតដោយអចេតនា បទ សមគំនិតក្នុងអំពើបង្ករបួសស្នាមដោយអចេតនា និងបទ សមគំនិតក្នុងអំពើធ្វើឲ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោសដោយសារការបង្កឲ្យមានរបួសស្នាមដល់អ្នកដទៃ ប្រព្រឹត្តនៅ ភូមិ៣ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៩ តាមបញ្ញត្តិមាត្រា២៩ មាត្រា២០៧ មាត្រា ២៣៦ និងមាត្រា៤១៤ នៃក្រមព្រហ្មទណ្ឌ។ អង្គហេតុនៃការចោទប្រកាន់គឺមានការរលំបាក់អគារ ដែលជាក់ស្តែងជនជាប់ចោទបានអះអាងថាមានកម្ពស់០៧ជាន់ តែការពិនិត្យនៅកន្លែងកើតហេតុចាត់ទុកថា ០៨ ជាន់ ដោយសារមានដំបូលខាងលើព្យសនកម្មបង្កឲ្យមានការខូចខាតសំណង់ ក៏ដូចជាទ្រព្យសម្បត្តិអ្នកជិតខាង និងបង្កឲ្យមានមនុស្សស្លាប់ចំនួន ២៨ នាក់ និងរបួសចំនួន ២៦ នាក់ ផងដែរ។ តំណាងអយ្យការសុំទាញចំណាប់អារម្មថា ក្រៅពីរបបប៉ុលពតមានតែ អង្គហេតុនេះមួយដែលបង្កឲ្យមានមនុស្សស្លាប់ច្រើន បន្ទាប់ពីហេតុការនៅកោះពេជ្រ តំណាងអយ្យការសុំសំដែងនូវការសោកស្តាយចំពោះជនរងគ្រោះដែលបានបាត់បង់ជីវិត និងរងរបួស។ ការចោទប្រកាន់អំពីបទល្មើសខាងលើមានលក្ខណៈគ្រប់គ្រាន់ក្នុងការចោទប្រកាន់ និងការទទួលខុសត្រូវចំពោះមុខច្បាប់របស់ជនជាប់ចោទ។ ចំពោះជនជាប់ចោទឈ្មោះ [redacted] KUN ក្រោយ ពីបានធ្វើការស៊ើបអង្កេតយ៉ាងហ្មត់ចត់និងការស៊ើបសួររបស់ចៅក្រមស៊ើបសួរអាចបញ្ជាក់ឲ្យឃើញថា គាត់ជាម្ចាស់អគារដែលបាក់រលំ រីឯជនជាប់ចោទឈ្មោះ [redacted] XING GUI គឺជាអ្នកមៅការសំណង់ ព្រមទាំងជាជាងសំណង់ផងដែរ។ ជនជាប់ចោទឈ្មោះ [redacted] YAPING ជាបងជីដូនមួយរបស់ឈ្មោះ [redacted] KUN មានតួនាទីមើលការខុសត្រូវលើការដ្ឋានសំណង់នោះផងដែរ។ ដោយឡែកឈ្មោះ [redacted] YU ជាជាងបូក និងលាបថ្នាំ ហើយក្នុងពេលនោះផងដែរ ជនជាប់ចោទឈ្មោះ [redacted] YU មានវត្តមាននៅលើអគារនោះផងដែរ ដែលគាត់បានស៊ីឈ្នួលឈ្មោះ [redacted] KUN និងចូលទៅធ្វើការងារនៅលើសំណង់អគារនោះ ហើយក៏មានការតាំងសំណួររបស់មេធាវីថា តើជាងបូកនោះធ្វើ

ឲ្យអគាររលំឬទេ? តំណាងអយ្យការក៏ចង់ស្វែងរកន្លូវចម្លើយផងដែរ ជាក់ស្តែងនៅពេលដែលរលំបាក់ តំណាងអយ្យការខ្លួនឯង និងបុគ្គលគ្រប់រូបមិនដឹងថាបាក់ដោយសារមូលហេតុអ្វីដែរ។ មុននឹងឈានទៅកំណត់ថានរណាដែលជាប់ពាក់ព័ន្ធ និងថាអគារបាក់ដោយសារអ្វីទើបរាជរដ្ឋាភិបាលបង្កើតក្រុមការងារពិសេសក្នុងការធ្វើកោសលវិច័យទៅលើសំណង់អគារនោះ។ ជនជាប់ចោទឈ្មោះ [redacted] THI THUY HAO ហៅ អាហ័រ ជាប្រពន្ធរបស់ឈ្មោះ [redacted] XING GUI តាមអង្គហេតុដែលរកឃើញបុគ្គលម្នាក់នេះជាអ្នកទិញដែក ចាត់ចែងការងារដែកសំណង់ទៅលើក្រុមហ៊ុនមួយដែលមានឈ្មោះ [redacted] XING GUI ជាម្ចាស់ក្រុមហ៊ុន ហើយគាត់ក៏ជាអ្នករត់ការច្បាប់សាងសង់ផងដែរ ដោយឡែកជនជាប់ចោទឈ្មោះ សាត ប៊ុនធឿន ជាមេជាងសំណង់ និងគ្រោងដែក ហើយក៏ជាអ្នកមៅការសំណង់បន្តពីឈ្មោះ [redacted] XING GUI ផងដែរ ទើបមានការជាប់ពាក់ព័ន្ធចំពោះបុគ្គលទាំង០៦ រូប។ សរុបសេចក្តីមក តំណាងអយ្យការតម្កល់បទចោទទៅលើជនជាប់ចោទទាំង ០៥ រូប ទុកជាត្រឹមត្រូវនៅដដែល ដោយឡែកជនជាប់ចោទឈ្មោះ [redacted] YU សុំឲ្យក្រុមប្រឹក្សាជំនុំជម្រះពិនិត្យ និងសម្រេចទៅតាមច្បាប់។

២៥.លោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] XING GUI បានធ្វើសេចក្តីសន្និដ្ឋានការពារកូនក្តីខ្លួនថា: មុននឹងឈានដល់ការធ្វើសេចក្តីសន្និដ្ឋាន ខ្លួនសុំចូលរួមរំលែកទុក្ខជាមួយក្រុមគ្រួសារសព និងជនរងគ្រោះដែលរងរបួសដោយការសោកស្តាយ។ កូនក្តីខ្លួនបានរងបទចោទប្រកាន់ចំនួន ០៣ បទល្មើស ពីបទ មនុស្សឃាតដោយអចេតនា បទ បង្ករបួសស្នាមដោយអចេតនា និងបទ ធ្វើឲ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោសដោយសារការបង្ករបួសស្នាមដល់អ្នកដទៃ។ ចំពោះបទចោទ មនុស្សឃាតដោយអចេតនា និងបទ បង្ករបួសស្នាមដោយអចេតនា តាមបញ្ញត្តិមាត្រា ២៣៦ និងតាមមាត្រា២០៧ នៃក្រមព្រហ្មទណ្ឌ ខ្លួនសុំទទួលយកដោយសារកូនក្តីខ្លួនបានប្រព្រឹត្តបទល្មើសដោយអចេតនា ដោយសារតែកូនក្តីខ្លួនជាអ្នកវិនិយោគ និងមិនចង់ជួបនូវឧប្បទ្វេវហេតុបាក់រលំអគារស្លាប់មនុស្សនោះទេ។ ចំពោះការចោទប្រកាន់កូនក្តីខ្លួនពីបទ ធ្វើឲ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោសដោយសារការបង្ករបួសដល់អ្នកដទៃ តាមបញ្ញត្តិមាត្រា ៤១៤ នៃក្រមព្រហ្មទណ្ឌ ខ្លួនពុំឯកភាពនោះទេ ព្រោះបញ្ញត្តិនៃមាត្រា៤១៤ ចង្អុលបង្ហាញទៅបញ្ញត្តិមាត្រា៤១៣ នៃក្រមព្រហ្មទណ្ឌ បានចែងថាស្ថានទម្ងន់ទោសដោយសារការប្រើប្រាស់វិធីគ្រោះថ្នាក់ដល់បុគ្គល អំពើប្រព្រឹត្តដោយចេតនាដើម្បីបំផ្លិចបំផ្លាញ ធ្វើឲ្យទ្រុឌទ្រោម ឬធ្វើឲ្យ ខូចខាតទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិរបស់អ្នកដទៃដោយអានុភាពនៃគ្រឿងផ្ទុះនៃអគ្គីភ័យ នៃគ្រប់វិធីដទៃទៀត ដែលនាំឲ្យគ្រោះថ្នាក់ដល់បុគ្គលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល បានផ្ទុយគ្នាទៅនឹងបញ្ញត្តិមាត្រា២០៧ និងមាត្រា២៣៦ នៃក្រមព្រហ្មទណ្ឌ ទៅហើយ ដូច្នេះបញ្ញត្តិមាត្រា៤១៤ នៃក្រមព្រហ្មទណ្ឌនេះ គឺសំដៅទៅលើបញ្ញត្តិមាត្រា៤១៣ នៃក្រមព្រហ្មទណ្ឌ សកម្មភាពចេតនា គឺត្រូវមានសកម្មភាពស្តែងចេញតាមរយៈការធ្វើឲ្យខូចខាត ធ្វើឲ្យផ្ទុះ ធ្វើអ្វីក៏ដោយមានចេតនាចេញជាក់ស្តែង ដូច្នេះខ្លួនសំណូមពរដល់តំណាងអយ្យការ និង ក្រុមប្រឹក្សាជំនុំជម្រះឲ្យលើកចោលបទចោទប្រកាន់លើកូនក្តីខ្លួនតាមបញ្ញត្តិមាត្រា ៤១៤ នៃក្រមព្រហ្មទណ្ឌ ព្រោះបញ្ញត្តិមាត្រានេះបានប្រឆាំងគ្នាជាមួយនឹងមាត្រា ៤១៣ មាត្រា ២០៧ និងមាត្រា ២៣៦ នៃក្រមព្រហ្មទណ្ឌ។ ពាក់ព័ន្ធនឹងជនរងគ្រោះនៅក្នុងសំណុំរឿងនេះចែកចេញជា ០៣ ប្រភេទ រួមមាន ជនរងគ្រោះដែលស្លាប់, ជនរងគ្រោះ

ដែលរបួសស្នាម និងជនរងគ្រោះទទួលការខូចខាត អ្នកជិតខាង ហើយព្រះករុណាព្រះបាទ នរោត្តម សីហមុនី. រាជរដ្ឋាភិបាលដែលមានសម្តេចអគ្គសេនាមហាបតីតេជោ ហ៊ុន សែន រួមនឹងស្ថានទូតចិនប្រចាំនៅកម្ពុជា បានជួយដល់ជនរងគ្រោះផ្នែកស្លាប់ និងរបួសជាច្រើនផងដែរ ដែលជនរងគ្រោះស្លាប់ និងរបួសបានទទួលជំនួយចាប់ពី ២០.000 (ពីរម៉ឺន) ដុល្លារអាមេរិក រហូតដល់ ៩0.000 (ប្រាំបួនម៉ឺន) ដុល្លារអាមេរិក ផងដែរ។ ចំណុចនេះ ខ្លួនស្នើសុំឲ្យក្រុមប្រឹក្សាជំនុំជម្រះមេត្តាពិចារណាថាជនជាប់ចោទបានខាតបង់ថវិការ ដែលបានវិនិយោគដោយសារអគាររលំបាក់អស់ទៅហើយ ដូច្នេះការប្តឹងទាមទារសំណងរដ្ឋប្បវេណីពីសំណាក់ដើមបណ្តឹងរដ្ឋប្បវេណីមានលក្ខណៈធ្ងន់ធ្ងរណាស់ចំពោះជនជាប់ចោទ ហើយមិនមានលទ្ភាពណាមួយដែលជនជាប់ចោទអាចសងដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះដូចក្នុងពាក្យបណ្តឹងបានទេ។ ម្យ៉ាងទៀត ក្នុនក្តីខ្លួនបានប្រគល់សំណង់អគារជាន់ទី១ ទៅឲ្យឈ្មោះ [redacted] KUN រួចរាល់ផងដែរ តែឈ្មោះ [redacted] KUN បានយកសំណង់អគារដែលក្នុនក្តីខ្លួនបានប្រគល់ ជួលឲ្យទៅឈ្មោះ ហៃ យៀក ហើយឈ្មោះ [redacted] យៀក បានហៅជាងមកជួសជុលដែលធ្វើឲ្យអគាររលំ ដូច្នេះអ្នកដែលទទួលខុសត្រូវនៅក្នុងការបាក់រលំអគារនេះ មានឈ្មោះ [redacted] XING GUI ឈ្មោះ [redacted] KUN និងឈ្មោះ [redacted] យៀក ផងដែរ។ ខ្លួនសំណូមពរឲ្យក្រុមប្រឹក្សាជំនុំជម្រះ និងតំណាងអយ្យការលើកលែងបទចោទតាមបញ្ញត្តិមាត្រា៤១៤ នៃក្រមព្រហ្មទណ្ឌ លើក្នុនក្តីខ្លួនចោល និងសុំឲ្យតុលាការដាក់ទណ្ឌកម្មលើក្នុនក្តីខ្លួននៅក្នុងបទចោទប្រកាន់តាមមាត្រា ២0៧ និងមាត្រា ២៣៦ នៃក្រមព្រហ្មទណ្ឌដោយក្តីអនុគ្រោះ។

២៦.លោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ ឈ្មោះ [redacted] YU, ឈ្មោះ [redacted] THI THUY HAO ហៅ អាហ័រ និងឈ្មោះ [redacted] ប៊ុនធឿន បានធ្វើសេចក្តីសន្និដ្ឋានការពារក្នុនក្តីខ្លួនថា: ឆ្លងតាមការសួរដេញដោលនាពេលសវនាការ និងតាមការពិនិត្យលើសំណុំរឿង ខ្លួនសុំធ្វើការសន្និដ្ឋានរួម អំពីបទចោទប្រកាន់លើក្នុនក្តីខ្លួនទាំង ០៣ រូប។ ក្នុនក្តីខ្លួនឈ្មោះ [redacted] YU ជាប់ចោទពីបទ សមគំនិតក្នុងអំពើមនុស្សឃាតដោយអចេតនា. បទ សមគំនិតក្នុងអំពើបង្កវបួសស្នាមដោយអចេតនា និងបទ សមគំនិតក្នុងអំពើធ្វើឲ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោសដោយសារការបង្កវបួសស្នាមដល់អ្នកដទៃ តាមបញ្ញត្តិមាត្រា ២៩ មាត្រា ២0៧ មាត្រា ២៣៦ និងមាត្រា៤១៤ នៃក្រមព្រហ្មទណ្ឌ យើញថាក្នុនក្តីខ្លួនគ្រាន់តែជាជាងឈ្នួក និងលាបថ្នាំ ដោយឈ្មោះ [redacted] KUN ដែលជាម្ចាស់សំណង់ធ្វើការពឹងពាក់ឲ្យជួយឈ្នួក លាបថ្នាំ ឬការកែតម្រូវតិចតួចតែប៉ុណ្ណោះ ហើយក្នុនក្តីខ្លួនទើបតែមកធ្វើការបាន ៣ ទៅ ៤ ថ្ងៃ តែប៉ុណ្ណោះ។ មួយវិញទៀត គាត់មកធ្វើការមិនបានមកធ្វើការពេញលេញនោះទេ ថ្ងៃខ្លះមានភ្លៀងមិនបានធ្វើតែម្តង ថ្ងៃខ្លះធ្វើបានតែ ២ ទៅ ៣ ម៉ោង តែប៉ុណ្ណោះ និងមកធ្វើការនៅមុនពេលដែលបាក់រលំអគារប្រហែល ១ សប្តាហ៍។ ការចោទប្រកាន់ក្នុនក្តីខ្លួនពីបទសមគំនិតនេះ ឃើញថា ហាក់ដូចជាផ្ទុយអំពីមាត្រា២៩ និយមន័យនៃអ្នកសមគំនិតបានចែងថា ត្រូវចាត់ទុកជាអ្នកសមគំនិតក្នុងបទឧក្រិដ្ឋ ឬបទមជ្ឈឹម ចំពោះបុគ្គលណាដែលជួយសម្រួលដោយចេតនាដល់ការប៉ុនប៉ង ឬការសម្រេចបទឧក្រិដ្ឋ ឬបទមជ្ឈឹមនោះ ដោយផ្តល់ជំនួយ ឬការឧបត្ថម្ភរបស់ខ្លួន តាមនិយមន័យនៃអ្នកសមគំនិតនេះឃើញថា តើគាត់សមគំនិតយ៉ាងដូចម្តេច? ជួយសម្រួលដោយចេតនាយ៉ាងដូចម្តេច? បើគាត់អត់ដឹងអំពីបច្ចេកទេសផងគាត់គ្រាន់តែជាអ្នកលាបថ្នាំ។ រីឯក្នុនក្តីខ្លួនម្នាក់ទៀតគ្រាន់តែជាអ្នកទទួលលុយពីឈ្មោះ [redacted]

XING GUI ដែលជាអ្នកចុះកិច្ចសន្យាជាមួយឈ្មោះ [redacted] KUN ទៅធ្វើការរត់ការច្បាប់សាងសង់ ប៉ុន្តែឈ្មោះ [redacted] XING GUI បានបញ្ជាក់ហើយថា គាត់បានទំនាក់ទំនងទៅអ្នករត់ការច្បាប់សាងសង់នោះ តែគាត់ឲ្យកូនក្តីខ្លួនឈ្មោះ [redacted] THI THUY HAO ហៅ អាហ័រ ជាអ្នកយកលុយទៅប្រគល់ឲ្យនរណាគាត់អត់ដឹងទេ ហើយនរណាដែលទទួលបន្ទុកក្នុងការចេញច្បាប់សាងសង់ ឬក៏រត់ការឲ្យគាត់នោះ គាត់អត់ដឹងច្បាស់ទេ ដឹងតែឲ្យលេខទូរស័ព្ទទៅឈ្មោះ [redacted] THI THUY HAO ហៅ អាហ័រ យកលុយ ១៥.000 (មួយម៉ឺនប្រាំពាន់) ដុល្លារអាមេរិក ទៅប្រគល់ឲ្យអ្នកដែលទទួលបន្ទុករត់ការនោះ។ ចំពោះកូនក្តីខ្លួនឈ្មោះ [redacted] ប៊ុនធឿន គាត់គ្រាន់តែជាកម្មករជាងដែកតែប៉ុណ្ណោះ។ ម្យ៉ាងទៀត មិនមានចម្លើយ ឬភស្តុតាងដាក់បន្ទុកណាមួយទៅលើកូនក្តីខ្លួនដែរ។ ខ្លួនសង្កេតឃើញថា ពុំមានភស្តុតាងណាមួយបញ្ជាក់ថា កូនក្តីខ្លួនទាំង ៣ នាក់ បានប្រព្រឹត្តបទល្មើសសមគំនិតនោះទេ ព្រោះថារាល់ការចុះកិច្ចសន្យាមានតែឈ្មោះ [redacted] KUN ដែលជាម្ចាស់អគារជាមួយឈ្មោះ [redacted] XING GUI ដែលជាអ្នកមៅការតែប៉ុណ្ណោះ ហើយកូនក្តីខ្លួនឈ្មោះ [redacted] YU បានបញ្ជាក់ផងដែរថា រាល់ការលាបថ្នាំសូរថាគាត់ត្រូវដឹងអំពីបច្ចេកទេសសំណង់ដែរ ឬទេ? ត្រូវដឹងអំពីប្លង់ស្តាបត្បកម្មដែរ ឬទេ? ដូច្នេះការលាបថ្នាំមិនចាំបាច់ដឹងអំពីបច្ចេកទេសសំណង់ឲ្យបានជាក់លាក់នោះទេ គ្រាន់តែធ្វើការ លាបថ្នាំទៅតាមបច្ចេកទេស ដោយលាបឲ្យបានស្មើ ឬក៏ឲ្យបានស្អាតតែប៉ុណ្ណោះ។ ផ្អែកតាមបញ្ញត្តិមាត្រា ៣៨ កថាខណ្ឌទី៥ នៃរដ្ឋធម្មនុញ្ញ និងមាត្រា ៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ វិមតិសង្ស័យត្រូវបានជាប្រយោជន៍ជនជាប់ចោទជានិច្ច ដូច្នេះខ្លួនសំណូមពរឲ្យប្រធានក្រុមប្រឹក្សាជំនុំជម្រះ ក៏ដូចជាតំណាងអយ្យការមេត្តាពិនិត្យអំពីវិមតិសង្ស័យទៅលើកូនក្តីខ្លួនទាំង ៣ រូប។ តាមការសួរដេញដោលមកលើកូនក្តីខ្លួននាពេលសវនាការឃើញថាពុំមានបទល្មើសដូចការចោទប្រកាន់មកលើកូនក្តីខ្លួននោះទេ សំណូមពរឲ្យតុលាការមេត្តាសម្រេចឲ្យកូនក្តីខ្លួនរួចផុតពីបទចោទពិបទ សមគំនិតក្នុងអំពើមនុស្សឃាតដោយអចេតនា បទ សមគំនិតក្នុងអំពើបង្ករបួសស្នាមដោយអចេតនា និងបទ សមគំនិតក្នុងអំពើធ្វើឲ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោសដោយសារការបង្ករបួសស្នាមដល់អ្នកដទៃ ដោយផ្អែកតាមបញ្ញត្តិមាត្រា ៣៨ កថាខណ្ឌទី៥ នៃរដ្ឋធម្មនុញ្ញ មាត្រា៣៥០ និងមាត្រា៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌដោយក្តីអនុគ្រោះ។

២៧.តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំតបថា: ដោយផ្អែកតាមសេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] XING GUI ឃើញថាមេធាវីបានចែកជនរងគ្រោះជា ៣ ប្រភេទ រួមមានអ្នកស្លាប់, អ្នករបួស រួមជាមួយ នឹងជនរងគ្រោះដែលនៅជុំវិញអគារដែលរលំបាក់ ហេតុនេះបញ្ញត្តិមាត្រា៤១៤ សំដៅទៅលើជនរងគ្រោះប្រភេទទី៣ នេះហើយ។

២៨.លោក [redacted] **ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ** [redacted] XING GUI បានធ្វើសេចក្តីសន្និដ្ឋានការពារតបថា: បទល្មើសដែលចែងតាមមាត្រា ៤១៤ ជាបទល្មើសដែលមានចង្អុល ដោយមាត្រា៤១៣ ហើយមាត្រា ៤១៣ បញ្ជាក់ទៅមាត្រា៤១៤ វិញ សំដៅទៅធាតុចេតនា។

២៩.តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំបន្ថែមថា: នៅក្នុងអង្គហេតុនេះឃើញថា មុនពេលកើតហេតុម្ចាស់យានដ្ឋានអរុណរះបានប្តឹងទៅអាជ្ញាធរមានសមត្ថកិច្ចចំនួន ០២ ដង ហេតុនេះ តំណាងអយ្យការជឿថា កូនក្តីរបស់លោកមេធាវីបានដឹងចេតនារបស់គាត់បញ្ជាក់នៅត្រង់កន្លែងនឹង។

៣0.លោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] KUN និងឈ្មោះ [redacted] YAPING បានធ្វើសេចក្តីសន្និដ្ឋានការពារក្ងនក្តីខ្លួនជាលាយលក្ខណ៍អក្សរថា: ក្ងនក្តីខ្លួនឈ្មោះ [redacted] KUN ត្រូវបានតំណាងអយ្យការចោទប្រកាន់ពីបទ មនុស្សឃាតដោយអចេតនា បទ បង្កវបូសស្នាមដោយអចេតនា និងបទ ធ្វើឲ្យខ្ងចខាតដោយចេតនាមានស្ថានទម្ងន់ទោស ដោយសារការបង្កវបូសដល់អ្នកដទៃ តាមបញ្ញត្តិមាត្រា ២0៧ មាត្រា២៣៦ មាត្រា៤១៤ នៃក្រមព្រហ្មទណ្ឌ និងឈ្មោះ [redacted] YAPING ត្រូវបានតំណាងអយ្យការចោទប្រកាន់ពីបទ សមគំនិតក្នុងអំពើមនុស្សឃាតដោយអចេតនា បទ សមគំនិតក្នុងអំពើបង្កវបូសស្នាមដោយអចេតនា និងបទ សមគំនិតក្នុងអំពើធ្វើឲ្យខ្ងចខាតដោយចេតនាមានស្ថានទម្ងន់ទោសដោយសារការបង្កវបូសដល់អ្នកដទៃ តាមបញ្ញត្តិមាត្រា ២៩ មាត្រា ២0៧ មាត្រា២៣៦ មាត្រា៤១៤ នៃក្រមព្រហ្មទណ្ឌ។ ក្រោយពីបានពិនិត្យសិក្សាសំណុំរឿង ក៍ដូចជាបានស្តាប់ចម្លើយជនជាប់ចោទ ចម្លើយសាក្សី និងភស្តុតាងទាំងអស់នៅក្នុងសំណុំរឿង ឃើញថា ក្ងនក្តីខ្លួនពុំបានប្រព្រឹត្តអំពើដូចការចោទប្រកាន់របស់តំណាងអយ្យការឡើយ។ ក្ងនក្តីខ្លួនគ្មានបច្ចេកទេសនៅក្នុងការសាងសង់នោះទេ ក្រោយពេលជួលដីបានពីឈ្មោះ [redacted] ហ៊ុយ ក្ងនក្តីខ្លួនបានចុះកិច្ចសន្យាមៅការសាងសង់ទាំងកម្លាំង ពលកម្ម និងសម្ភារៈជាមួយឈ្មោះ [redacted] XING GUI។ យោងតាមខ្លឹមសារនៃកិច្ចសន្យាមៅការសាងសង់ នៅក្នុងប្រការ៦ ចំណុចទី៣ បានចែងយ៉ាងច្បាស់អំពីទម្រង់នៃការមៅការ ទាំងកម្លាំងពលកម្ម ទាំងសម្ភារៈ ដោយភាគីលោក [redacted] XING GUI ផ្តល់ជូនទូវាល់ប្លង់សាងសង់ទាំងអស់ ក្នុងនោះរួមមាន ការសាងសង់គ្រឹះ ការសង់គ្រឿងបង្គុំដែក ការចាក់ប្លង់សេ។ល។ យោងតាមប្រការ២ ទឹកប្រាក់ដែលមៅការសរុបចំនួន ៦៧៧.000 (ហុកសិបប្រាំពីរម៉ឺនប្រាំពីរពាន់) ដុល្លារអាមេរិក ដែលទឹកប្រាក់នេះក្ងនក្តីខ្លួនឈ្មោះ [redacted] KUN បានបង់ចំនួន ៣0 % ទៅឲ្យលោក [redacted] XING GUI ស្មើនឹង ២0៣.900 (ម្ភៃម៉ឺនបីពាន់មួយរយ) ដុល្លារអាមេរិក នៅថ្ងៃចុះកិច្ចសន្យា។ យោងតាមប្រការ៥ អំពីគុណភាពនៃគម្រោងបានចែងឲ្យលោក [redacted] ING GUI ត្រូវធ្វើការសាងសង់ដោយម៉ឺងម៉ាត់ ម៉ត់ចត់ទៅតាមប្លង់សាងសង់ ឯកសារ ស្តង់ដា បទដ្ឋានសាងសង់សំណង់ និងមានគុណភាព នេះស្តែងឲ្យឃើញអំពីកាតព្វកិច្ចរបស់លោក [redacted] XING GUI នៅក្នុងការសាងសង់ ដែលត្រូវប្រុងប្រយ័ត្នធ្វើយ៉ាងណាឲ្យសំណង់មានគុណភាពល្អ។ កិច្ចសន្យាមៅការសាងសង់ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២0១៩ រវាងលោក [redacted] KUN និងលោក [redacted] XING GUI ត្រង់: ចំណុច៤ នៃកិច្ចព្រមព្រៀងលោក [redacted] XING GUI មៅការទាំងកម្លាំងពលកម្ម និងទាំងសម្ភារៈសម្រាប់សាងសង់ទាំងអស់។ ចំណុចទី៩ នៃកិច្ចព្រមព្រៀងនេះ សំណង់ដែលសាងសង់ធានាគុណភាពសម្រាប់គ្រឿងបង្គុំទាំងមូលពីជាន់ទី១ ដល់ ជាន់ទី៧ រយៈពេល១0 ឆ្នាំ រាល់បញ្ហាដូចជា ការប្រេះជញ្ជាំង ការលេចទឹកតាមបន្ទប់ និងបញ្ហាគុណភាពផ្សេងទៀតលោក [redacted] XING GUI ជាអ្នកទទួលខុសត្រូវ។ យោងតាមចម្លើយក្ងនក្តី ខ្លួនឈ្មោះ [redacted] KUN នៅគ្រប់ដំណាក់កាល និងចម្លើយរបស់លោក [redacted] XING GUI នៅដំណាក់កាលសមត្ថកិច្ចបង្ហាញដូចគ្នាថា ប្រាក់ដែលលោក [redacted] KUN ប្រគល់ទៅឲ្យលោក [redacted] XING GUI អស់ប្រមាណ ៦៣9.000 (ហុកសិបបីម៉ឺនមួយពាន់) ដុល្លារអាមេរិក ហើយលោក [redacted] XING GUI ក៍បានទទួលប្រាក់ចំនួននេះដែរ។ យោងតាមចម្លើយរបស់លោក [redacted] XING GUI បានឆ្លើយនៅចំពោះមុខអង្គសវនាការថា ក្នុងកិច្ចការងារសាងសង់នេះ ខ្លួនមានសញ្ញាបត្រវិស្វករ ចំពោះអគារដែលសាងសង់នេះ ប្រើដែក៥៨ តោន

បេតុង ៥៥ គីប ក្នុង មួយជាន់ ទម្ងន់សរុបក្នុង១ ជាន់ ស្មើនឹង ១៥០ តោន ចំពោះសសរដែកមួយដើមអាចទ្រទម្ងន់បាន ១00 តោន ហើយត្រូវប្រើដែកចំនួន ២0 ដើម ក្នុង១ ជាន់។ លោក [redacted] XING GUI បានបញ្ជាក់ទៀតថា តំណភ្ជាប់ពីដែកមួយទៅដែកមួយត្រូវចាប់ប្លុងចំនួន៦ គ្រាប់តែនៅជាន់ខាងលើ កន្លែងខ្លះចាប់បានតែ៤ គ្រាប់ទេ ដោយសារតែគាត់ធ្វេសប្រហែស គ្រប់គ្រងមិនបានដិតដល់ ចំពោះគ្រោងដែកនោះគាត់បានបញ្ជាក់ថា អាចធ្វើបានរហូតដល់ ៩ ជាន់ និងធានារយៈពេល ១0 ឆ្នាំ ចំពោះអគារនោះ។ អគារដែលទ្រេតចំនួន ២ តឹក នោះ គាត់បានធានាថាមិនមានបញ្ហានោះទេ កុំឲ្យតែលើសពីកន្លះម៉ែត្រ។ យោងតាមចម្លើយសាក្សីឈ្មោះ [redacted] សុវន្ត បានបញ្ជាក់ថា តាមលទ្ធផលនៃការគណនាបង្ហាញថា ទំហំមុខកាត់ធាតុនៃគ្រឿងបង្គុំ (ធ្នឹម ធ្នឹមរងសសរ) ជាក់ស្តែងមិនគ្រប់គ្រាន់ជាមួយនឹងការគណនាធាតុផ្សំត្រង់ដំណធ្នឹម និងសសរមិនមានលទ្ធភាពទ្រទ្រង់ និងមានកំហុសបច្ចេកទេសនៃការសាងសង់ដូចជាប្លុងចាប់ខ្វះ និងខុសស្តង់ដា។ តាមចម្លើយសាក្សីឈ្មោះ [redacted] សុវិន បំភ្លឺនៅក្នុងអង្គសវនាការថា មុនអគាររលំរំលងមួយថ្ងៃ ខ្លួនបានមកធ្វើការជាអ្នកបោសសំអាត គាត់បញ្ជាក់ថារាល់ពេលដែលខ្លួនបើកប្រាក់ខែ បើកពីឈ្មោះ [redacted] XING GUI នេះបង្ហាញឲ្យឃើញថា តាំងពីចាប់ផ្តើមសាងសង់រហូតមកដល់អគាររលំ ឈ្មោះ [redacted] XING GUI នៅតែជាអ្នកមៅការ។ ជារួមមកអគារនេះស្ថិតក្រោមការទទួលខុសត្រូវរបស់លោក [redacted] XING GUI ជាពិសេសគឺបច្ចេកទេសនៅក្នុងការសាងសង់ការផ្សារភ្ជាប់ដំណ ការចាប់ប្លុង លោក [redacted] XING GUI គឺជាបុគ្គលដែលមៅការ ហើយត្រូវមានភាតព្វកិច្ចប្រុងប្រយ័ត្ននៅលើការងារសាងសង់របស់ខ្លួនជាពិសេសគឺបង្គុំដែក។ កូនក្តីខ្លួនឈ្មោះ [redacted] KUN ជាជនរងគ្រោះម្នាក់ដែលខាតបង់នូវថវិការជាច្រើនឲ្យទៅលោក [redacted] XING GUI ក្នុងកិច្ចការមៅការសាងសង់ ដោយសង្ឃឹមថានឹងទទួលបានអគារមួយដើម្បីដំណើរការអាជីវកម្មរបស់ខ្លួននៅថ្ងៃអនាគត តែផ្ទុយមកវិញអគារមិនទាន់បានសង់រួចរាល់ផង មិនទាន់បានប្រគល់ឲ្យខ្លួនផង ត្រូវបានរលំបាត់ទៅហើយ។ រីឯកូនក្តីខ្លួនឈ្មោះ [redacted] YAPING វិញគ្រាន់តែជាចុងភៅមួយរូប ជួយដាំបាយ ធ្វើម្ហូបឲ្យប្អូនប្រុសរបស់ខ្លួន ហើយការងារមួយចំនួនកូនក្តីខ្លួនធ្វើក្នុងគោលបំណងជាអ្នកជួយយកអាសារបងប្អូនតែប៉ុណ្ណោះ គ្មានប្រយោជន៍ណាមួយពិសំណង់អគារ និងមិនមែនជាមេការអ្វីនោះទេ។ ផ្អែកតាមអង្គហេតុ អង្គច្បាប់ និងការលើកឡើងខាងលើនេះ ខ្លួនស្នើសុំឲ្យក្រុមប្រឹក្សាជំនុំជម្រះមេត្តាពិចារណាឲ្យកូនក្តីខ្លួនឈ្មោះ [redacted] KUN និងឈ្មោះ [redacted] YAPING រួចផុតពីបទចោទ និងដោះលែងកូនក្តីខ្លួនឲ្យមានសេរីភាពវិញដោយក្តីអនុគ្រោះ។

៣១.ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ ក៏ដូចជាសេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ និងមេធាវីតំណាងដោយអាណត្តិឲ្យដើមបណ្តឹងរដ្ឋប្បវេណី តាមអង្គហេតុ ឃើញថា អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] KUN, ឈ្មោះ [redacted] XINGGUI, ឈ្មោះ [redacted] YAPING និងឈ្មោះ [redacted] YU ពុំមានចេតនាធ្វើឲ្យខូចខាតទ្រព្យសម្បត្តិរបស់អ្នកដទៃ ក៏ដូចជាបង្កឲ្យមានព្យសនកម្មដល់អ្នកដទៃ ពុំមានធាតុផ្សំគ្រប់គ្រាន់ពិបទធ្វើឲ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោសដោយសារការបង្កវបូសដល់អ្នកដទៃ តុលាការគប្បីឲ្យឈ្មោះ [redacted] KUN. ឈ្មោះ [redacted] XING GUI រួចខ្លួនពីបទចោទ ពីបទ ធ្វើឲ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោសដោយសារការបង្កវបូសដល់អ្នកដទៃ និងឈ្មោះ [redacted] YAPING និងឈ្មោះ [redacted] YU រួចខ្លួនពីបទចោទ ពីបទ សមគំនិតក្នុងអំពើធ្វើឲ្យខូចខាតដោយចេតនាមាន

ស្ថានទម្ងន់ទោសដោយសារការបង្ករបួសដល់អ្នកដទៃ ប្រព្រឹត្តនៅ ក្រុមទី១៥ ភូមិ៣ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្ត ព្រះសីហនុ កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៩ តាមមាត្រា៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៣២.ជនជាប់ចោទឈ្មោះ [redacted] THI THUY HAO ហៅ អាហ័រ ភេទស្រី ជនជាតិវៀតណាម តាមអង្គហេតុនៃការចោទប្រកាន់ ឈ្មោះនេះពីបទ សមគំនិតក្នុងអំពើធ្វើឲ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោសដោយសារការបង្ករបួសដល់អ្នកដទៃ ឃើញថាពុំសមហេតុផលឡើយ ជាក់ស្តែងជនជាប់ចោទឈ្មោះ [redacted] THI THUY HAO ហៅ អាហ័រ ជាអ្នកចាត់ចែង និងផ្គត់ផ្គង់សម្ភារៈ, ជាអ្នករត់ការសាងសង់ ជាម្ចាស់ភាគហ៊ុនរួមគ្នាក្នុងការសាងសង់អគារ ជាមួយឈ្មោះ [redacted] XING GUI ជនជាប់ចោទរូបនេះជាសហចារី ដែលរួមប្រព្រឹត្តបទល្មើសជាមួយជនជាប់ចោទឈ្មោះ [redacted] KUN និងជនជាប់ចោទឈ្មោះ [redacted] XING GUI ដែរ។

៣៣.ជនជាប់ចោទឈ្មោះ [redacted] ប៊ុនធឿន ភេទប្រុស (មានសាវតារជាតិខាងលើ) ត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យព័បទ **សមគំនិតក្នុងអំពើមនុស្សឃាតដោយអចេតនា, បទ សមគំនិតក្នុងអំពើបង្កឲ្យមានរបួសស្នាមដោយអចេតនា** និងបទ **សមគំនិតក្នុងអំពើធ្វើឲ្យខូចខាតមានស្ថានទម្ងន់ទោសដោយសារការបង្ករបួសដល់អ្នកដទៃ** ប្រព្រឹត្តនៅ ក្រុមទី ១៥ ភូមិ៣ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៩ បទល្មើសដែលមានចែង និងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **២៩** មាត្រា **២០៧** មាត្រា **២៣៦** និងមាត្រា **៤១៥** នៃក្រមព្រហ្មទណ្ឌ។ តាមអង្គហេតុខាងលើបង្ហាញឲ្យឃើញថា ឈ្មោះ [redacted] ប៊ុនធឿន ជាកម្មករជាងដែក ពុំបានជួយសម្រួលដល់ជនជាប់ចោទឈ្មោះ [redacted] KUN និងឈ្មោះ [redacted] XING GUI ដោយចេតនានោះឡើយ។ ដូចនេះអំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] ប៊ុនធឿន ពុំចាត់ចូលជាបទសមគំនិតនោះឡើយ។ ផ្អែកតាមអង្គហេតុខាងលើ តុលាការគប្បីឲ្យឈ្មោះ [redacted] ប៊ុនធឿន រួចខ្លួនពីបទ **សមគំនិតក្នុងអំពើមនុស្សឃាតដោយអចេតនា, បទ សមគំនិតក្នុងអំពើបង្កឲ្យមានរបួសស្នាមដោយអចេតនា** និងបទ **សមគំនិតក្នុងអំពើធ្វើឲ្យខូចខាតមានស្ថានទម្ងន់ទោសដោយសារការបង្ករបួសដល់អ្នកដទៃ** តាមមាត្រា៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៣៤.ជនជាប់ចោទឈ្មោះ [redacted] YU ភេទប្រុស និងឈ្មោះ [redacted] YAPING ភេទស្រី ត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យព័បទ **សមគំនិតក្នុងអំពើមនុស្សឃាតដោយអចេតនា, បទ សមគំនិតក្នុងអំពើបង្កឲ្យមានរបួសស្នាមដោយអចេតនា** និងបទ **សមគំនិតក្នុងអំពើធ្វើឲ្យខូចខាតមានស្ថានទម្ងន់ទោសដោយសារការបង្ករបួសដល់អ្នកដទៃ** ប្រព្រឹត្តនៅ ក្រុមទី១៥ ភូមិ៣ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៩ បទល្មើសដែលមានចែង និងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **២៩** មាត្រា **២០៧** មាត្រា **២៣៦** និងមាត្រា **៤១៥** នៃក្រមព្រហ្មទណ្ឌ។ តាមអង្គហេតុខាងលើបង្ហាញឲ្យឃើញថាឈ្មោះ [redacted] YAPING ជាអ្នកមើលការខុសត្រូវលើការដ្ឋានសាងសង់ពេលដែលឈ្មោះ [redacted] KUN មិនមានវត្តមានម្តងម្កាលនៅការដ្ឋាន ចំណែកឯជនជាប់ចោទឈ្មោះ [redacted] YU ជាជាងបូក និងលាបថ្នាំ បានធ្វេសប្រហែសខ្ជិខ្ជា បានរួមចំណែកធ្វើឲ្យអគាររលំបាក់ជាមួយ ជនជាប់ចោទឈ្មោះ CHENG KUN និងឈ្មោះ [redacted] XING GUI ដូចនេះជនជាប់ចោទឈ្មោះ [redacted] YU ជាសហចារី។ អំពើប្រព្រឹត្តរបស់ជនជាប់ចោទទាំងពីរនាក់ចាត់ចូលជាបទ **មនុស្សឃាតដោយអចេតនា, បទ បង្កឲ្យមាន**

របួសស្នាមដោយអចេតនា បទល្មើសដែលមានចែង និងឲ្យផ្តន្ទាទោសតាមមត្រា២០៧ និងមាត្រា ២៣៦ នៃក្រមព្រហ្មទណ្ឌ។

៣៥.កំណត់ហេតុ និងឯកសារនានា ធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធម៌។

៣៦.ជនជាប់ចោទឈ្មោះ [redacted] KUN. [redacted] XING GUI. [redacted] THI THUY HAO ហៅ អាហ័រ, ឈ្មោះ [redacted] YAPING និងឈ្មោះ [redacted] YU ជានីតិជន មានសតិបញ្ញាដឹងខុសត្រូវ មានសមត្ថភាព និងការយល់ដឹងគ្រប់គ្រាន់ (គ្មានវិបល្លាសស្មារតី) ក្នុងការទទួលខុសត្រូវនូវអំពើប្រព្រឹត្តរបស់ខ្លួន។

៣៧.អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] KUN, [redacted] XING GUI, [redacted] THI THUY HAO ហៅ **អាហ័រ** ឈ្មោះ[redacted] YAPING និងឈ្មោះ[redacted] YU បានធ្វើឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ របៀបរៀបរយរបស់សង្គម និងរូបរាងកាយ ព្រមទាំងអាយុជីវិតរបស់អ្នកដទៃ ហើយអំពើនេះកំណត់ថាជាបទល្មើសព្រហ្មទណ្ឌដែលមានចែង និងឲ្យផ្តន្ទាទោសតាមមត្រា ២០៧ និងមាត្រា២៣៦ នៃក្រម ព្រហ្មទណ្ឌ។

៣៨.វត្ថុចាប់យកមាន:

ក.ឯកសារផ្សេងៗមួយចំនួនធំ

ត្រូវប្រគល់ឲ្យម្ចាស់ដើមវិញ តាមមាត្រា ៣៥៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៣៩.សំដីចុងក្រោយរបស់ជនជាប់ចោទ:

ក.ឈ្មោះ [redacted] KUN ថា: សុំឲ្យតុលាការលើកលែងទោសឲ្យខ្លួនផង។

ខ.ឈ្មោះ [redacted] XING GUI ថា: សុំឲ្យតុលាការសម្រាលទោសឲ្យខ្លួនផង។

គ.ឈ្មោះ [redacted] PING ថា: ខ្លួនសុំត្រឡប់ទៅផ្ទះវិញ។

ឃ.ឈ្មោះ [redacted] YU ថា: សុំឲ្យតុលាការលើកលែងទោសឲ្យខ្លួនផង ខ្លួនគ្រាន់តែជាជាងលាបថ្នាំម្នាក់ ខ្លួនមិនដឹងអ្វីទេ។

៤០.មានពិរុទ្ធភាព និងភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] **KUN** ភេទប្រុស អាយុ៣៩ ឆ្នាំ ជនជាតិចិន ឈ្មោះ [redacted] **XING GUI** ភេទប្រុស អាយុ៤៨ ឆ្នាំ ជនជាតិចិន, ឈ្មោះ [redacted] **THI THUY HAO** ហៅ **អាហ័រ** ភេទស្រី កើតថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៧៧ ជនជាតិវៀតណាម. ឈ្មោះ XIE YAPING ភេទស្រី កើតថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ១៩៧៣ និងឈ្មោះ GAO YU ភេទប្រុស ថ្ងៃទី២០ ខែមេសា ឆ្នាំ១៩៩០ (សាវតារជាតិខាងលើ) ពីបទ: **មនុស្សឃាតដោយអចេតនា និងបទ បង្កឲ្យមានរបួសស្នាមដោយអចេតនា** ប្រព្រឹត្តនៅ ក្រុមទី ១៥ ភូមិ៣ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពី ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៩ បទល្មើសដែលមានចែង និងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **២០៧** និងមាត្រា **២៣៦** នៃក្រមព្រហ្មទណ្ឌ។

៤១.ពុំមានពិរុទ្ធភាព និងភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] **ប៊ុនធឿន** ហៅ **ធឿន** ភេទប្រុស កើតថ្ងៃទី០៩ ខែសីហា ឆ្នាំ១៩៧៩ (សាវតារជាតិខាងលើ) ពីបទ: **សមគំនិតក្នុងអំពើមនុស្សឃាតដោយអចេតនា, បទ សមគំនិតក្នុងអំពើបង្កឲ្យមានរបួសស្នាមដោយអចេតនា** និងបទ **សមគំនិតក្នុងអំពើធ្វើឲ្យខូចខាតមានស្ថានទម្ងន់ទោសដោយសារការបង្ករបួសដល់អ្នកដទៃ** ប្រព្រឹត្តនៅ ក្រុមទី១៥ ភូមិ៣ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្ត

Scanned with CamScanner

ព្រះសីហនុ កាលពី ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៩ តុលាការគប្បីឲ្យជនជាប់ចោទរូបនេះ រួចខ្លួនពីបទចោទប្រកាន់តាមមាត្រា៣៥០ នៃក្រមនីតិវិធី ព្រហ្មទណ្ឌ។

៤២.ជនជាប់ចោទឈ្មោះ [redacted] **THI THUY HAO** ហៅ **អាហ័រ** ភេទស្រី កើតថ្ងៃទី០៩ ខែតុលា ឆ្នាំ**១៩៧៧** ជនជាតិវៀតណាម ត្រូវបានចៅក្រមស៊ើបសួរនៃ សាលាដំបូងខេត្ត ព្រះសីហនុ បង្គាប់ឲ្យចាប់ខ្លួនតាមដីកាបង្គាប់ឲ្យចាប់ខ្លួនលេខ **៤៧/១៩** ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ ២០១៩ និងឈ្មោះ [redacted] **ប៊ុនធឿន ហៅ ធឿន** ត្រូវបានចៅក្រមស៊ើបសួរនៃ សាលាដំបូងខេត្ត ព្រះសីហនុបង្គាប់ឲ្យចាប់ខ្លួនតាមដីកាបង្គាប់ឲ្យចាប់ខ្លួនលេខ **៤៨/១៩** ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០១៩ ដីកាបង្គាប់ឲ្យចាប់ខ្លួនខាងលើត្រូវអស់អានុភាពអនុវត្តតាមអំណាចសាលក្រមព្រហ្មទណ្ឌ នេះ។

៤៣.ជនរងគ្រោះ និងសិទ្ធិវន្តរបស់ជនរងគ្រោះដែលបានរងរបួស និងទទួលមរណៈភាព ដែលបណ្តាលមកពីការបាក់រលំអគារកម្ពស់ ០៧ ជាន់ ស្ថិតនៅ ក្រុមទី១៥ ភូមិ៣ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ បានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅចំពោះមុខចៅក្រមស៊ើបសួរ ដើម្បីទាមទារសំណងពីជនជាប់ចោទឈ្មោះ [redacted] **KUN** ភេទប្រុស អាយុ៣៩ ឆ្នាំ ជនជាតិចិន និងឈ្មោះ [redacted] **XING GUI** ភេទប្រុស អាយុ៤៨ ឆ្នាំ ជនជាតិចិន និងឈ្មោះ [redacted] **THI THUY HAO** ហៅ **អាហ័រ** ភេទស្រី កើតថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៧៧ ជនជាតិវៀតណាម ឈ្មោះ [redacted] **YU** ភេទប្រុស អាយុ២៩ ឆ្នាំ ជនជាតិចិន, ឈ្មោះ [redacted] YAPING ភេទស្រី កើតថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ១៩៧៣ និងឈ្មោះ [redacted] **ប៊ុនធឿន** ហៅ **ធឿន** ភេទប្រុស កើតថ្ងៃទី០៩ ខែសីហា ឆ្នាំ**១៩៧៩** តុលាការគប្បីពិចារណា អំពីសំណងនេះឲ្យធួនល្មមនឹងព្យសនកម្មដែលជន រងគ្រោះទទួលរង តាមមាត្រា**១៣៧**, មាត្រា **១៤** និងមាត្រា**១៦** នៃក្រមនិតិវិធីព្រហ្មទណ្ឌ។

៤៤.ជនជាប់ចោទឈ្មោះ [redacted] **THI THUY HAO** ហៅ **អាហ័រ** ភេទស្រី កើតថ្ងៃទី០៩ ខែតុលា ឆ្នាំ**១៩៧៧** ជនជាតិវៀតណាម បានរត់គេចខ្លួន បន្ទាប់ពីប្រព្រឹត្តបទល្មើស តុលាការបង្គាប់ឲ្យចាប់ខ្លួនឈ្មោះនេះមកអនុវត្តទោស តាមមាត្រា៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៤៥.ជនជាប់ចោទ [redacted] **KUN** ភេទប្រុស អាយុ៣៩ ឆ្នាំ ជនជាតិចិន, ឈ្មោះ [redacted] **XING GUI** ភេទប្រុស អាយុ៤៨ ឆ្នាំ ជនជាតិចិន និងឈ្មោះ [redacted] **THI THUY HAO** ហៅ **អាហ័រ** ភេទស្រី កើតថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៧៧ ជនជាតិវៀតណាម ត្រូវទទួលសងការខូចខាតដោយសាមគ្គិដល់ជនរងគ្រោះ ដែលរងរបួស, ទទួលមរណភាព និងអ្នកទទួលរងការខូចខាតដោយសារអំពើប្រព្រឹត្តរបស់ខ្លួនខាងលើ តាមមាត្រា៣៥៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៤៦.ជនជាប់ចោទឈ្មោះ [redacted] KUN និងឈ្មោះ [redacted] XINGGUI ជាអ្នកទទួលខុសត្រូវខ្ពស់នូវអំពើប្រព្រឹត្តរបស់ខ្លួន ដូចនេះតុលាការគប្បីផ្តន្ទាទោសដល់កម្រិតអតិប្បរមានៃទោស តាមមាត្រា១៣៧ នៃក្រមព្រហ្មទណ្ឌ។

៤៧.ជនជាប់ចោទទាំងប្រាំ នាក់ ត្រូវបានតុលាការបង្គាប់ឲ្យសងសំណងដល់ដើមបណ្តឹងរដ្ឋប្បវេណីដែលមានទំហំទឹកប្រាក់ច្រើន ដូចនេះតុលាការគប្បីផ្តន្ទាទោសជនជាប់ចោទខាងលើដោយដាក់ពន្ធនាគារតែមួយមុខ រីឯទោសពិន័យជាប្រាក់ពុំគប្បីអនុវត្តលើជនជាប់ចោទខាងលើឡើយ តាមមាត្រា៩៧ នៃក្រមព្រហ្មទណ្ឌ។

៤៨.ដើម្បីធានាសំណងដល់ដើមបណ្តឹងរដ្ឋប្បវេណី ដែលបានប្តឹងទាមទារសំណងពីជនជាប់ចោទទាំងប្រាំ នាក់ ខាងលើ ជនជាប់ចោទជាជនបរទេស អ្នកទាំងនេះនឹងអាចវិលត្រឡប់ទៅប្រទេសកំណើតខ្លួនវិញ បន្ទាប់ពីអនុវត្តទណ្ឌកម្មចប់ ជាហេតុនាំឲ្យប៉ះពាល់ដល់ផលប្រយោជន៍ធ្ងន់ធ្ងររបស់ជនរងគ្រោះ ដូចនេះ តុលាការគប្បីហាមឃាត់ជនជាប់ចោទទាំងប្រាំ នាក់ នេះ មិនឲ្យចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជាក្នុងរយៈពេលប្រាំ ឆ្នាំ តាមមាត្រា៦០ នៃក្រមព្រហ្មទណ្ឌ។

ហេតុដូច្នេះ

ខណិច្ឆ័យសេចក្តី

១-**ឲ្យឈ្មោះ [redacted] ប៊ុនធឿន** ហៅ **ធឿន** ភេទប្រុស កើតថ្ងៃទី០៩ ខែសីហា ឆ្នាំ១៩៧៩ ជនជាតិខ្មែរ (សាវតារជាតិខាងលើ) **រួចខ្លួនពីបទចោទ** ពីបទ **សមគំនិតក្នុងអំពើមនុស្សឃាតដោយអចេតនា, បទ សមគំនិតក្នុងអំពើបង្កឲ្យមានរបួសស្នាមដោយអចេតនា** និងបទ **សមគំនិតក្នុងអំពើធ្វើឲ្យខូចខាតមានស្ថានទម្ងន់ទោសដោយសារការបង្ករបួសដល់អ្នកដទៃ** ប្រព្រឹត្តនៅក្រមទី ១៥ ភូមិ៣ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្ត ព្រះសីហនុ កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៩ តាមមាត្រា **៣៥០** នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២-ប្តូរបទចោទប្រកាន់លើឈ្មោះ [redacted] THI THUY HAO ហៅ **អាហ័រ** ភេទស្រី កើតថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៧៧ ជនជាតិវៀតណាម ពីបទ **សមគំនិតក្នុងអំពើមនុស្សឃាតដោយអចេតនា និងបទសមគំនិតក្នុងអំពើបង្កឲ្យមានរបួសស្នាមដោយអចេតនា តាមបញ្ញត្តិមាត្រា ២៩ មាត្រា២០៧ និងមាត្រា២៣៦ នៃក្រមព្រហ្មទណ្ឌ** ប្រព្រឹត្តនៅ ក្រមទី ១៥ ភូមិ៣ សង្កាត់ លេខ៤ ក្រុងព្រះសីហនុ ខេត្ត ព្រះសីហនុ កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៩ **ទៅជាបទ: មនុស្សឃាតដោយអចេតនា និងបទ បង្កឲ្យមានរបួសស្នាមដោយអចេតនា តាមបញ្ញត្តិមាត្រា២០៧ និងមាត្រា ២៣៦ វិញ។**

៣-ឲ្យ

ក.ឈ្មោះ [redacted] KUN ភេទប្រុស អាយុ៣៩ ឆ្នាំ ជនជាតិចិន (សាវតារជាតិខាងលើ)

ខ.ឈ្មោះ [redacted] **XING GUI** ភេទប្រុស អាយុ៤៨ ឆ្នាំ ជនជាតិចិន (សាវតារជាតិខាងលើ)

រួចខ្លួនពីបទចោទ ពីបទ **ធ្វើឲ្យខូចខាតមានស្ថានទម្ងន់ទោសដោយសារការបង្ករបួសដល់អ្នកដទៃ**

គ.ឈ្មោះ [redacted] **THI THUY HAO** ហៅ **អាហ័រ** ភេទស្រី កើតថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៧៧ ជនជាតិវៀតណាម (សាវតារជាតិ ខាងលើ)

ឃ.ឈ្មោះ [redacted] **YAPING** ភេទស្រី អាយុ៤៣ ឆ្នាំ ជនជាតិចិន (សាវតារជាតិ ខាងលើ)

ង.ឈ្មោះ [redacted] **YU** ភេទ ប្រុស អាយុ២៩ ឆ្នាំ ជនជាតិចិន (សាវតារជាតិខាងលើ)

រួចខ្លួនពីបទចោទ ពីបទ **សមគំនិតក្នុងអំពើធ្វើឲ្យខូចខាតមានស្ថានទម្ងន់ទោសដោយសារការបង្ករបួសដល់អ្នកដទៃ**

ប្រព្រឹត្តនៅ ក្រមទី ១៥ ភូមិ៣ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្ត ព្រះសីហនុ កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៩ តាមមាត្រា **៣៥០** នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៤-ផ្តន្ទាទោសជនជាប់ចោទ:

ក.ឈ្មោះ [redacted] **KUN** ភេទប្រុស អាយុ៣៩ ឆ្នាំ ជនជាតិចិន (មានសាវតារជាតិខាងលើ) **ដាក់ពន្ធនាគារ**កំណត់ ០៣ (បី) ឆ្នាំ

ខ.ឈ្មោះ [redacted] **XING GUI** ភេទប្រុស អាយុ៤៨ ឆ្នាំ ជនជាតិចិន (មានសាវតារជាតិខាងលើ) **ដាក់ពន្ធនាគារ**កំណត់ ០៣ (បី) ឆ្នាំ

គ.ឈ្មោះ [redacted] **THI THUY HAO** ហៅ **អាហ័រ** ភេទស្រី កើតថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៧៧ ជនជាតិវៀតណាម (មានសាវតារជាតិខាងលើ) **ដាក់ពន្ធនាគារ**កំណត់ ០៣ (បី) ឆ្នាំ

ឃ.ឈ្មោះ: ឈ្មោះ: [redacted] **YAPING** ភេទស្រី អាយុ៤៣ ឆ្នាំ ជនជាតិចិន (មានសាវតារជាតិខាងលើ) **ដាក់ពន្ធនាគារ**កំណត់ ០២ (ពី) ឆ្នាំ ០៦ (ប្រាំមួយ) ខែ

ង.ឈ្មោះ: [redacted] **YU** ភេទ ប្រុស អាយុ២៩ ឆ្នាំ ជនជាតិចិន (មានសាវតារជាតិខាងលើ) **ដាក់ពន្ធនាគារ**កំណត់ ០២ (ពិ) ឆ្នាំ ០៦ (ប្រាំមួយ) ខែ

ពីបទ: **មនុស្សឃាតដោយអចេតនា** និងបទ **បង្កឲ្យមានរបួសស្នាមដោយអចេតនា** ប្រព្រឹត្តនៅ ក្រុមទី១៥ ភូមិ៣ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពី ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៩ បទល្មើសដែលមានចែង និងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **២០៧**, មាត្រា **២៣៦** និង**៥៧** នៃក្រមព្រហ្មទណ្ឌ។

៥-ដីកាបង្គាប់ឲ្យចាប់ខ្លួនលេខ **៥៧/១៩** ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ ២០១៩ លើឈ្មោះ [redacted] **THI THUY HAO** ហៅ **អាហ័រ** ភេទស្រី កើតថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៧៧ ជនជាតិវៀតណាម និងលេខ**៥៨/១៩** ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០១៩ លើឈ្មោះ សាត ប៊ុនធឿន ហៅ ធឿន ត្រូវអស់អានុភាពអនុវត្តតាមអំណាចសាលក្រមព្រហ្មទណ្ឌនេះ។

៦-**បង្គាប់ឱ្យចាប់ខ្លួន និងឃុំខ្លួន**ឈ្មោះ [redacted] **THI THUY HAO** ហៅ **អាហ័រ** ភេទស្រី កើតថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៧៧ ជនជាតិវៀតណាម មកអនុវត្តទោសនៅពន្ធនាគារខេត្តព្រះសីហនុ តាមអំណាចសាលក្រមព្រហ្មទណ្ឌនេះ តាមមាត្រា **៣៥៣** នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៧-**បង្គាប់ឲ្យជនជាប់ចោទឈ្មោះ** [redacted] **KUN, ឈ្មោះ** [redacted] **XING GUI និងឈ្មោះ** [redacted] **N THI THUY HAO ហៅ អាហ័រ, ឈ្មោះ** [redacted] **YU និងឈ្មោះ** [redacted] **YAPING រួមគ្នាដោយសាមគ្គីសងសំណងការខូចខាតទៅឲ្យដើមបណ្តឹងរដ្ឋប្បវេណីដូចខាងក្រោម:**

៧.១.ឈ្មោះ: សាប់ រិទ្ធិវុឌ្ឍ

ក.ថ្លៃខូចខាតសម្ភារៈ និងផ្ទះ: ចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិក

ខ.ថ្លៃខាតបង់ថ្លៃឈ្នួលផ្ទះ: ចំនួន ៧០.០០០ (ប្រាំពីម៉ឺន) ដុល្លារអាមេរិក

ការទាមទារលើសពីនេះត្រូវបដិសេធចោល។

៧.២.ឈ្មោះ [redacted] TOMOTAKA និងឈ្មោះ [redacted] YUKO

ក.ថ្លៃខូចខាតសម្ភារៈ: ចំនួន ៩០.០០០ (ប្រាំបួនម៉ឺន) ដុល្លារអាមេរិក

ខ.ថ្លៃការខាតបង់លើប្រាក់ចំណូលអាជីវកម្ម ៦០.០០០ (ប្រាំមួយម៉ឺន) ដុល្លារអាមេរិក

គ.សំណងជំងឺចិត្តចំនួន ២០.០០០ (ពីរម៉ឺន) ដុល្លារអាមេរិក

ការទាមទារលើសពីនេះត្រូវបដិសេធចោល។

៧.៣.ឈ្មោះ ឆៃ វ៉ាន់ដា

ក.សងថ្លៃរថយន្ត ម៉ាក LEXUS 470 មួយគ្រឿង ចំនួន ២០.០០០ (ពីរម៉ឺន) ដុល្លារអាមេរិក

Scanned with CamScanner

ខ.សងថ្លៃរថយន្តម៉ាក STAREX (ខូចខាតទាំងស្រុង) មួយគ្រឿង ចំនួន ១៥.000 (មួយម៉ុនប្រាំពាន់) ដុល្លារអាមេរិក

គ.សងថ្លៃរថយន្តម៉ាក MERCEDES S320 សេរីឆ្នាំ ១៩៩៨ ចំនួន ៥.000 (ប្រាំពាន់) ដុល្លារអាមេរិក

ឃ.សងថ្លៃរថយន្តម៉ាក HYUNDAI 1.5 TON ចំនួន ២.000 (ពីរពាន់) ដុល្លារអាមេរិក

ង.សងថ្លៃរថយន្តម៉ាក RANGROVER សេរីឆ្នាំ២00៥ (ខូចខាត ៤0%) ចំនួន ៣0.000 (បីម៉ឺន) ដុល្លារអាមេរិក

ច.សងថ្លៃខូចខាតរោងជាងចំនួន ២0.000 (ពីរម៉ឺន) ដុល្លារអាមេរិក

ឆ.សងជំងឺចិត្ត ចំនួន ១0.000 (មួយម៉ឺន) ដុល្លារអាមេរិក

ការទាមទារលើសពីនេះត្រូវបដិសេធចោល។

៨-**បង្គាប់ឲ្យជនជាប់ចោទ**ឈ្មោះ [redacted] KUN, ឈ្មោះ [redacted] XING GUI, ឈ្មោះ [redacted] THI THUY HAO ហៅ **អាហ័រ, ឈ្មោះ** [redacted] **YU និងឈ្មោះ** [redacted] **YAPING រួមគ្នាដោយសាមគ្គីសងសំណងថ្លៃព្យាបាលរបួសឲ្យទៅដើមបណ្តឹងរដ្ឋប្បវណីដែលរងរបួសដូចខាងក្រោម:**

៨.១.ឈ្មោះ [redacted] លក្ខ ចំនួន ២0.000.000 (ម្ភៃលាន) រៀល ការទាមទារលើសពីនេះត្រូវបដិសេធចោល។

៨.២.ឈ្មោះ [redacted] រ៉ន ហៅ ចន ពៅ ចំនួន ២0.000.000 (ម្ភៃលាន) រៀល ការទាមទារលើសពីនេះ ត្រូវបដិសេធចោល។

៨.៣.ឈ្មោះ [redacted] ប្រុស ចំនួន ២0.000.000 (ម្ភៃលាន) រៀល ការទាមទារលើសពីនេះត្រូវបដិសេធចោល។

៨.៤.ឈ្មោះ [redacted] សុន ចំនួន ២0.000.000 (ម្ភៃលាន) រៀល ការទាមទារលើសពីនេះត្រូវបដិសេធចោល។

៨.៥.ឈ្មោះ [redacted] អៀន ចំនួន ២0.000.000 (ម្ភៃលាន) រៀល ការទាមទារលើសពីនេះ ត្រូវបដិសេធចោល។

៨.៦.ឈ្មោះ [redacted] ចាន់ណេត ចំនួន ២0.000.000 (ម្ភៃលាន) រៀល ការទាមទារលើសពីនេះ ត្រូវបដិសេធចោល។

៨.៧.ឈ្មោះ [redacted] សុភាព ចំនួន ២0.000.000 (ម្ភៃលាន) រៀល ការទាមទារលើស ពីនេះត្រូវបដិសេធចោល។

៨.៨.ឈ្មោះ [redacted] សុផស់ ចំនួន ២0.000.000 (ម្ភៃលាន) រៀល ការទាមទារលើសពីនេះត្រូវបដិសេធចោល។

៨.៩.ឈ្មោះ [redacted] ដា ចំនួន ២0.000.000 (ម្ភៃលាន) រៀល ការទាមទារលើសពីនេះត្រូវបដិសេធចោល។

៨.១0.ឈ្មោះ [redacted] រស់ ចំនួន ២0.000.000 (ម្ភៃលាន) រៀល ការទាមទារលើសពីនេះត្រូវបដិសេធចោល។

៨.១១.ឈ្មោះ [redacted] ស៊ីថា ចំនួន ២0.000.000 (ម្ភៃលាន) រៀល ការទាមទារលើសពីនេះត្រូវបដិសេធចោល។

៨.១២.ឈ្មោះ [redacted] សុខន ចំនួន ២០.០០០.០០០ (ម្ភៃលាន) រៀល ការទាមទារលើសពីនេះ: ត្រូវបដិសេធចោល។

៨.១៣.ឈ្មោះ [redacted] នាង ចំនួន ២០.០០០.០០០ (ម្ភៃលាន) រៀល ការទាមទារលើសពីនេះ ត្រូវបដិសេធចោល។

៨.១៤.ឈ្មោះ [redacted] ចំរើន ចំនួន ២០.០០០.០០០ (ម្ភៃលាន) រៀល ការទាមទារលើសពីនេះ ត្រូវបដិសេធចោល។

៨.១៥.ឈ្មោះ [redacted] ប៊ុនធឿន ចំនួន ២០.០០០.០០០ (ម្ភៃលាន) រៀល ការទាមទារលើសពីនេះ: ត្រូវបដិសេធចោល។

៨.១៦.ឈ្មោះ [redacted] សែន ចំនួន ២០.០០០.០០០ (ម្ភៃលាន) រៀល ការទាមទារលើសពីនេះ ត្រូវបដិសេធចោល។

៨.១៧.ឈ្មោះ [redacted] សុខៀន ចំនួន ២០.០០០.០០០ (ម្ភៃលាន) រៀល ការទាមទារលើសពីនេះ: ត្រូវបដិសេធចោល។

៨.១៨.ឈ្មោះ [redacted] ៣ ចំនួន ២០.០០០.០០០ (ម្ភៃលាន) រៀល ការទាមទារលើសពីនេះ ត្រូវបដិសេធចោល។

៨.១៩.ឈ្មោះ [redacted] ឃាង ចំនួន ២០.០០០.០០០ (ម្ភៃលាន) រៀល ការទាមទារលើសពីនេះ: ត្រូវបដិសេធចោល។

៨.២០.ឈ្មោះ [redacted] វុធ ចំនួន ២០.០០០.០០០ (ម្ភៃលាន) រៀល ការទាមទារលើសពីនេះ ត្រូវបដិសេធចោល។

៨.២១.ឈ្មោះ [redacted] ផេត ចំនួន ២០.០០០.០០០ (ម្ភៃលាន) រៀល ការទាមទារលើសពីនេះ ត្រូវបដិសេធចោល។

៨.២២.ឈ្មោះ [redacted] ប្រុស ចំនួន ២០.០០០.០០០ (ម្ភៃលាន) រៀល ការទាមទារលើសពីនេះ: ត្រូវបដិសេធចោល។

៨.២៣.ឈ្មោះ [redacted] សំអុល ចំនួន ២០.០០០.០០០ (ម្ភៃលាន) រៀល ការទាមទារលើសពីនេះ: ត្រូវបដិសេធចោល។

៨.២៤.ឈ្មោះ [redacted] សាវ៉ាត ចំនួន ២០.០០០.០០០ (ម្ភៃលាន) រៀល ការទាមទារលើសពីនេះ: ត្រូវបដិសេធចោល។

៨.២៥.ឈ្មោះ [redacted] ធីម ចំនួន ២០.០០០.០០០ (ម្ភៃលាន) រៀល ការទាមទារលើសពីនេះ: ត្រូវបដិសេធចោល។

៨.២៦.ឈ្មោះ [redacted] ចិនឡាង ត្រូវជាបងប្រុសរបស់ជនរងគ្រោះឈ្មោះ [redacted] អូនណេង (រងរបួសធ្ងន់) ចំនួន ៣០.០០០.០០០ (សាមសិបលាន) រៀល ការទាមទារលើសពីនេះត្រូវបដិសេធចោល។

៩-បង្គាប់ឲ្យជនជាប់ចោទឈ្មោះ [redacted] **KUN, ឈ្មោះ** [redacted] **XING GUI, ឈ្មោះ** [redacted] **THI THUY HAO ហៅ អាហ័រ, ឈ្មោះ** [redacted] **YU និងឈ្មោះ** [redacted] **YAPING រួមគ្នាដោយសាមគ្គីសងសំណងឲ្យទៅដើមបណ្តឹងរដ្ឋប្បវេណី ដែលជាសិទ្ធិវន្តរបស់ជនរងគ្រោះបានទទួលមរណភាព** ដូចខាងក្រោម:

Scanned with CamScanner

៩.១.ឈ្មោះ [redacted] ផិត ត្រូវជាម្តាយរបស់សពឈ្មោះ [redacted] ឡៃ ចំនួន ៦០.០០០.០០០ (ហុកសិបលាន) រៀល

៩.២.ឈ្មោះ [redacted] កា ត្រូវជាម្តាយរបស់សពឈ្មោះ [redacted] រឿន ចំនួន ៦០.០០០.០០០ (ហុកសិបលាន) រៀល

៩.៣.ឈ្មោះ [redacted] យ៉ុន ត្រូវជាម្តាយរបស់សពឈ្មោះ [redacted] ប៊ុនធី ចំនួន ៦០.០០០.០០០ (ហុកសិបលាន) រៀល

៩.៤.ឈ្មោះ [redacted] សាខន ត្រូវជាប្រពន្ធរបស់សពឈ្មោះ [redacted] មៅ ចំនួន ១០០.០០០.០០០ (មួយរយលាន) រៀល ការទាមទារលើសពីនេះត្រូវបដិសេធចោល។

៩.៥.ឈ្មោះ [redacted] សុថាត ត្រូវជាប្រពន្ធសពឈ្មោះ [redacted] ចាន់ដេវីត ចំនួន ១០០.០០០.០០០ (មួយរយលាន) រៀល ការទាមទារលើសពីនេះត្រូវបដិសេធចោល។

៩.៦.ឈ្មោះ ភូន សំណាង ត្រូវជាប្រពន្ធសពឈ្មោះ [redacted] ចន្ថា ចំនួន ១០០.០០០.០០០ (មួយរយលាន) រៀល ការទាមទារលើសពីនេះត្រូវបដិសេធចោល។

៩.៧.ឈ្មោះ [redacted] អិត ត្រូវជាប្រពន្ធសពឈ្មោះ [redacted] មន ចំនួន ១០០.០០០.០០០ (មួយរយលាន) រៀល ការទាមទារលើសពីនេះត្រូវបដិសេធចោល។

៩.៨.ឈ្មោះ [redacted] ចិនឡាង ត្រូវជាកូនរបស់សពឈ្មោះ [redacted] ណា (ជាឪពុក) ឈ្មោះ [redacted] ដែន (ជាម្តាយ) ចំនួន ២០០.០០០.០០០ (ពីររយលាន) រៀល ការទាមទារលើសពីនេះត្រូវបដិសេធចោល។

៩.៩.ឈ្មោះ [redacted] ញ៉ ត្រូវជាឪពុករបស់សពឈ្មោះ [redacted] ចាន់ថន ចំនួន ១០០.០០០.០០០ (មួយរយលាន) រៀល ការទាមទារលើសពីនេះត្រូវបដិសេធចោល។

៩.១០.ឈ្មោះ [redacted] ម៉ារ៉ា ត្រូវជាប្រពន្ធសពឈ្មោះ [redacted] សុខហៀង ចំនួន ១០០.០០០.០០០ (មួយរយលាន) រៀល ការទាមទារលើសពីនេះត្រូវបដិសេធចោល។

៩.១១.ឈ្មោះ [redacted] យ៉ុន ត្រូវជាប្រពន្ធសពឈ្មោះ [redacted] មៅ ចំនួន ១០០.០០០.០០០ (មួយរយលាន) រៀល ការទាមទារលើសពីនេះត្រូវបដិសេធចោល។

៩.១២.ឈ្មោះ [redacted] ហាត់ ត្រូវជាប្រពន្ធរបស់សពឈ្មោះ [redacted] វិច្ឆិរ៉ា ចំនួន ១០០.០០០.០០០ (មួយរយលាន) រៀល ការទាមទារលើសពីនេះត្រូវបដិសេធចោល។

៩.១៣.ឈ្មោះ [redacted] វណ្ណា ត្រូវជាម្តាយរបស់សពឈ្មោះ [redacted] បញ្ញា ចំនួន ១០០.០០០.០០០ (មួយរយលាន) រៀល ការទាមទារលើសពីនេះត្រូវបដិសេធចោល។

៩.១៤.ឈ្មោះ [redacted] ផៃ ត្រូវជាឪពុករបស់សពឈ្មោះ [redacted] ជាន់ណា ចំនួន ១០០.០០០.០០០ (មួយរយលាន) រៀល ការទាមទារលើសពីនេះត្រូវបដិសេធចោល។

៩.១៥.ឈ្មោះ [redacted] ថន ត្រូវជាឪពុករបស់សពឈ្មោះ [redacted] ឃាន ចំនួន ១០០.០០០.០០០ (មួយរយលាន) រៀល ការទាមទារលើសពីនេះត្រូវបដិសេធចោល។

៩.១៦.ឈ្មោះ [redacted] ម៉ុម ត្រូវជាម្តាយបង្កើតរបស់សពឈ្មោះ [redacted] ចន្ថា និងត្រូវជាម្តាយក្មេករបស់សពឈ្មោះ [redacted] ប្រុស ចំនួន ២០០.០០០.០០០ (ពីររយលាន) រៀល ការទាមទារលើសពីនេះត្រូវបដិសេធចោល។

៩.១៧.ឈ្មោះ [redacted] សុភា ត្រូវជាប្រពន្ធរបស់សពឈ្មោះ គុន ទីម ចំនួន ១០០.០០០.០០០ (មួយរយលាន) រៀល ការទាមទារលើសពីនេះត្រូវបដិសេធចោល។

Scanned with CamScanner

៩.១៨.ឈ្មោះ [redacted] កែនរស្មី ត្រូវជាប្តីរបស់សពឈ្មោះ [redacted] សំអង ចំនួន ១០០.០០០.០០០ (មួយរយលាន) រៀល ការទាមទារលើសពីនេះត្រូវបដិសេធចោល។

៩.១៩.ឈ្មោះ [redacted] ស្រីកា ត្រូវជាបងស្រីរបស់សពឈ្មោះ [redacted] សុភ័ណ្ឌា ចំនួន ១០០.០០០.០០០ (មួយរយលាន) រៀល ការទាមទារលើសពីនេះត្រូវបដិសេធចោល។

៩.២០.ឈ្មោះ [redacted] ប្រុស ត្រូវជាឪពុករបស់សពឈ្មោះ [redacted] សំណាង និងសពឈ្មោះ [redacted] ភត្រា ចំនួន ២០០.០០០.០០០ (ពីររយលាន) រៀល ការទាមទារលើសពីនេះត្រូវបដិសេធចោល។

៩.២១.ឈ្មោះ [redacted] សារុន ត្រូវជាប្រពន្ធរបស់សពឈ្មោះ [redacted] ម៉េង ចំនួន ១០០.០០០.០០០ (មួយរយលាន) រៀល ការទាមទារលើសពីនេះត្រូវបដិសេធចោល។

៩.២២.ឈ្មោះ [redacted] លេង ត្រូវជាប្រពន្ធរបស់សពឈ្មោះ [redacted] ថាវ ហៅ ចាន់តូ ចំនួន ១០០.០០០.០០០ (មួយរយលាន) រៀល ការទាមទារលើសពីនេះត្រូវបដិសេធចោល។

១០-វត្ថុចាប់យកមាន:

-ឯកសារមួយចំនួន

ត្រូវប្រគល់ឲ្យម្ចាស់ដើមវិញ តាមមាត្រា ៣៥៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

១១.ហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជាចំពោះទណ្ឌិតឈ្មោះដូចខាងក្រោម:

ក.ឈ្មោះ [redacted] **KUN** ភេទប្រុស អាយុ៣៩ ឆ្នាំ ជនជាតិចិន (មានសាវតារជាតិខាងលើ)

ខ.ឈ្មោះ [redacted] **XING GUI** ភេទប្រុស អាយុ៤៨ ឆ្នាំ ជនជាតិចិន (មានសាវតារជាតិខាងលើ)

គ.ឈ្មោះ [redacted] **THI THUY HAO** ហៅ **អាហ័រ** ភេទស្រី កើតថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៧៧ ជនជាតិវៀតណាម (មានសាវតារជាតិខាងលើ)

ឃ.ឈ្មោះ: ឈ្មោះ [redacted] **YAPING** ភេទស្រី អាយុ៤៣ ឆ្នាំ ជនជាតិចិន (មានសាវតារជាតិខាងលើ)

ង.ឈ្មោះ [redacted] **YU** ភេទ ប្រុស អាយុ២៩ ឆ្នាំ ជនជាតិចិន (មានសាវតារជាតិខាងលើ)

បន្ទាប់ពីអនុវត្តទោសពន្ធនាគារចប់សម្រាប់រយៈពេល០៥ (ប្រាំ) ឆ្នាំ។ ការហាមឃាត់នេះជាវិធានការរក្សាទុកទណ្ឌិតឲ្យសងសំណងទៅដើមបណ្តឹងរដ្ឋប្បវេណី ដែលមានចែងក្នុងសេចក្តីសម្រេចទី៧, ទី៨ និងទី៩ នៃសាលក្រមនេះ។

ទណ្ឌិតទាំងប្រាំនាក់ខាងលើត្រូវប្រគល់លិខិតឆ្លងដែនរបស់ខ្លួនឲ្យទៅក្រឡាបញ្ជីសាលាដំបូងខេត្តព្រះសីហនុតម្កល់ទុកតាមមាត្រា៦០ នៃក្រមព្រហ្មទណ្ឌ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២៥ និងថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២០ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] **KUN, ឈ្មោះ** [redacted] **XING GUI, ឈ្មោះ** [redacted] **YAPING និងឈ្មោះ** [redacted] **YU** និងកំពាំងមុខកំពាំងមុខជនជាប់ចោទឈ្មោះ [redacted] **THI THUY HAO** ហៅ **អាហ័រ,** និងឈ្មោះ [redacted] **ប៊ុនធឿន** ចាត់ទុកថា**ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី** និងប្រកាសជាសាធារណៈនៅថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ២០២០ ទុកសិទ្ធិឱ្យប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់៕

ក្រឡាបញ្ជី	ចៅក្រមប្រឹក្សា	ចៅក្រមប្រឹក្សា	ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
ហត្ថលេខា	[redacted]		

ត្រឹមត្រូវតាមច្បាប់ដើម
ខេត្តព្រះសីហនុ, ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២០
ក្រឡាបញ្ជី

[redacted]

បានឃើញ
ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]